ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ

កម្មវិធីព្រៃឈើជាតិ

# កម្រងរបាយការណ៍

## នៃសិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិ



ខេត្តកំពង់ចាម ថ្ងៃទី ៤-៥ មិថុនា ឆ្នាំ២០០៩

# មាតិការឿង

-របាយការណ៍សង្ខេប

-របាយការណ៍ស្តីពីលទ្ធផលកិច្ចពិគ្រោះយោបល់ជាសាធារណៈលើកម្មវិធីព្រៃឈើជាតិ នៅខេត្តកំពង់ចាម

-ឧបសម្ព័ន្ធ ១: បញ្ជីឈ្មោះសិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលា

-ឧបសម្ព័ន្ធ ២: របៀបវារៈកម្មវិធីសិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធារណៈនៅខេត្តកំពង់ចាម

-ឧបសម្ព័ន្ធ ៣: បទបង្ហាញអំពីសិក្ខាសាលា

-ឧបសម្ព័ន្ធ ៤: ដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិនៅកម្ពុជា

-ឧបសម្ព័ន្ធ ៥: បទបង្ហាញពីឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិ

-ឧបសម្ព័ន្ធ ៦: បទបង្ហាញដោយសង្ខេបពីកម្មវិធីព្រៃឈើជាតិពីទី ១-៥

-ឧបសម្ព័ន្ធ ៧: បទបង្ហាញស្តីពីកម្មវិធីហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

-ឧបសម្ព័ន្ធ ៨: សំណួរ ចម្លើយ ពីកម្មវិធីព្រៃឈើជាតិ

-ឧបសម្ព័ន្ធ ៩: បញ្ជីឈ្មោះសិក្ខាកាមពិភាក្សាតាមក្រុម

-ឧបសម្ព័ន្ធ ១០: បទបង្ហាញពីលទ្ធផលរបស់ក្រុមពិភាក្សា

-ឧបសម្ព័ន្ធ ១១: សំណួរ ចម្លើយ ពីលទ្ធផលពិភាក្សាតាមក្រុម

-ឧបសម្ព័ន្ធ ១២: មតិចាប់អារម្មណ៍របស់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

-ឧបសម្ព័ន្ធ១៣:របាយការណ៍បូកសរុបលទ្ធផលសិក្ខាសាលារបស់លោក ហ៊ុន-អៀង នាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ។

-ឧបសម្ព័ន្ធ១៤:រូបភាពស្តីពីសកម្មភាពមួយចំនួននៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនៅខេត្តកំពង់ចាម ។

# របាយការណ៍សង្ខេប

ដើម្បីធ្វើឱ្យសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះមានខ្លឹមសារកាន់តែប្រសើរអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព និង ឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋានរដ្ឋបាលព្រៃឈើបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ សាធារណៈមួយទៀតប្រព្រឹត្តទៅនៅថ្ងៃទី០៤-០៥ខែមិថុនា ឆ្នាំ ២០០៩នៅសណ្ឋាគារភ្នំប្រុសនាទីក្រុងកំពង់ចាម ខេត្តកំពង់ចាម ។អង្គសិក្ខាសាលានេះជាអង្គសិក្ខាសាលាលើកទី៥ មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសរុបចំនួន ១៦៤រូប ។

បទបង្ហាញពីលទ្ធផលទទួលបានពីសិក្ខាសាលាទាំងបួនលើកមុនត្រូវបានលើកយកមកបង្ហាញដល់សិក្ខាកាមដើម្បីឱ្យពួកគេបានយល់ពីលទ្ធផលសម្រេចបាននាដេល់អ្នកចូលរួមជាមួយនិងបទបង្ហាញផ្សេងៗទៀត។ ជាលទ្ធផលទទួលបានមកវិញតាមរយៈក្រុមពិភាក្សាផ្អែកលើប្រធានបទ " ឯកសារគោលកម្មវិធីព្រៃឈើជាតិ " រួមមានៈ ពង្រឹងការអនុវត្តន៏ច្បាប់ បង្កើនការយកចិត្តទុកដាក់បង្កើតសហគមន៏ព្រៃឈើឱ្យបានកាន់តែច្រើន និងស្នើសុំឱ្យមានការបង្កើតច្បាប់ស្តីពីការយកសេវាកម្មបរិស្ថានរបស់ព្រៃឈើ ដើម្បីងាយស្រួលដល់ការអនុវត្តន៏ និងទាញយកចំណូលឱ្យបានសមស្របក្នុងទិសដៅកាត់បន្ថយភាពក្រីក្រស្របតាមផែនការអភិវឌ្ឍន៏ជាតិ។ ឯ "កម្មវិធីហិរញ្ញប្បទានព្រៃឈើ" រួមមានៈ តម្រូវឱ្យមានការគិតគូរឡើងវិញលើការចំណាយឱ្យបានសមស្របតាមកម្មវិធីនីមួយៗ ហើយការកំណត់ព្រំប្រទល់ព្រៃវាជាការចាំបាច់ និងបន្ទាន់ដើម្បីដោះស្រាយបញ្ហាជម្លោះដែលកំពុងកើតមាននាពេលបច្ចុប្បន្ន ប៉ុន្តែគួរកាត់បន្ថយការចំណាយលើកម្មវិធីនេះ ហើយបំពេញថវិកាបន្ថែមលើកម្មវិធីបួនផ្សេងទៀតជាពិសេសបង្កើនឱ្យបានសមស្របលើកម្មវិធីទីប្រាំ។

ក្រៅពីលទ្ធផលក្រុមពិភាក្សាខាងលើ អ្នកចូលរួមពីមន្ទីរ ក្រសួង សហគមន៏ អង្គការមិនមែនរដ្ឋាភិបាល ព្រះសង្ឃ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងអាជ្ញាធរដែនដីបានធ្វើការចាប់អារម្មណ៏គាំទ្រដល់ដំណើរការរៀបចំ និងខ្លឹមសារដែលមានចែងក្នុងឯកសារសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ។

ពិធីបិទ និងបើកកម្មវិធីអង្គសិក្ខាសាលាបានការចូលរួមយ៉ាងពេញទំហឹងពីថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ អភិបាលរងខេត្តកំពង់ចាម និងដៃគូអភិវឌ្ឍន៏។ ជារួមសិក្ខាសាលាចំនួនពីរថ្ងៃនេះបានទទួលលទ្ធផលជាផ្លែផ្កាស្របទៅតាមសេចក្តីរំពឹងទុក និងមានការពេញចិត្តពេញថ្លើមពីអ្នកចូលរួមទាំងអស់ ។

របាយការណ៏សង្ខេបនេះ ពុំមានរៀបរាប់លំអិតអំពីលទ្ធផលនៃអង្គសិក្ខាសាលាទេ។ លទ្ធផលទាំងស្រុងមានរៀបរាប់លំអិតក្នុងរបាយការណ៏រួមដែលជាផ្នែកសំខាន់ជាងគេក្នុងកំរងរបាយការណ៏នេះ។

# របាយការណ៍
# ស្តីពីលទ្ធផលកិច្ចពិគ្រោះយោបល់ជាសាធារណៈលើកម្មវិធីព្រៃឈើជាតិ នៅខេត្តកំពង់ចាម

## ១~សេចក្តីផ្តើម

ក្នុងអំឡុងខែមិនា ២០០៩ កន្លងមក កម្មវិធីព្រៃឈើជាតិបានរៀបចំឡើងនៅអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំងបួនរួចហើយ ហើយមតិយោបល់របស់បណ្តាភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ ត្រូវបានប្រមូលយកដើម្បីធ្វើការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ ។ ដើម្បីផ្តល់ឱកាសឱ្យអ្នកចូលរួមផ្តល់យោបល់បានកាន់តែច្រើនថែមទៀត ដើម្បីឱ្យខ្លឹមសារមានភាពស៊ីជម្រៅកាន់តែល្អ ទើបកិច្ចពិគ្រោះយោបល់ជាសាធារណៈលើកម្មវិធីព្រៃឈើជាតិត្រូវបានរៀបចំឡើងម្តងទៀតនៅខេត្តកំពង់ចាម ។

## ២~កិច្ចដំណើរការសិក្ខាសាលា

កិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីកម្មវិធីព្រៃឈើជាតិនៅខេត្តកំពង់ចាម បានរៀបចំឡើងនៅសណ្ឋាគារ **ភ្នំប្រុស** នៅថ្ងៃទី០៨-០៩ ខែមិថុនា ឆ្នាំ២០០៩ ក្រោមអធិបតីភាព ឯកឧត្តម **ទី សុគន្ធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ឯកឧត្តម **ហោ សុភាព** រដ្ឋលេខាធិការក្រសួងព័ត៌មាន ឯកឧត្តម **ម៉េង សួន** អភិបាលរងខេត្តកំពង់ចាម លោក **Michael Scott** តំណាងអង្គការ DANIDA និងលោក **ជួប ប៉ារីស៍** តំណាងអង្គការ FAO ។

សិក្ខាកាមចូលរួមក្នុងកិច្ចពិគ្រោះយោបល់នេះមកពីបណ្តាអ្នកពាក់ព័ន្ធរួមមាន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាក់ព័ន្ធ រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិ មន្ទីរ និងនាយកដ្ឋានពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សារព័ត៌មាន ព្រះសង្ឃ និងតំណាងសហគមន៍ព្រៃឈើមានចំនួនសរុប១៦៨នាក់មកពី៩ខេត្ត-ក្រុង ។បញ្ជីឈ្មោះសិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលាមានភ្ជាប់នៅឧបសម្ព័ន្ធ១ ។

វិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងអង្គសិក្ខាសាលារួមមាន សុន្ទរកថាស្វាគមន៍របស់អភិបាលរងខេត្តកំពង់ចាម ចំណាប់អារម្មណ៍របស់តំណាងអង្គការ FAO, DANIDA និងសុន្ទរកថាបើកសិក្ខាសាលារបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ បទបង្ហាញពីគោលបំណងនៃសិក្ខាសាលា បទបង្ហាញពីដំណើរការរៀបចំចងក្រងកម្មវិធីព្រៃឈើជាតិ វេទិកាសំនួរ-ចម្លើយ ការបែងចែកក្រុមពិភាក្សាជា០៤ក្រុមទៅតាមប្រធានបទ បទបង្ហាញពីលទ្ធផលពិភាក្សាតាមក្រុម និងមតិចាប់អារម្មណ៍របស់ តំណាងអង្គភាព ពាក់ព័ន្ធដែលបានចូលរួម របាយការណ៍ បូកសរុបរបស់នាយខ័ណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ព្រមទាំងការបិទសិក្ខាសាលាដោយឯកឧត្តម

អនុប្រធានរដ្ឋបាលព្រៃឈើ។ របៀបវារៈកម្មវិធីសិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធារណៈនៅខេត្តកំពង់ចាម មានភ្ជាប់នៅ ឧបសម្ព័ន្ធ ២។

## ៣. លទ្ធផលសិក្ខាសាលា

### ៣.១: ពិធីបើកសិក្ខាសាលា

ក្នុងសុន្ទរកថាស្វាគមន៍ ឯកឧត្តម **ម៉េង សួន** អភិបាលរងខេត្តកំពង់ចាមបានលើកឡើងពីស្ថានភាពព្រៃឈើនៅខេត្តកំពង់ចាមពីមុន និងបច្ចុប្បន្ន និងបានសំដែងនូវសេចក្តីរីករាយដែលសិក្ខាសាលានេះត្រូវបានរៀបចំនៅលើទឹកដីខេត្តកំពង់ចាម ព្រមទាំងបានគាំទ្រកម្មវិធីព្រៃឈើជាតិ ដែលបានរៀបចំឡើងដោយរដ្ឋបាលព្រៃឈើ និងបណ្តាអ្នកពាក់ព័ន្ធ។

លោក **ជួប ប៉ារីស៍** តំណាងអង្គការ FAO បានធ្វើការចាប់អារម្មណ៏ថា នៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានឯកភាពថា យុទ្ធសាស្រ្តផ្អែកតាមកម្មវិធី (Programme Based Approaches) ជាយុទ្ធសាស្រ្តអភិវឌ្ឍន៍ដ៏មានប្រសិទ្ធភាព ហើយកម្មវិធីព្រៃឈើជាតិ ជាយុទ្ធសាស្រ្តផ្អែក តាមកម្មវិធី ព្រមទាំងមានផែនទីបង្ហាញផ្លូវច្បាស់លាស់ដែលនឹងត្រូវបញ្ចប់នៅខែកញ្ញា ឆ្នាំ២០០៩ ហើយសង្ឃឹមថា កម្មវិធីព្រៃឈើជាតិនេះនឹងក្លាយជាឧបករណ៏គតិយុត្តក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

លោក **Michael Scott** តំណាងអង្គការ DANIDA បានសំដែងការចាប់អារម្មណ៏ថា រដ្ឋបាលព្រៃឈើបានខិតខំរៀបចំកម្មវិធីព្រៃឈើជាតិនេះជាច្រើនឆ្នាំមកហើយ ហើយសិក្ខាសាលាថ្ងៃនេះបង្ហាញនូវការតាំងចិត្តមួយយ៉ាងធំ ក្នុងការបញ្ចប់កម្មវិធីព្រៃឈើជាតិតាមការគ្រោងទុក។ កម្មវិធីព្រៃឈើជាតិនេះជាសូចនាករមួយក្នុងចំណោមសូចនាករទាំង៣ ក្នុងនោះមានការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៏ ការធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ និងការរៀបចំកម្មវិធីព្រៃឈើជាតិនេះ។

ឯកឧត្តម **ទី សុគន្ធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា ដោយបានលើកឡើងថា ការបាត់បង់ព្រៃឈើជាបញ្ហារបស់ពិភពលោកទាំងមូល ហើយតាមទិន្នន័យរបស់ FAO ផ្ទៃដីព្រៃឈើជាង២០លានហិកតា បានក្លាយជាវាលរហោស្ថានគ្មានជីជាតិ ដែលក្នុងនោះភាគច្រើននៅអាហ្រ្វិក អាមេរិកខាងជើង អាស៊ីកណ្តាល និងអូស្រ្តាលី។ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពក្លាយជាបញ្ហាសំខាន់ និងយកចិត្តទុកដាក់ជាងគេក្នុងការពិភាក្សាស្តីពីបញ្ហាបម្រែបម្រួលអាកាសធាតុ។ សម្រាប់កម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពជារបៀបវារៈនយោបាយអាទិភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយការកើនឡើងកំដៅផែនដី។ ក្នុងអាណត្តិទី៣នៃរាជរដ្ឋាភិបាលកម្ពុជា បទល្មើសព្រៃឈើមានការថយចុះ៧ដងធៀប

នឹងបទល្មើសព្រៃឈើដែលកើតឡើងនៅអាណត្តិទី២។ ផ្ទៃដីព្រៃឈើដែលកាន់កាប់ដោយខុសច្បាប់ជាង២៦ម៉ឺនហិកតាត្រូវបានដកហូតមកជាសម្បត្តិរដ្ឋវិញ។ ឯកឧត្តមប្រធានរដ្ឋបាលព្រៃឈើក៏បានរំលឹកពីប្រសាសន៍របស់សម្តេច **ហ៊ុន សែន** ក្នុងឱកាសបិទមហាសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៩ ដែលបានចេញបទបញ្ជាដល់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ អាជ្ញាធរដែនដី និងមេឃុំ ឱ្យបញ្ឈប់ការបញ្ជាក់លើលិខិត ទិញ លក់ដីព្រៃឈើ និង ព្រៃលិចទឹក។ គ្រប់សមត្ថកិច្ចទាំងអស់ត្រូវចូលរួមជាមួយរដ្ឋបាលព្រៃឈើក្នុងការកំណត់ព្រំប្រទល់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យបានយ៉ាងតិច១000គីឡូម៉ែត្រ ក្នុង១ឆ្នាំ ដើម្បីរក្សាគម្របព្រៃឈើឱ្យបាន60% ធៀបនឹងផ្ទៃប្រទេសនៅឆ្នាំ២០១៥។ ឯកឧត្តមប្រធានរដ្ឋបាលព្រៃឈើក៏បានបញ្ជាក់ទៀតថា កម្ពុជាបានបញ្ឈប់ការនាំចេញឈើ ហើយយកចិត្តទុកដាក់លើការលក់កាបូនព្រៃឈើដើម្បីយកប្រាក់វិញ ហើយការដាំឈើជាការងារអាទិភាព។

## ៣.២: បទបង្ហាញអំពីអង្គសិក្ខាសាលា និងអំពីខ្លឹមសារឯកសារព្រាងកម្មវិធីព្រៃឈើជាតិ

បន្ទាប់មកលោកបណ្ឌិត **សុខ ហេង** អ្នកសម្របសម្រួលកម្មវិធីព្រៃឈើជាតិបានធ្វើបទបង្ហាញអំពីគោលបំណងនិងលទ្ធផលរំពឹងទុករបស់កម្មវិធីព្រៃឈើជាតិ។ សិក្ខាសាលានេះមានគោលបំណងទទួលមតិ ទស្សនៈ និង យោបល់ពីអ្នកពាក់ព័ន្ធនានា ដើម្បីកែលំអឯកសារពង្រាងកម្មវិធីព្រៃឈើជាតិឱ្យកាន់តែប្រសើរ បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងអំពីកម្មវិធីព្រៃឈើជាតិ។ ចំណែកលទ្ធផលរំពឹងទុកគឺ ការយល់ដឹងបន្ថែមពីកម្មវិធីព្រៃឈើជាតិ ទទួលបានការរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន និង បង្កើនការគាំទ្រ ការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ និងការអនុវត្តកម្មវិធីព្រៃឈើជាតិ រួមទាំងបទបង្ហាញអំពីដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិនៅកម្ពុជា។ បទបង្ហាញអំពីអង្គសិក្ខាសាលាមានភ្ជាប់នៅឧបសម្ព័ន្ធ៣ និង បទបង្ហាញពីដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិនៅកម្ពុជា មានភ្ជាប់នៅឧបសម្ព័ន្ធ៤ ។

## ៣.៣: បទបង្ហាញសេចក្តីព្រាង

ជាបន្ត លោក Arvid Sloth បានធ្វើបទបង្ហាញពីឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិ ដោយបានគូសបញ្ជាក់ថា កម្មវិធីព្រៃឈើជាតិគឺជាដំណើការមួយដោយមានការចូលរួមពីអន្តរវិស័យក្នុងការកសាងផែនការការអនុវត្ត និងការតាមដាន ដែលបង្កើតជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយដើម្បីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ បទបង្ហាញពីឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិមានភ្ជាប់នៅឧបសម្ព័ន្ធ៥ ។

ជាបន្ទាប់មក លោក **ហុង គីមហ៊ាន** បានធ្វើបទបង្ហាញដោយសង្ខេបពីកម្មវិធីព្រៃឈើជាតិពីទី ១ដល់ ទី៥ ដែលបានធ្វើសិក្ខាសាលាចំនួនបួនលើកក្នុងខែមិនាកន្លងមក មានភ្ជាប់នៅឧបសម្ព័ន្ធ៦។

ឯកឧត្តម **ថន សារ៉ាត់** បានធ្វើបទបង្ហាញពីកម្មវិធីទី៦ ស្តីពីកម្មវិធីហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដែលក្នុងនោះមានអនុកម្មវិធីចំនួន៥ រួមមាន: អនុកម្មវិធីហិរញ្ញប្បទានពីរដ្ឋាភិបាល អនុកម្មវិធីហិរញ្ញប្បទានពីព្រៃឈើជាតិ អនុកម្មវិធីហិរញ្ញប្បទានពីវិស័យឯកជន និងសហគមន៍ អនុកម្មវិធីហិរញ្ញប្បទានតាមរយៈជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល និងអនុកម្មវិធីហិរញ្ញប្បទានរបកគំហើញ CDM/REDD កីឡាប្រមាញ់ និងទេសចរណ៍ធម្មជាតិ។ ចំពោះផែនការចំណាយក្នុងរយៈពេល ១២ឆ្នាំនៃកម្មវិធីទាំង៥ក្នុងកម្មវិធីព្រៃឈើជាតិមានទឹកប្រាក់សរុបចំនួន ៧០,៦លាន ដុល្លារសហរដ្ឋអាមេរិក។ បទបង្ហាញស្តីពីកម្មវិធីហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព មានភ្ជាប់នៅឧបសម្ព័ន្ធ៧។

ក្រោយពីបទបង្ហាញខាងលើបានបញ្ចប់ វេទិកាសំនួរ-ចម្លើយត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱកាសដល់សិក្ខាកាមក្នុងអង្គសិក្ខាសាលាសាកសួរបន្ថែមពីបញ្ហាដែលពាក់ព័ន្ធ។ សំណួរ ចម្លើយពីកម្មវិធីព្រៃឈើជាតិមានភ្ជាប់នៅឧបសម្ព័ន្ធ ៨ ។

## ៣.៤: ការពិភាក្សា និងលទ្ធផលតាមក្រុម

បន្ទាប់ពីវេទិកាសំនួរ-ចម្លើយ អង្គសិក្ខាសាលាបានធ្វើការបែងចែកសិក្ខាកាមជា៤ក្រុម ដោយពីរក្រុមពិភាក្សាលើប្រធានបទ"ឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិ" និងពីរក្រុមទៀតពិភាក្សាលើប្រធានបទ"កម្មវិធីហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព។ បញ្ជីឈ្មោះសិក្ខាកាមពិភាក្សាតាមក្រុមមានភ្ជាប់នៅឧបសម្ព័ន្ធ ៩។ ជាលទ្ធផល ដើម្បីដោះស្រាយចំពោះ ឧបសគ្គចំបង៧ ក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងដើម្បីទប់ស្កាត់ការគំរាមកំហែងពីការកាប់រានដីព្រៃ ធ្វើជាកម្មសិទ្ធិត្រូវ :

-កំណត់មុខងារព្រៃឈើឱ្យបានច្បាស់លាស់ដើម្បីងាយស្រួលធ្វើផែនការគ្រប់គ្រងព្រៃឈើឱ្យបានសមស្រប។

-ផែនការគ្រប់គ្រងព្រៃឈើត្រូវផ្អែកលើច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារ។

-បង្កើនការបង្កើតសហគមន៍ព្រៃឈើឱ្យបានចំនួនកាន់តែច្រើន និងកសាងសមត្ថភាពជំនាញដល់អ្នកគ្រប់គ្រងព្រៃឈើ។

-ស្វះស្វែងរកថវិកាគាំទ្រកម្មវិធីឱ្យបានតាមផែនការគ្រោងទុក។

-បង្កើនការអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

-ការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនណាមួយត្រូវមានការពិគ្រោះ និងព្រមព្រៀងពីសហគមន៍មូលដ្ឋាន។

-បន្ថយការប្រើប្រាស់ថាមពលបានពីព្រៃឈើ ទៅជាការប្រើប្រាស់ថាមពលដូចជា ឧស្ម័ន អគ្គីសនី...។

-បង្កើនកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីពង្រឹងកិច្ចការពារព្រៃឈើ។

-មន្ត្រីរដ្ឋបាលព្រៃឈើត្រូវបោះទីតាំងនៅក្បែរដែនព្រៃ និងដាក់ចុះកម្មវិធីត្រួតពិនិត្យព្រៃឱ្យបានជាប្រចាំ។

-ពង្រឹងការអនុវត្តន៍ច្បាប់ស្ដីពីព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយមានការចូលរួមពេញទំហឹងក្នុងការត្រួតពិនិត្យពីអាជ្ញាធរមូលដ្ឋាន។

-ពង្រឹងការអនុវត្តន៍ច្បាប់ចំពោះបុគ្គលដែលរំលោភដីព្រៃក្រោមរូបភាពអភិវឌ្ឍន៍។

-បោះបង្គោលព្រំប្រទល់ព្រៃ និងដាក់ស្លាកសញ្ញាសំគាល់ដីព្រៃឈើឱ្យបានច្បាស់លាស់។

-បញ្ឈប់ការចេញលិខិតកាន់កាប់ដីព្រៃឈើ ដោយអាជ្ញាធរមូលដ្ឋាន។

ដើម្បីបង្កើនប្រាក់ចំណូល និងបែងចែកផលប្រយោជន៍ដោយសមធម៌ពីសេវាកម្មបរិស្ថានរបស់ព្រៃឈើត្រូវៈ

-កំណត់យកពន្ធលើឧស្សាហកម្មដែលប៉ះពាល់ដល់បរិស្ថាន ហើយបង្វិលថវិកានេះគាំទ្រដល់សហគមន៍ព្រៃឈើ។

-វិស័យឯកជនត្រូវបង់ថ្លៃសួយសារជូនរដ្ឋសម្រាប់សេវាកម្មបរិស្ថានរបស់ព្រៃឈើ ហើយរដ្ឋត្រូវផ្ដល់ឱកាសដល់វិស័យឯកជនធ្វើការអភិវឌ្ឍន៍តាមគោលការណ៍និរន្តរភាព។

-ក្រុមហ៊ុនវារីអគ្គិសនីត្រូវបង់ថ្លៃឱ្យអ្នកការពារព្រៃឈើ។

-បង្កើតច្បាប់ស្ដីពីការប្រើប្រាស់សេវាកម្មបរិស្ថានរបស់ព្រៃឈើ។

ចំពោះក្រសួងអប់រំគួររួមចំណែកក្នុងការគ្រប់គ្រងធនធានធម្មជាតិ តាមរយៈសកម្មភាពៈ

-បញ្ចូលច្បាប់ព្រៃឈើ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិរក្សព្រៃឈើក្នុងកម្មវិធីសិក្សា។

-ធ្វើការស្រាវជ្រាវដែលមានលក្ខណៈជាការរៀនសូត្រផង និងអនុវត្តន៍ផង និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

-គួរមានទស្សនកិច្ចសិក្សាបង្កើនការយល់ដឹង និងបណ្ដុះបណ្ដាលឱ្យចេះទប់ស្កាត់បទល្មើសព្រៃឈើ យល់ដឹងពីសារប្រយោជន៍របស់ព្រៃឈើ រុក្ខវប្បកម្ម និងអេកូឡូស៊ីព្រៃឈើ។

ចំពោះក្រុមពីរទៀតដែលពិភាក្សាលើប្រធានបទ កម្មវិធីហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ទទួលបានលទ្ធផលដូចខាងក្រោមៈ

ការប៉ាន់ប្រមាណនូវថវិកាសម្រាប់អនុវត្តកម្មវិធីទាំងប្រាំមានៈ

-ត្រូវសិក្សាពីតម្រូវការជាក់ស្ដែងរបស់កម្មវិធីនីមួយៗ ទើបអាចប៉ាន់ប្រមាណបានត្រឹមត្រូវ ដោយក្នុងនោះកម្មវិធីទី១ ការចំណាយមានចំនួនច្រើនពេក ដោយឡែកកម្មវិធីបួនទៀត ថវិកាចំណាយមានចំនួនតិចពេក។

-ត្រូវសិក្សាអំពីទំនាក់ទំនងរវាងកម្មវិធីទាំងអស់ក្នុងកម្មវិធីព្រៃឈើជាតិ ដើម្បីឱ្យមានភាពរលូនក្នុងការអនុវត្តន៍សកម្មភាព និងថវិកា។

ការងារអាទិភាពដែលអ្នកពាក់ព័ន្ធចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ ទាក់ទងនឹងការប្រមូលប្រាក់ចំណូលពីអាជីវកម្មឈើមូល គឺៈ

-រៀបចំប្រព័ន្ធគ្រប់គ្រងវិស័យព្រៃឈើឱ្យបានល្អ (មានផែនការអាជីវកម្ម លទ្ធកម្ម ការត្រួតពិនិត្យ និងវាយតម្លៃ) ដោយក្នុងនោះត្រូវរៀបចំ និងវិភាគផែនការប្រើប្រាស់ឈើក្នុងស្រុកឱ្យបានសមស្រប រៀបចំនីតិវិធីរដ្ឋបាលឱ្យបានខ្លីជាងមុន។

ការងារអាទិភាពដែលអ្នកពាក់ព័ន្ធចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ ទាក់ទងនឹងការបណ្តាក់ទុន និងការប្រមូលប្រាក់ចំណូលពីការលក់កាបូនព្រៃឈើក្រោមយន្តការ REDD គឺៈ

-យកប្រាក់ដែលបានពីលក់កាបូនព្រៃឈើទៅជួយដល់សហគមន៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តដល់កិច្ចខិតខំប្រឹងប្រែង ការថែរក្សា ការការពារព្រៃធម្មជាតិដោយសហគមន៍មូលដ្ឋាន។

-ធ្វើការផ្សព្វផ្សាយពីផលប្រយោជន៍បានពី REDD ឱ្យបានទូលំទូលាយ ពិសេសដល់សហគមន៍មូលដ្ឋាន និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។

ការងារអាទិភាពដែលអ្នកពាក់ព័ន្ធចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ ទាក់ទងនឹងការបណ្តាក់ទុន និងការប្រមូលប្រាក់ចំណូលពីសម្បទានបែបអភិរក្ស គឺៈ

-បង្កើតគោលការណ៍សម្រាប់សហគមន៍ចំពោះការបណ្តាក់ទុនដោយសហគមន៍មូលដ្ឋាន។

-ផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងធ្វើការបែងចែកផលចំណូលបានពីសម្បទានបែបអភិរក្សនេះដល់សហគមន៍ក្នុងទិសដៅបង្កើនជីវភាព។

-ធ្វើការសិក្សា និងពិភាក្សាជាមួយសហគមន៍ដោយផ្ទាល់ដើម្បីឱ្យដឹងពីតម្រូវការពិតប្រាកដរបស់សហគមន៍។

ដើម្បីជម្រុញឱ្យមានប្រសិទ្ធភាពលើការបោះបង្គោលព្រំ ការសិក្សាស្រាវជ្រាវ ការដាំដុះ ដោយមានការត្រួតពិនិត្យពីស្ថាប័នឯករាជ្យត្រូវ :

-បង្កើតគណៈកម្មការចម្រុះដើម្បីធ្វើការបោះបង្គោលព្រំព្រៃឈើ និងពង្រឹងសមត្ថភាពដល់គណៈកម្មការដែលបានបង្កើត។

-ជ្រើសរើសយកប្រព័ន្ធម៉ៅការ និងដាក់ឱ្យដេញថ្លៃជាសាធារណៈក្នុងការបោះបង្គោលព្រំព្រៃ។

-ផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយពីព័ត៌មានទាំងនេះ។ បទបង្ហាញពីលទ្ធផលរបស់ក្រុមពិភាក្សាមានភ្ជាប់នៅឧបសម្ព័ន្ធទី ១០។

បន្ទាប់ពីបទបង្ហាញពីលទ្ធផលពិភាក្សាតាមក្រុមរួចមក តំណាងក្រុមនីមួយៗបានឆ្លើយទៅនឹងសំនួរដែលសិក្ខាកាមបានលើកឡើងទាក់ទងនឹងលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ សំណួរ-ចម្លើយ ពីលទ្ធផលពិភាក្សាតាមក្រុមមានភ្ជាប់នៅឧបសម្ព័ន្ធ ១១។

## ៣.៥: មតិចាប់អារម្មណ៍ពីតំណាងភាគីពាក់ព័ន្ធ

បន្ទាប់មកតំណាងសិក្ខាកាមមកពីស្ថាប័នពាក់ព័ន្ធនានាបានឡើងធ្វើការចាប់អារម្មណ៍លើកម្មវិធីព្រៃឈើជាតិដែលបានរៀបចំឡើងដោយរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ។ សេចក្តីចាប់អារម្មណ៍មានៈ

-ព្រះតេជគុណ **ញ៉ែម គីមតេង** នាយកអង្គការសន្តិសេនា ខេត្តស្វាយរៀង បានចាប់អារម្មណ៍ថា សិក្ខាសាលានេះពិតជាមានសារសំខាន់បំផុត ព្រោះបានអញ្ជើញអ្នកពាក់ព័ន្ធគ្រប់សមាសភាពមកពីគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់គ្នាស្វែងរកគន្លឹះក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ សិក្ខាសាលានេះបានធ្វើឱ្យយើងមានឱកាសបានផ្លាស់ប្តូរមតិ យោបល់ និងបានទទួលនូវព័ត៌មានល្អៗពីគ្នាទៅវិញទៅមក។ ព្រះករុណាអាត្មាភាព សូមធ្វើសំណូមពរយ៉ាងទទូចដល់ក្រុមការងារបច្ចេកទេសមេត្តាពិចារណា និង ដាក់បញ្ចូលនូវការផ្តល់លទ្ធភាពតាមផ្លូវច្បាប់ដល់ព្រះសង្ឃ និងវត្តអារាមក្នុងការចូលរួមលើផែនការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ។

-ឯកឧត្តម **ហោ សុភាព** រដ្ឋលេខាធិការក្រសួងព័ត៌មាន បានចាប់អារម្មណ៍ថាក្រសួងព័ត៌មានសូមគាំទ្រ និង អបអរសាទរចំពោះកម្មវិធីព្រៃឈើជាតិដែលកំពុងរៀបចំនេះ និងសូមឱ្យសារព័ត៌មានជាតិ និងអន្តរជាតិចូលរួមចំណែកគាំទ្រកម្មវិធីព្រៃឈើជាតិដើម្បីឱ្យភពផែនដីមានសុខភាពល្អ ហើយជឿជាក់ថានឹងមានគម្របព្រៃ៦០% ហើយការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

-លោក **ខោល យុទ្ធលី** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ បានសំដែងការកោតសរសើរយ៉ាងខ្លាំងចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសក្រុមការងារបច្ចេកទេសវិស័យព្រៃឈើ និងបរិស្ថាន ដែលបានលើកយកបញ្ហាព្រៃឈើនេះមកដាក់ជារបៀបវារៈសម្រាប់ធ្វើការជជែកក្នុងគោលបំណងរកដំណោះស្រាយរួមមួយដើម្បីទប់ស្កាត់រាល់បទល្មើសព្រៃឈើដែលកើតមានឡើងកន្លងមក។ តែខ្ញុំបានពិនិត្យឃើញថា ឯកសារស្តីពីកម្មវិធីព្រៃឈើជាតិនេះមិនទាន់បានសរសេរបញ្ជាក់ឱ្យបានច្បាស់អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធឡើយ ពិសេសអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានបញ្ជាក់ពីតួនាទីរបស់អាជ្ញាធរមូលដ្ឋានក្នុងការជម្រុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិប្រកបដោយចិរភាពសម្រាប់បំពេញសេចក្តីត្រូវការរបស់មូលដ្ឋាន។ នេះបញ្ជាក់ថា ច្បាប់បានតម្រូវឱ្យអាជ្ញាធរមូលដ្ឋានចូលរួមចំណែកក្នុងការទប់ស្កាត់ និងថែរក្សាធនធានធម្មជាតិ សម្បត្តិវប្បធម៌ជាតិឱ្យរក្សាបានភាពគង់វង្ស។

-លោក **លិ វុឌ្ឍី** តំណាងដៃគូអភិវឌ្ឍន៍នានាបានចាប់អារម្មណ៍ថា ពង្រាងកម្មវិធីព្រៃឈើជាតិនេះផ្តល់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍន៍វិស័យនានាដែលមានចំណងទាក់ទងជាមួយនឹងព្រៃឈើនាអំឡុងពេល

ឆ្នាំ ២០១០ ដល់ ២០៣០។ ក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិបង្ហាញទិសដៅលើគោលដៅសំខាន់៧សំរាប់ការអនុវត្តន៍កិច្ចការព្រៃឈើដូចជា ការកំណត់ព្រំព្រៃឈើ និងការចាត់ថ្នាក់ព្រៃឈើ ការគ្រប់គ្រងព្រៃឈើជាតិ និងការអភិរក្សកិច្ចការសហគមន៍ព្រៃឈើ ការអនុវត្តន៍ច្បាប់ព្រៃឈើ និងអភិបាលកិច្ច ការកសាងសមត្ថភាព និងការស្រាវជ្រាវហើយនិងនិរន្តរភាពនៃហិរញ្ញប្បទានព្រៃឈើ។ ពង្រាងកម្មវិធីព្រៃឈើជាតិនេះផ្តល់នូវការអនុវត្តន៍មួយដ៏មានតម្លាភាពតាមរយៈការចូលរួមពីបណ្តាវិស័យដទៃៗទៀតជាច្រើន និង ដាក់ឱ្យអនុវត្តជាអាទិភាពលើការបញ្ចៀស និងដោះស្រាយទំនាស់ ប្រព័ន្ធការត្រួតពិនិត្យ និងការវាយតម្លៃ។

-លោក **ស្រេង អូន** អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបន្ទាយមានជ័យតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចាប់អារម្មណ៍ថា ក្នុងនាមក្រសួងលោកយល់ឃើញថាការរៀបចំកម្មវិធីព្រៃឈើជាតិនេះជាការងារល្អណាស់ ហើយនៅពេលដែលរដ្ឋបាលព្រៃឈើបានបោះបង្គោលព្រំរួចហើយ នឹងបានកាត់បន្ថយបញ្ហាទំនាស់ក្នុងការរំលោភកាន់កាប់គ្រប់បែបយ៉ាង ហើយងាយស្រួលក្នុងការចុះបញ្ជីដីធ្លី។

-លោក **ថន គឹមហុង** អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានការពារអភិរក្សធនធានធម្មជាតិនៃក្រសួងបរិស្ថាន បានចាប់អារម្មណ៍ថាការរៀបចំកម្មវិធីព្រៃឈើជាតិមានលក្ខណៈល្អប្រសើរដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ហើយមានសារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ក្នុងប្រទេសកម្ពុជាមានស្ថាប័នពីរ គឺរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម និង អគ្គនាយកដ្ឋានការពារអភិរក្សធនធានធម្មជាតិនៃក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃឈើ ដូចនេះត្រូវសហការគ្នាទើបការគ្រប់គ្រងទទួលបានជោគជ័យ។

-លោក **ស៊ឹម ស៊ីសុខាលី** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចាប់អារម្មណ៍ថា ក្រសួងរបស់លោកនឹងបន្តការចូលរួមក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដោយធ្វើការសិក្សាវាយតម្លៃផលប៉ះពាល់ពីការសាងសង់ទំនប់វារីអគ្គិសនី និងការជីកយករ៉ែជាដើម។

-លោក **នេត មុនី** ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់អារម្មណ៍ថាកន្លងមកក្រសួងរបស់លោកមានការសហការល្អ និងមានក្រុមការងារចូលរួមក្នុងការរៀបចំកម្មវិធីព្រៃឈើជាតិនេះហើយនឹងត្រៀមសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសលើការប្រមូលចំណូលពីវិស័យព្រៃឈើ។

-លោក **ឡុង សុខា** ប្រធាននាយកដ្ឋានកសិកម្មនៃទីស្តីការនាយករដ្ឋមន្ត្រី បានចាប់អារម្មណ៍ថាលោកសូមកោតសរសើររដ្ឋបាលព្រៃឈើ និងក្រុមការងារដែលបានខិតខំរៀបចំកម្មវិធីព្រៃឈើជាតិនេះ ហើយវានឹងជាឧបករណ៍តម្រង់ទិសក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ លោកសូមគាំទ្រកម្មវិធីព្រៃឈើជាតិនេះនៅពេលដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី។

-លោក **ប៊ុល ពិសិដ្ឋ** តំណាងអង្គការ Concern worldwide បានសំដែងការគាំទ្រយ៉ាងពេញទំហឹងចំពោះកម្មវិធីព្រៃឈើជាតិ ហើយបញ្ជាក់ថាអង្គការរបស់លោកនឹងចូលរួមចំណែកឱ្យបានច្រើនក្នុងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិ ដើម្បីថែរក្សាធនធានព្រៃឈើឱ្យនៅគង់វង្ស ។

-លោក **សែ សុភី** តំណាង NGOs Forum សូមអបអរសាទរ និង កោតសរសើរចំពោះគំនិតផ្តួចផ្តើម និងការខិតខំប្រឹងប្រែងក្នុងការរៀបចំធ្វើសេចក្តីព្រាងនេះឡើង ។ ប៉ុន្តែលោកបានយល់ថាការផ្តល់ដីសម្បទាន ពិតជាបានរួមចំណែកដ៏ធំក្នុងការបំផ្លិចបំផ្លាញព្រៃឈើ ហើយពុំទាន់មានសូចនាករច្បាស់លាស់ណាបានបង្ហាញថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចបានកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ផ្ទុយទៅវិញគេឃើញផ្ទៃដីព្រៃធម្មជាតិបានប្រែក្លាយទៅជាការដ្ឋានកាប់ឈើ ជាចំការឈើដាំ និងការទុកដីអោយនៅទំនេរ និងបានធ្វើអោយមានផលប៉ះពាល់សង្គម បរិស្ថាន សេដ្ឋកិច្ច និង វប្បធម៌ ជាពិសេសជនក្រីក្រ និងជនជាតិដើមភាគតិចនៅតាមមូលដ្ឋាន ។ លោកបានផ្តល់អនុសាសន៍មួយចំនួនដូចជា :

- ធ្វើការត្រួតពិនិត្យមើលភាពស្របច្បាប់នានាពាក់ព័ន្ធដីសម្បទានសេដ្ឋកិច្ច ធ្វើការដកហូត និង បញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចបន្ថែមទៀត និងចូលរួមថែរក្សាព្រៃរិចរិលអោយដុះឡើងវិញ ។ ធ្វើការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថាន និង សង្គមដោយមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ហើយធានាថាព័ត៌មានត្រូវបានបើកចំហរចំពោះផ្ទៃដីសម្បទានសេដ្ឋកិច្ច ។
- ធ្វើការប្រកាសជាចំហរនូវតំបន់សក្តានុពលសំរាប់រៀបចំសហគមន៍ព្រៃឈើ និង ព្រៃសហគមន៍ ដែលធានាដល់ការផ្ទេរអំណាចក្នុងការគ្រប់គ្រងដោយសហគមន៍មូលដ្ឋានផ្ទាល់ ។ ធ្វើការជំរុញដល់មន្ត្រីរដ្ឋបាលព្រៃឈើក្នុងការរៀបចំសហគមន៍ព្រៃឈើ និងព្រៃសហគមន៍ដែលបាន និងកំពុងមានដំណើរការ ។
- ប្រែក្លាយខ្លឹមសារនៅក្នុងកម្មវិធីព្រៃឈើជាតិកម្ពុជា និង លទ្ធផលពិគ្រោះយោបល់ដែលបានឯកភាព ជាពិសេសសំណើនានាដែលលើកឡើងដោយសហគមន៍មូលដ្ឋាន ទៅជាការអនុវត្តន៍ជាក់ស្តែង ដើម្បីលើកទឹកចិត្តដល់ការចូលរួមប្រកបដោយនិរន្តរភាព ។

-លោក **សេង សុខហេង** តំណាងសហគមន៍មូលដ្ឋានខេត្តបន្ទាយមានជ័យ និងលោក **ជា ជួង** តំណាងសហគមន៍មកពីខេត្តឧត្តរមានជ័យ បានចាប់អារម្មណ៍ថាលោកសូមថ្លែងអំណរគុណចំពោះការអញ្ជើញឱ្យមកចូលរួមសិក្ខាសាលាលើកនេះ ហើយលោកសង្ឃឹមថានឹងដាក់បញ្ចូលនូវតម្រូវការរបស់សហគមន៍ក្នុងកម្មវិធីព្រៃឈើជាតិ ។ លោកបានស្នើឱ្យកម្មវិធីព្រៃឈើជាតិនេះជួយបញ្ជូនព័ត៌មានពីការលក់កាបូនព្រៃឈើដល់សហគមន៍មូលដ្ឋាន និងសូមឱ្យមានការពង្រឹងការអនុវត្តន៍ច្បាប់លើបទល្មើសព្រៃឈើដែលកើតមានឡើង ហើយចំពោះដីសម្បទានដែលបានផ្តល់រួចហើយក្រុមហ៊ុនបានរំលោភកិច្ចសន្យា ត្រូវដកហូតយកមកវិញ ។ មតិចាប់អារម្មណ៍របស់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធមានភ្ជាប់នៅឧបសម្ព័ន្ធ ១២ ។

### ៣.៦:ពិធីបិទអង្គសិក្ខាសាលា

លោក **ហ៊ុន-អៀង** នាយខ័ណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាមបានឡើងធ្វើសេចក្ដីរាយការណ៍សង្ខេបពីលទ្ធផលសិក្ខាសាលាដែលទទួលបានក្នុងថ្ងៃនេះ ដោយបានលើកឡើងថា ការចូលរួមរបស់ ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ជាវិភាគទានដ៏មានតំលៃ ក្នុងការកសាងនូវកម្មវិធីព្រៃឈើជាតិរបស់យើង មានលក្ខណៈជាតិស្របទៅតាមតំរូវការក្នុងមូលដ្ឋាន មានតម្លាភាព និងមានសុខដុមនីយកម្មទៅនឹងច្បាប់ស្ដីពីព្រៃឈើគោលនយោបាយយុទ្ធសាស្ត្រចតុកោណជំហានទី ២ របស់រាជរដ្ឋាភិបាល និង គោលដៅអភិវឌ្ឍសហសវត្សន៍កម្ពុជាដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើរបស់យើងប្រកបដោយនិរន្តភាព សំរាប់កូនចៅជំនាន់ក្រោយ។ ជាមួយគ្នានេះដែរ លោកក៏បានសំដែងនូវការអរគុណ ចំពោះវត្តមានដ៏មានតម្លៃរបស់សិក្ខាកាមទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសាលាក្នុងរយៈពេលពីរថ្ងៃនេះ។ របាយការណ៍បូកសរុបលទ្ធផលសិក្ខាសាលារបស់លោក ហ៊ុន-អៀង នាយខណ្ឌរដ្ឋបាលព្រៃឈើ កំពង់ចាមមានភ្ជាប់នៅឧបសម្ព័ន្ធ ១៣។

ជាកិច្ចបញ្ចប់ ឯកឧត្តម **ជា សំអាង** បានថ្លែងបិទសិក្ខាសាលា ដោយបានគូសបញ្ជាក់ថា និន្នាការនៅលើពិភពលោកសព្វថ្ងៃផ្ដោតលើបញ្ហាសុខសន្តិភាពនៃការរស់នៅ ភាពប្រឈមនៃបញ្ហាសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ និងកិច្ចខិតខំប្រឹងប្រែងដើម្បីបន្ថយការឡើងកំដៅផែនដី។ ចំពោះកម្ពុជា យើងកំពុងរៀបចំខ្លួនដើម្បីទទួលការអភិវឌ្ឍន៍ ដែលក្នុងនោះមានការអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ កំណែទម្រង់នៅថ្នាក់មូលដ្ឋាន និងការអភិរក្សធនធានធម្មជាតិ។ ការរៀបចំកម្មវិធីព្រៃឈើជាតិ ជាតម្រូវការជាប្រវត្តិសាស្ត្រ ដែលពីមុនមិនធ្លាប់បានធ្វើ ហើយឯកសារនេះមានលក្ខណៈជាអន្តរជាតិ ហើយក្រុមការងាររៀបចំមានតំណាងមកពីគ្រប់ស្ថាប័នពាក់ព័ន្ធ។ ជាមួយគ្នានេះដែរ ឯកឧត្តមក៏បានផ្ដល់អនុសាសន៍សម្រាប់ការពិចារណារួមមានៈ ការចូលរួមថែរក្សា ធនធានធម្មជាតិដែលមានស្រាប់ ការបង្កើនព្រៃដាំដើម្បីធានានូវការប្រើប្រាស់ និងការប្រើប្រាស់ធនធានព្រៃឈើដោយសន្សំសំចៃ។

## ៤.សន្និដ្ឋាន

ដោយផ្អែកលើលទ្ធផលរំពឹងទុកមុនអង្គសិក្ខាសាលាចាប់ផ្ដើមរួមមានៈ ការយល់ដឹងបន្ថែមពីកម្មវិធីព្រៃឈើជាតិ ទទួលបានការរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន និង បង្កើនការគាំទ្រការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ និង ការអនុវត្តន៍កម្មវិធីព្រៃឈើជាតិនាពេលខាងមុខ ដូចនេះយើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថា អង្គសិក្ខាសាលាបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ដោយគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួម ក្នុងសិក្ខាសាលាទទួលបានការយល់ដឹងបន្ថែមមួយកម្រិតទៀតពីកម្មវិធីព្រៃឈើជាតិ ហើយក្នុងនោះសិក្ខាកាមបានចូលរួមផ្ដល់មតិ

រិះគន់ស្ដាបនាតាមរយៈវេទិកាសំនួរ-ចម្លើយ ក្រុមពិភាក្សា និងមតិចាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធ។ ជាពិសេសជាងនេះទៀត តំណាងភាគច្រើននៃអ្នកចូលរួមបានធ្វើការប្ដេជ្ញាចិត្តដើម្បីសហការ និងគាំទ្រកម្មវិធីព្រៃឈើជាតិនេះ។ ដោយឡែកក៏មានតំណាងមកពីវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា និងតំណាងសហគមន៍មូលដ្ឋានបានធ្វើសំណូមពរទាក់ទង បញ្ឈប់ការផ្ដល់ដីសម្បទាន ជុំរុញការបង្កើតសហគមន៍ព្រៃឈើ ជុំរុញការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាពចំពោះ ការបាត់បង់ធនធានព្រៃឈើនាពេលបច្ចុប្បន្នការគាំទ្រពីអ្នកពាក់ព័ន្ធលើបញ្ហាកើតមានឡើងក្នុងវិស័យព្រៃឈើនិងដើម្បីអនាគត។

**<u>ឧបសម្ព័ន្ធ ២</u>៖** របៀបវារៈកម្មវិធីសិក្ខាសាលាកិច្ចពិគ្រោះយោបល់ជាសាធារណៈនៅខេត្តកំពង់ចាម

## សិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ
## សណ្ឋាគារ ភ្នំប្រុស ខេត្ត កំពង់ចាម ថ្ងៃទី ៤-៥ ខែមិថុនា ឆ្នាំ២០០៩

| កាលបរិច្ឆេទ | ពេលវេលា | កម្មវត្ថុ | វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| 4 **មិថុនា** | 08:00 – 08:30 | ចុះឈ្មោះ | | អ្នកជំនួយការ |
| | Plenary session<br>08:30 – 09:30 | - សុន្ទរកថាស្វាគមន៍ និងបើក<br>- សេចក្តីថ្លែងការ<br>- សេចក្តីថ្លែងការ<br>- សេចក្តីថ្លែងការ | មតិ | - ឯ.ឧ. អភិបាលខេត្តកំពង់ចាម<br>-លោក ជួប ប៉ារីស (FAO)<br>- ៖ លោក Michael Scott (Danida)<br>- ឯ.ឧ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា |
| | 09:30 – 10:00 | អាហារសំរន់ | | |
| | 10:00 – 10:20 | អំពីអង្គសិក្ខាសាលា<br>- គោលបំណង និងលទ្ធផលរំពឹងទុក<br>- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ | បទបង្ហាញ | បណ្ឌិត សុខ ហេង |
| | 10:20 – 10:40 | បទបង្ហាញអំពី<br>ឯកសារក្របខណ្ឌយុទ្ធសាស្ត្រ | បទបង្ហាញ | លោក ឡុង ប៊ុង និង លោក Arvid Sloth |
| | 10:40 – 11:10 | បទបង្ហាញអំពី កម្មវិធីទី១ ដល់ ទី ៥ | បទបង្ហាញ | លោក ហុង គីមហ៊ាន |
| | 11:10 – 11:30 | បទបង្ហាញអំពី<br>កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ | បទបង្ហាញ | ឯ.ឧ. ថន សារ៉ាត់ |
| | 11:30 – 12:00 | សំនួរ និងចំលើយ | | ឯ.ឧ. ជា សំអាង បណ្ឌិត សុខ ហេង<br>លោក Arvid Sloth និង<br>អ្នកចងក្រង |
| | 12:00 – 13:30 | អាហារថ្ងៃត្រង់ | | |
| | 13:30 – 15:00 | ពិភាក្សាតាមក្រុម<br>លើឯកសារក្របខណ្ឌយុទ្ធសាស្ត្រ និង<br>កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ | ប្រមូលមតិ | ឯកសារក្របខណ្ឌ៖ លោក ឡុង ប៊ុង<br>កម្មវិធីវិនិយោគ៖ លោក ហាក់ សារុំ |
| | 15:00 – 15:30 | អាហារសំរន់ | | |
| | 15:30 – 17:00 | ពិភាក្សាតាមក្រុម<br>លើឯកសារក្របខណ្ឌយុទ្ធសាស្ត្រ និង<br>កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ | ប្រមូលមតិ | ឯកសារក្របខណ្ឌ៖ លោក ឡុង ប៊ុង<br>កម្មវិធីវិនិយោគ៖ លោក ហាក់ សារុំ |

| | | | | |
|---|---|---|---|---|
| 5 **មិថុនា** | 08:00 – 10:00 | បទបង្ហាញ លទ្ធផលពីក្រុមពិភាក្សា | បទបង្ហាញ | តំណាងក្រុមពិភាក្សា |
| | 1:00 – 10:30 | អាហារសំរន់ | | |
| | 10:30 – 12:00 | សេចក្តីថ្លែងការៈ ក្រសួងមន្ទីរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អ្នកសារព័តិមាន និង ព្រះសង្ឃ | មតិ | មិនទាន់បានកំណត់ឈ្មោះ |
| | 12:00 – 13:30 | អាហារថ្ងៃត្រង់ | | |
| | 13:30 – 15:30 | សេចក្តីថ្លែងការៈ<br>សហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល<br>វិស័យឯកជន និង ដៃគូអភិវឌ្ឍន៍ | មតិ | មិនទាន់បានកំណត់ឈ្មោះ |
| | 15:30 – 16:00 | អាហារសំរន់ | | |
| | 16:00 – 17:30 | - -របាយការណ៏បូកសរុប<br>- មតិចាប់អារម្មណ៏របស់អ្នកចូលរួម<br>- សុន្ទរកថាបិទអង្គសិក្ខាសាលា | មតិ | - លោក ហ៊ុន អៀង នាយខ័ណ្ឌ រព.កច<br>-<br>មិនទាន់បានកំណត់ឈ្មោះ<br>- ឯ.ឧ. ជា សំអាង អនុប្រធានរ.ព |

**<u>ឧបសម្ព័ន្ធ ៣៖</u>** បទបង្ហាញអំពីសិក្ខាសាលា

សិក្ខាសាលាស្តីពី
ការពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ

# អំពីសិក្ខាសាលា

សុខ ហេង

## មាតិកាបទបង្ហាញ

- ប្រវត្តិ
- គោលបំណង
- លទ្ធផលរំពឹងទុក
- ដំណើរការអង្គសិក្ខាសាលា

# ប្រវត្តិ

- ក្រុមការងារកម្មវិធីព្រៃឈើជាតិត្រូវបានបង្កើត នៅ ឆ្នាំ ២០០៧
- ការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិត្រូវបានកំណត់ ជាស្ថាបនករក្នុងតារាងសូចនករតាមជាន់រួម
- កម្មវិធីការងារជាអាទិភាពចំនួនប្រាំមួយត្រូវបានអភិវឌ្ឍសំរាប់អនុវត្តក្នុងរយៈពេល ២០ ឆ្នាំខាងមុខ
- ការពិគ្រោះយោបល់ត្រូវបានកំណត់ក្នុងវិថីគោចរ នៃការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ

# អ្នកចូលរួម

| ប្រភេទអ្នកចូលរួម | ចំនួន | សំគាល់ |
|---|---|---|
| មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន | ១២ | សង្កាត់រដ្ឋបាលព្រៃឈើ, ផ្នែក និង ខ័ណ្ឌ, អធិការដ្ឋាន |
| អាជ្ញាធរមូលដ្ឋាន | ១២ | ឃុំ, ស្រុក, ខេត្ត |
| សហគមន៍មូលដ្ឋាន | ១៧ | សហគមន៍ព្រៃឈើ និង ព្រះសង្ឃ |
| អង្គការ, វិស័យឯកជន, សារព័ត៌មាន | ៣៦ | អ្នកធ្វើការពាក់ព័ន្ធព្រៃឈើ និង បរិស្ថាន និងបណ្តាញផ្សព្វផ្សាយ |
| ក្រសួងមន្ទីរពាក់ព័ន្ធ | ៦៩ | ទីស្តីការគណៈរដ្ឋមន្ត្រី សុរិយោដី, បរិស្ថាន, ឧស្សាហកម្ម, អភិវឌ្ឍជនបទ,កសិកម្ម, អប់រំ, ព័ត៌មាន, សេដ្ឋកិច្ច និងហិរញ្ញវត្ថុ,ពាណិជ្ជកម្ម, ធម្មការនិងសាសនា ។ល។ |
| អ្នកផ្សេងទៀត | ២០ | ក្រុមពិគ្រោះយោបល់ និង អ្នកជំនួយការសិក្ខាសាលា |
| សរុប | ១៨១ | |

# គោលបំណង

*ដើម្បីទទួលកែលំអឯកសារពង្រាងកម្មវិធីព្រៃឈើជាតិឱ្យកាន់តែប្រសើរ*

- បង្កើនការផ្សព្វផ្សាយ  និងការយល់ដឹងអំពីកម្មវិធីព្រៃឈើជាតិ
- ប្រមូលមតិ, ឧស្សុនៈ  និង  យោបល់ពីអ្នកពាក់ព័ន្ធនានា
- បង្កើនការគាំទ្រ  និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍ និងការអនុវត្តកម្មវិធីព្រៃឈើជាតិ

# វិធាននៃការពិភាក្សាពិគ្រោះយោបល់

- សំនួរ  និង  ការពិភាក្សាត្រូវ  ផ្តោតលើខ្លឹមសារសំខាន់ៗ ក្នុងឯកសារសេចក្តីព្រាង
- សិក្ខាកាមគ្រប់រូប  មានសិទ្ធិស្មើគ្នា  និង  ត្រូវគោរពសិទ្ធិគ្នា
- ជៀសវាង  ការវាយប្រហារពាក្យសំដី  និង  ការចោទប្រកាន់
- ការផ្តល់មតិត្រូវមានលក្ខណៈរិះគន់ស្ថាបនា

# កំណត់ចំណាំ

- នេះមិនមែនជាវេទិកាសួរដេញដោលបញ្ហានានាក្នុងវិស័យព្រៃឈើទេ
- ត្រូវការមតិ ឬ ទស្សនៈរបស់ជាងមតិផ្ទាល់ខ្លួន
- មតិទាំងអស់នឹងត្រូវទទួលយកទៅពិចារណា និង សំយោគ
- មិនតំរូវអោយមានការឯកភាព រឺ បដិសេដលើសេចក្តីព្រាងទេ

**<u>ឧបសម្ព័ន្ធ ៤</u>:** ដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិនៅកម្ពុជា

**សិក្ខាសាលាស្តីពី**

**ការពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ**

**កំពង់ចាម ៤-៥ មិថុនា ២០០៩**

# ដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ

**សុខ ហេង**

## មាតិកាបទបង្ហាញ

- និយមន័យ គោលបំណង គោលការណ៍សកល
- ប្រវត្តិដើមរឿងនៃដំណើរការចងក្រង និងលទ្ធផល
- ទិសដៅបន្ត

## និយមន័យ និងគោលបំណង នៃកម្មវិធីព្រៃឈើជាតិ

- **និយមន័យ:**

កម្មវិធីព្រៃឈើជាតិ គឺជាដំណើរការដែលមានការចូលរួមពីដៃគូជាច្រើននៅក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យលើសកម្មភាពក្នុងវិស័យព្រៃឈើក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដោយចីរភាព។

- **គោលបំណង:**

ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និង ប្រើប្រាស់ ព្រៃឈើដោយសមធម៌តាមរយៈក្របខ័ណ្ឌកម្មវិធីជាតិរយៈពេលវែងមួយ

## គោលការណ៍កម្មវិធីព្រៃឈើជាតិ

គោលការណ៍

- ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
- អធិបតេយ្យភាពជាតិ និងភាពជាម្ចាស់
- ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- មានលក្ខណៈស៊ីសង្វាក់ និងតភ្ជាប់ជាមួយវិស័យផ្សេងៗ
- ជាដំណើរការមានរយៈពេលវែង និងមានការកែសំរួលជាប្រចាំ
- មានភាពស៊ីសង្វាក់ជាមួយនឹងគោលនយោបាយជាតិ និងអន្តរជាតិ
- មានការលើកកំពស់ការយល់ដឹង និង ផ្សព្វផ្សាយជាសាធារណៈ

## ដំណាក់កាល




## រចនាសម្ព័ន្ធក្រុមការងារកម្មវិធីព្រៃឈើជាតិ



## ដំណើរការនៃការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ




## សមាសភាព ក្រុមការងារកម្មវិធីព្រៃឈើជាតិ

- រដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ នៃ កសក
- ដៃគូអភិវឌ្ឍៈ Danida, Jica, UNDP, FAO , WB …
- ស្ថាប័នរដ្ឋៈ ក្រសួងដែនដី បរិស្ថាន មហាផ្ទៃ ឧស្សាហកម្ម សេដ្ឋកិច្ច
- អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល
- វិស័យឯកជន

## កម្មវិធី៦ ដែលបានរៀបចំជាពង្រាងៈ

១. កម្មវិធីកំនត់ព្រំប្រទល់ ចាត់ថ្នាក់ ការចុះបញ្ជីកាសម្បត្តិព្រៃឈើ

២. កម្មវិធីការគ្រប់គ្រងធនធានព្រៃឈើ និងអភិរក្ស

៣. កម្មវិធីការពង្រឹងច្បាប់ និងអភិបាលកិច្ច

៤. កម្មវិធីសហគមន៍ព្រៃឈើ

៥. កម្មវិធីកសាងសមត្ថភាព និងអភិវឌ្ឍន៍ការស្រាវជ្រាវ

៦. កម្មវិធីហិរញ្ញវត្ថុព្រៃឈើប្រកបដោយនិរន្តរភាព

## ការពិគ្រោះយោបល់លើឯកសារកម្មវិធីព្រៃឈើជាតិកន្លងមក

| អធិការដ្ឋាន | ខេត្ត | កាលបរិច្ឆេទ |
|---|---|---|
| ឈូងសមុទ្រ | ព្រះសីហនុ | ១៦-១៧ |
| ខាងត្បូងបឹងទន្លេសាប | ពោធិសាត់ | ១៩-២០ |
| មេគង្គ | ក្រចេះ | ២៥-២៦ |
| ខាងជើងបឹងទន្លេសាប | សៀមរាប | ៣០-៣១ |

## ផែនការបន្ទះ

- កែលំអសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ
- ពិនិត្យវាយតំលៃ និង កែលំអដោយអ្នកជំនាញការអន្តរជាតិ
- ពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ
- ការកែលំអចុងក្រោយ
- ក្រុមការងារកម្មវិធីព្រៃឈើជាតិ ពិនិត្យអនុម័ត
- រាជរដ្ឋាភិបាលពិនិត្យ និង អនុម័ត

http://www.twgfe.org/nfp/

## សូមអរគុណ

# ៤. កម្មវិធី ពង្រឹងការអនុវត្តន៍ច្បាប់ស្តី និង អភិបាលកិច្ច

## ៤.១: អនុកម្មវិធី កំណែទំរង់ច្បាប់ និងរដ្ឋបាល

- បង្កើតក្រុមការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត
- បង្កើតក្រុមការងារស៊ើបអង្កេត និងអធិការកិច្ចបទល្មើសព្រៃឈើ
- បង្កើតគណៈកម្មការពិនិត្យវាយតំលៃមន្ត្រីរដ្ឋបាលព្រៃឈើ
- ធ្វើឱ្យប្រសើរនូវរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើដែលមានស្រាប់
- បង្កើនសមត្ថភាពរដ្ឋបាលព្រៃឈើដើម្បីគ្រប់គ្រង និងដោះស្រាយទំនាស់ធនធានព្រៃឈើ
- ធ្វើឱ្យប្រសើរនូវការងារទំនាក់ទំនងរបស់រដ្ឋបាលព្រៃឈើ
- អភិបាលកិច្ចព្រៃឈើល្អ

## ៤.២: អនុកម្មវិធី ពង្រឹងការអនុវត្តច្បាប់ និង ការតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ

- ផ្តល់មធ្យោបាយ សំភារៈ និង បរិក្ខាឱ្យបានគ្រប់គ្រាន់ដល់មន្ត្រីពង្រឹងការអនុវត្តច្បាប់នៃរដ្ឋបាលព្រៃឈើ
- ធ្វើឱ្យប្រសើរនូវយន្តការតាមដាន និងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ
- សហការជិតស្និទជាមួយស្ថាប័នតុលាការដើម្បីឱ្យដំណើរការវិនិច្ឆ័យសេចក្តីសំណុំរឿងបទល្មើសព្រៃឈើឱ្យបានឆាប់
- ធ្វើឱ្យប្រសើរកិច្ចសហប្រតិបត្តិការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើឆ្លងកាត់ព្រំដែន
- សហការឱ្យមានប្រសិទ្ធភាពជាមួយអង្គភាពពង្រឹងការអនុវត្តច្បាប់ផ្សេងៗ
- ធ្វើឱ្យប្រសើរនូវយន្តការអនុគណៈកម្មាធិការខេត្ត ដើម្បីទប់ស្កាត់ និងបង្ក្រាបសកម្មភាពកាប់រាន និង ហ៊ុំព័ទ្ធយកដីព្រៃឈើខុសច្បាប់

### ៤.៣: អនុកម្មវិធី ការឆ្លើយតបរហ័សចំពោះពត៌មានបទល្មើសព្រៃឈើ

- បង្កើតក្រុមការងារឆ្លើយតបរហ័សចំពោះពតិមានបទល្មើសព្រៃឈើនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល
- បង្កើតក្រុមការងារឆ្លើយតបរហ័សចំពោះពតិមានបទល្មើសព្រៃឈើនៅរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋាន
- សហការឱ្យមានប្រសិទ្ធភាពជាមួយអ្នកសារពតិមាន និង អ្នកផ្តល់ពតិមាន

## ៥. កម្មវិធីសហគមន៍ព្រៃឈើ

### ៥.១: អនុកម្មវិធី : ការកំណត់តំបន់សក្តានុពល និង បង្កើតសហគមន៍ព្រៃឈើ

- សិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ័ទាំងអស់ ដើម្បីកំណត់តំបន់សក្តានុពលព្រៃសហគមន៍ ទាំង៤ទំរង់ (សហគមន៍ព្រៃឈើ សហគមន៍ព្រៃផ្តល់ផល សហគមន៍ព្រៃការពារ និងព្រៃឈើដៃគូ)

-ផ្សព្វផ្សាយ និង រៀបចំបង្កើតសហគមន៍ទាំង៤ទំរង់ ស្របតាមនីតិវិធី

-រៀបចំផែនការអភិវឌ្ឍ ព្រៃសហគមន៍

-អនុវត្ត និង តាមដានត្រួតពិនិត្យវាយតំលៃ សកម្មភាព ការងារ ។

## ៥.២: អនុកម្មវិធី : ការអភិវឌ្ឍន៍សហគមន៍ និង ការបង្កើនជីវភាព

-កំណត់សក្តានុពលសំរាប់អភិវឌ្ឍសហគ្រាសសហគមន៍ព្រៃឈើ

-ពង្រឹងសមត្ថភាពស្ថាបន័ ដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាព និង ប្រសិទ្ធិភាព

-ពង្រឹងសមត្ថភាព និងការយល់ដឹងដល់សហកមន៍មូលដ្ឋានតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ទស្សនកិច្ចសិក្សា និង ចងក្រងបណ្តាញការងារ ។

-ស្វែងរកថវិកាសំរាប់ការរៀបចំសហគ្រាសសហគមន៍ព្រៃឈើ និងដំណើរការអនុវត្តន

## ៥.៣: អនុកម្មវិធី : ការគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

-ផ្តល់ចំណេះដឹងស្តីពីលិខិតបទដ្ឋានច្បាប់ បច្ចេកទេស ដំណើរការបង្កើត និង គ្រប់គ្រងសហគមន៍

-បង្កើនសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនៈកិច្ចសិក្សា និងបណ្តាញការងារ

-គ្រប់គ្រង និង ចែកចាយពតិមានស្តីពីសហគមន៍ព្រៃឈើ

-សំរបសំរួលដោះស្រាយទំនាស់ក្នុងការអនុវត្តន៍សហគមន៍ព្រៃឈើ

-ធ្វើការពិនិត្យឡើងវិញលើប្រសិទ្ធិភាពនៃការអនុវត្តលិខិតបទដ្ឋាននានា

-រៀបចំកំណត់ថ្លៃសួយសារ និង បុព្វលាភសំរាប់សហគមន៍ព្រៃឈើ

-ធ្វើការត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍កម្មវិធីសហគមន៍ព្រៃឈើ ។

# ៦. កម្មវិធីទី ៥. អភិវឌ្ឍសមត្ថភាព និងការស្រាវជ្រាវ

## ៦.១: អនុកម្មវិធី ការអភិវឌ្ឍន៍ធនធានមនុស្ស និងស្ថាប័ន

-បង្កើតយន្តការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យព្រៃឈើ

-ជ្រើសរើសមន្ត្រីថ្មី និងពង្រឹងសមត្ថភាពមន្ត្រីដែលមានស្រាប់នៃរដ្ឋបាលព្រៃឈើ

-អភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលឆ្លើយតបទៅនឹងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិ

## ៦.២: អនុកម្មវិធីផ្សព្វផ្សាយព្រៃឈើ និងបង្កើនការយល់ដឹងជាសាធារណៈ

-លើកកំពស់ការយល់ដឹងសម្រាប់ក្មេងជំនាន់ក្រោយ

-បង្កើនការផ្សព្វផ្សាយក្នុងការអនុវត្តកម្មវិធីព្រៃឈើជាតិ

-ការធ្វើប្រសើរឡើងនូវមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រៃឈើ

-យុទ្ធសាស្រ្តទំនាក់ទំនង

-ការវាយតម្លៃពីតម្រូវការសមត្ថភាព

-សេវាកម្មផ្សព្វផ្សាយព្រៃឈើ

-ការត្រួតពិនិត្យ និង វាយតម្លៃ

## ៦.៣: អនុកម្មវិធី ការអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ

-ត្រូវមានគណៈកម្មការតម្រង់ទិសមួយសម្រាប់ការស្រាវជ្រាវលើវិស័យព្រៃឈើ

-ពង្រឹងសមត្ថភាពស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍព្រៃឈើ-សត្វព្រៃ តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស និងបំពាក់ឧបករណ៍-សម្ភារៈស្រាវជ្រាវគ្រប់គ្រាន់

- បង្កើតបណ្តាញស្រាវជ្រាវទាំងក្នុងនិងក្រៅប្រទេស សម្រាប់អភិវឌ្ឍការស្រាវជ្រាវលើវិស័យព្រៃឈើ។

## ៦.៤: អនុកម្មវិធី វិញ្ញាបនបត្រព្រៃឈើ

-បង្កើតអង្គភាពវិញ្ញាបនប័ត្រព្រៃឈើមួយ

-បង្កើតក្រុមការងារសម្រាប់រៀបចំលក្ខណៈវិនិច្ឆ័យ និងសូចនាករក្នុងការចេញវិញ្ញាបនប័ត្រព្រៃឈើ

-ជ្រើសរើសប្រព័ន្ធវិញ្ញាបនប័ត្រព្រៃឈើដែលសមស្របទៅនឹងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្ន

-ធ្វើសមាហរណកម្មវិញ្ញាបនប័ត្រព្រៃឈើកម្ពុជា ជាមួយវិញ្ញាបនប័ត្រព្រៃឈើអន្តរជាតិ

**<u>ឧបសម្ព័ន្ធ ៧</u>:** បទបង្ហាញស្តីពីកម្មវិធីហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

# កម្មវិធីហិរញ្ញប្បទាន ដើម្បីគ្រប់គ្រងព្រៃឈើនិរន្តរភាព

## នៃកម្មវិធីព្រៃឈើជាតិ

**រដ្ឋបាលព្រៃឈើ**

**ការិយាល័យផែនការ និង គណនេយ្យ ហិរញ្ញវត្ថុ**

**រៀបចំដោយក្រុមការងារបច្ចេកទេស ធ្វើបទបង្ហាញដោយ ថន  សារ៉ាត**

**ក្រុងកំពង់ចាម ថ្ងៃទី ៤-៥ ខែ មិថុនា ឆ្នាំ ២០០៩**

## មាតិកា

**ក-ទស្សនវិស័យកម្មវិធីហិរញ្ញប្បទាន**

**ខ- កម្មវិធីហិរញ្ញប្បទាន:**

១.គោលបំណង :

២.យុទ្ធសាស្ត្រ :

៣.រយ:ពេល :

៤.ការរៀបចំផែនការគ្រប់គ្រង :

-ផែនការប្រើប្រាស់ដីព្រៃឈើ

-ផែនការតម្រូវការថវិការយ:ពេលខ្លី

-ផែនការគ្រប់គ្រងប្រភពហិរញ្ញប្បទាន

**គ-សនិដ្ឋាន:**

## ក-ទសន្សនវិស័យ កម្មវិធីហិរញ្ញប្បទាន ៖
## "ផ្តល់ផ្គង់ថវិការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព"

គម្រោងហិរញ្ញប្បទានដើម្បីគ្រប់គ្រងព្រៃឈើនិរន្តរភាពនេះ គឺជាផ្នែកទី៦ នៃកម្មវិធីព្រៃឈើជាតិ។ កម្មវិធីព្រៃឈើជាតិបាន និង កំពុងកំណែទម្រង់តាមកម្មវិធីជាតិដោយៈ

-បន្តអនុវត្តយុទសាស្រ្តចតុកោណជំហាន២ របស់រាជរដ្ឋាភិបាល

-បន្តផែនការ យុទសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០

-តម្រង់ទិសវិសយ័ព្រៃឈើសម្រេចបានតាមគោលដៅសហសវត្ស

-រៀបចំវិសយ័ព្រៃឈើបន្ថែមតាមនិយាមអន្តរជាតិ និង សម្រប សម្រួលការងារព្រៃឈើស្របតាមសភាពការណ៍ក្នុងតំបន់

## ខ- កម្មវិធីហិរញ្ញប្បទានៈ

### ១.គោលបំណងៈ

-ធានាសុវត្ថិភាពសិទ្ធិកាន់កាប់ និងសិទ្ធិអ្នកប្រើប្រាស់

-ធានាថាតម្លៃនៃធនធានព្រៃឈើត្រូវបានទទួលខុសត្រូវពេញលេញ

-បង្កើតប្រពន្ធ័ចរន្តហិរញ្ញប្បទាន និង កម្មវិធីវិនិយោគ

-រៀបចំវិភាគទានដែលបានពីការកកើតកាបោនធម្មជាតិ

-វិភាជធនធាន ជាប្រយោជន៍ដល់ជនក្រីក្រ និង ក្រុមងាយរងគ្រោះ

-ចាប់ផ្តើមគំនិតអភិវឌ្ឍន៍ ពីការពឹងអាស្រ័យលើជំនួយ មកពឹងលើខ្លួនឯង

## ២,យុទ្ធសាស្ត្រ: រៀបចំផែនការគ្រប់គ្រងផ្ទៃដីព្រៃឈើ ប្រមាណ ១០,៩ លាន ហត ស្មើ៦០ភាគរយនៃផ្ទៃដីប្រទេស ក្នុងនោះមាន:




## ៣. រយៈពេល : ២០ឆ្នាំ (២០១០-២០៣០)

| | រយៈពេលខ្លី (៤ឆ្នាំដំបូង) | រយៈពេលមធ្យម (ពង្រីកសកម្មភាព ៨ឆ្នាំបន្ទាប់) | រយៈពេលវែង (រួមបញ្ចូលសកម្មភាព ៨ឆ្នាំចុងក្រោយ) |
|---|---|---|---|
| **សកម្មភាព** | ហេដ្ឋារចនាសម្ព័ន<br>ខ្សែបន្ទាត់ព្រំប្រទល់<br>កម្មសិក្សានិងការអប់រំ<br>ការបង្កើនសមត្ថភាព | ហេដ្ឋារចនាសម្ព័នរួមបញ្ចូលគ្នា<br>បង្គោលមានសញ្ញា<br>ការអប់រំ<br>ការបង្កើនសមត្ថភាព | ការថែទាំហេដ្ឋារចនាសម្ព័ន<br>ការកត់ត្រានិងការវាយតម្លៃ<br>សេវាកម្មសិក្សានិង មេរៀន<br>ការផ្លាស់ប្តូរចំណេះដឹង |
| **ការផ្តត់ផ្គង់ហិរញ្ញវត្ថុ** | **ជំនួយការអភិវឌ្ឍន(ODA)**<br>**ការផ្តល់និងសប្បុរសធមិ**<br>**វិភាជន៍ថវិកាជាតិ** | **ODA 60 %**<br>**វិស័យឯកជន ២៥ %**<br>**វិភាជន៍ ១៥ %** | **ODA 40 %**<br>**វិស័យឯកជន ៣៥ %**<br>**វិភាជន៍ ២៥ %** |
| **លក្ខខណ្ឌ** | រចនាសម្ព័នដូចជា<br>នីតិកម្ម-ទីផ្សារ<br>ផែនទីធនធាន-ស្ថាប័ន | ការកែទម្រង់ដីធ្លី<br>ម្ចាស់ដី-ការកាន់កាប់ដី<br>អ្នកប្រើប្រាស់សិទ្ធិ...<br>ទីផ្សាររឹងមាំ-វប្បធមិស្អាតស្អំ (មិនពុករលួយ) និងមាន តម្លាភាព | វិភាជន៍ជាថ្មីឡើងវិញ<br>ដូចជាការលើកទឹកចិត្តម្ចាស់ដី<br>ការទំនុកបំរុង<br>កិច្ចការផ្សព្វផ្សាយសេវាកម្មព្រៃឈើ -ការស្រាវជ្រាវ<br>និង ការអភិវឌ្ឍន៍ |

## ៤.ការរៀបចំផែនការគ្រប់គ្រង:

## -ផែនការប្រើប្រាស់ដីព្រៃឈើ

-ការប្រើប្រាស់ដីព្រៃឈើ : គំរបព្រៃឈើ មាន៦០ភាគរយ: ប្រមាណ ១០,៩ លាន ហត នៃផ្ទៃដីសរុប

| តំបន់ការពារ<br>ប្រមាណ ៣លានហត | ព្រៃការពារ<br>ប្រមាណ ១.៥លានហត | សហគមន៍ព្រៃឈើ<br>ប្រមាណ២លានហត | ព្រៃសម្បទាន<br>ប្រមាណ៣.២លានហត | ព្រៃផ្តល់ផល<br>ប្រមាណ១.២លានហត |
|---|---|---|---|---|
| ដី ស ម្ប ទា ន សេ ដ្ឋ កិ ច្ច | | | | |
| (ប្រមាណ ២០០.០០០ហត) | (ប្រមាណ ១០០.០០០ហត) | (ប្រមាណ ២០០.០០០ហត) | (ប្រមាណ ៣០០.០០០ហត) | (ប្រមាណ ២០០.០០០ហត) |
| ដីព្រៃសល់<br>២,៨លាន ហត | ដីព្រៃសល់<br>១,៤លាន ហត | ដីព្រៃសល់<br>១,៨លាន ហត | ដីព្រៃសល់<br>២,៩លាន ហត | ដីព្រៃសល់<br>១លាន ហត |
| ប្លុក A | ប្លុក B | ប្លុក C | ប្លុក D | ប្លុក E |

## -ផែនការតម្រូវការថវិការយ:ពេលខ្លី

| ប្រភពចំណូល | ដុល្លារអាមេរិក | ចំណាយតាមអនុកម្មវិធី | ដុល្លារអាមេរិក |
|---|---|---|---|
| ហិរញ្ញប្បទានពីរាជរដ្ឋាភិបាល | ១ លាន | ១- កំណត់ព្រំប្រទល់: | ៥៣,៦ លាន |
| ព្រៃឈើជាតិ : | ១,៧ លាន | ២-គ្រប់គ្រងព្រៃឈើអភិរក្ស: | ៦ លាន |
| វិស័យឯកជន | ១,៦ លាន | ៣-អនុវត្តន៍ច្បាប់និងអភិបាលកិច្ច: | ១ លាន |
| ម្ចាស់ជំនួយអង្គការមិនមែនរដ្ឋាភិបាល | ៦៥,៨លាន | ៤-កម្មវិធីសហគមន៍ព្រៃឈើ: | ៧,២លាន |
| ប្រភពផ្សេងៗទៀត | ០,៥ លាន | ៥-អភិវឌ្ឍន៍សមត្ថភាពនិងការស្រាវជ្រាវ: | ២,៨ លាន |
| ហិរញ្ញប្បទានដំបូង | ៧០.៦លាន | ចំណាយដំបូង | ៧០,៦លាន |

## -ផែការគ្រប់គ្រងប្រភពហិរញ្ញប្បទានៈ

ដើម្បីគ្រប់គ្រងហិរញ្ញប្បទានគ្រប់ប្រភព មកអភិវឌ្ឍន៏វិស័យព្រៃឈើ តាមកម្មវិធីអាទិភាពនៃកម្មវិធីព្រៃឈើជាតិ គម្រោងត្រូវរៀបចំអនុកម្មវិធីៈ

១-អនុកម្មវិធី ហិរញ្ញប្បទាន ពីរដ្ឋាភិបាល

២-អនុកម្មវិធី ហិរញ្ញប្បទាន ពីព្រៃឈើជាតិ

៣-អនុកម្មវិធី ហិរញ្ញប្បទាន ពីវិស័យឯកជន និងសហគមន៍

៤-អនុកម្មវិធី ហិរញ្ញប្បទាន តាមរយៈជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល

៥-អនុកម្មវិធី ហិរញ្ញប្បទាន របកគំហើញ CDM/REDD កីឡាប្រមាញ់ និងជំរុំទេសចរណ៍ធម្មជាតិ

## ១-អនុកម្មវិធី ហិរញ្ញប្បទាន ពីរដ្ឋាភិបាល

-ការិយាល័យផែនការ និង គណនេយ្យហិរញ្ញវត្ថុត្រូវតាមដាន កត់ត្រានូវប្រភពចំណូល

-រៀបចំតារាងគណនេយ្យប្រចាំឆ្នាំត្រូវមានកត់ត្រាលំអិត និងបើកចំហសំរាប់សាធារណៈជន

-រៀបចំស្ថាបន័ថវិកា ដើម្បីកត់ត្រា និងបង្វិលថវិកាមកអនុវត្តកម្មវិធីព្រៃឈើជាតិ

-រៀបចំក្របខណ្ឌ័សកម្មភាពកម្មវិធីព្រៃឈើជាតិ ទៅក្នុងក្របខណ្ឌ័ថវិកាជាតិ

-រៀបចំថវិកាអនុវត្តមកម្មវិធីឱ្យសមស្រប នឹងសមត្ថភាព និងលទ្ធភាពធនធានមនុស្ស

## ២-អនុកម្មវិធី ហិរញ្ញប្បទាន ពីព្រៃឈើជាតិ

-រៀបចំចំណូលថ្លៃសួយ បុព្វលាភផលឈើ និង ពន្ធផ្សេងទៀតលើអាជីវកម្ម

-រៀបចំចំណូលការលក់ផលិតផល អនុផលព្រៃឈើផ្សេងៗទៀតដូចជាធ្យូង... ។ល ។

-រៀបចំចំណូលការលក់ការបោនព្រៃឈើ តាមតួនាទីរបស់ព្រៃឈើ

-រៀបចំបង្កើនចំណូល ការកែច្នៃផលព្រៃឈើ ដើម្បីបង្កើតតម្លៃបន្ថែម





## ៣-អនុកម្មវិធីហិរញ្ញប្បទានពីវិស័យឯកជន និងសហគមន៍ព្រៃឈើ



-រៀបចំគ្រប់គ្រងពន្ធលើអចលនវត្ថុលើចំការឈើដាំឯកជន

-រៀបចំគ្រប់គ្រង់ចំណូលសួយសារនិង បុព្វលាភពីការកាប់ឈើ នៅក្នុងសហគមន៍ព្រៃឈើ ដែលមានទិសដៅពាណិជ្ជកម្ម

-រៀបចំគ្រប់គ្រងចំណូលសួយសារ និង បុពលាភពីការកាប់ឈើ នៅក្នុងតំបន់សម្បទាន



-រៀបចំការផ្តល់សេវាកម្មពីរដ្ឋបាលព្រៃឈើ ឧទាហរណ៍ គំរោងគ្រប់គ្រង និង ផ្សព្វផ្សាយវិសយ័ព្រៃឈើ ដល់វិសយ័ឯកជន

## ៤-អនុកម្មវិធី ហិរញ្ញប្បទាន តាមរយៈជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល

-រៀបចំកម្មវិធី/គម្រោងតាមទម្រង់ងាយស្រួលសម្រាប់មូលដ្ឋានអនុវត្តនិងតាមដាន

-រៀបចំវិធីសាស្រ្តការផ្តល់ហិរញ្ញប្បទានរួមជាមួយនឹងបែបបទហិរញ្ញវត្ថុ

-រៀបចំកម្មវិធីអនុវត្តន៏គម្រោងតាមរយៈដៃគូទីបី,វិស័យឯកជន និងស្ថាប័នឯករាជ្យ ដែលមាន សមត្ថភាពពេញលេញ។

## ៥-អនុកម្មវិធី ហិរញ្ញប្បទាន រកបកគំហើញ CDM/REDD កីឡាប្រមាញ់ និង ជំរុំទេសចរណ៍ធម្មជាតិ

-រៀបចំគ្រប់គ្រងការបង់ប្រាក់សំរាប់សេវាកម្មបរិស្ថាន

-រៀបចំគ្រប់គ្រងចំណូលពីការចូលកំសាន្តតំបន់ ជំរុំទេសចរណ៍ធម្មជាតិ

-រៀបចំគ្រប់គ្រងការចេញអជ្ញាប័ណ្ណផ្តល់សិទ្ធប្រើប្រាស់ដីព្រៃឈើ

-រៀបចំគ្រប់គ្រងការលក់តំលៃកាបូនដោយជៀសវាងការដាំដើមឈើឡើងវិញ

-រៀបចំគ្រប់គ្រងការលក់ស្តុកកាបូនដោយបានមកពីការកាត់បន្ថយផលប៉ះពាល់ ពីការធ្វើអាជីវកម្មព្រៃឈើ

-រៀបចំគ្រប់គ្រងការលក់ស្តុក/អាងកាបូននៅតំបន់ព្រៃល្បោះរេចរិល

-រៀបចគ្រប់គ្រងការលក់សិទ្ធប្រមាញ់

## គ-សេចក្ដីសន្និដ្ឋាន ៖

ដើម្បីរៀបចំអនុកម្មវិធីប្រភពចំណូលទាំង ៥ អនុកម្មវិធីខាងលើ រួមជាមួយការរៀបចំប្រភពចំណូល-ចំណាយ ប្រកបដោយនិរន្តរភាពតាមគោលបំណង និង យុទ្ធសាស្ត្រ ដើម្បីគាំទ្រសកម្មភាពកម្មវិធីព្រៃឈើជាតិ តម្រង់ទិសតាមទស្សនៈវិស័យគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរៈភាពនោះ គួរជម្រុញដំណើរការវិនិយោគវិស័យព្រៃឈើ ឱ្យស្រប តាមគោលការណ៍ប្រពន្ធ័គ្រប់គ្រងធនធានធម្មជាតិសកល និង តំបន់ ដូចកម្មវិធី បានផ្ដល់ការវិភាគ និង លិទ្ធផលសិក្សា។ ព្រោះការវិនិយោគវិស័យព្រៃឈើ និងការដាំដុះព្រៃឈើជាទុនប្រតិបត្តិការ ចំណូល-ចំណាយ គួបផ្សំការរៀបចំគម្រោង CDM/ REDD កីឡាប្រមាញ់ និងជំរុំទេសចរណ៍ធម្មជាតិ គឺជាចំណូលការប្រាក់ សម្រាប់ចំណាយមូលធនសង្គមជំនាន់នេះ និងជំនាន់ក្រោយ ។

**ឧបសម្ព័ន្ធ ៨:** សំណួរ ចម្លើយ ពីកម្មវិធីព្រៃឈើជាតិ

## សំនួរ ចម្លើយ ពីកម្មវិធីព្រៃឈើជាតិនៅ

ក្រុមការងារសម្រាប់ឆ្លើយនឹងសំនួរសិក្ខាកាមៈ ឯកឧត្តម **ថន សារ៉ាត់** លោក **ឃន សារ៉េត** លោក **សួន សុវណ្ណ** លោក **ចាន់ សុផល** លោក **ប៉ក់ ជាលី** លោក **ឡាវ សេដ្ឋាផល** និងលោក **Arvid Sloth**

*សំនួរទី ១* : តើអភិបាលកិច្ចព្រៃឈើ និងអភិរក្សព្រៃឈើដូចគ្នាឬទេ?

*ចម្លើយទី ១* :អភិបាលកិច្ចជាដំណើរការដូចជា ការបែងចែកផលប្រយោជន៍ដោយសមធម៌ក្នុងសង្គម។ ដូចនេះអភិបាលកិច្ចទាក់ទងនឹងបញ្ហាទាំងអស់ រួមទាំងការអភិរក្សផង។

*សំនួរទី ២* : កម្មវិធីព្រៃឈើជាតិលើកឡើងពីបញ្ហាជាច្រើន តើអ្នកណាជាអ្នកអនុវត្តការងារទាំងនេះ?

*ចម្លើយទី ២*: កម្មវិធីព្រៃឈើជាតិលើកឡើងពីអ្វីដែលត្រូវធ្វើ និងធ្វើដោយរបៀបណា។ មិនសំខាន់លើអ្នកណាជាអ្នកអនុវត្តន៍ទេ។

*សំនួរទី ៣* : រយៈពេលសម្រាប់អនុវត្តកម្មវិធីព្រៃឈើជាតិមាន ៤ឆ្នាំ ៨ឆ្នាំ ៨ឆ្នាំ គឺមិនស៊ីសង្វាក់គ្នាជាមួយនឹងផែនការអភិវឌ្ឍសង្គមជាតិ តើគួរធ្វើដូចម្តេច?

*ចម្លើយទី ៣* : រយៈពេលនេះមិនសំខាន់ទេ។ សំខាន់តើយើងត្រូវធ្វើអ្វី ហើយម្យ៉ាងទៀត យើងអាចកែប្រែរយៈពេលនេះបាន បើចាំបាច់។

*សំនួរទី ៤*: កម្មវិធីព្រៃឈើជាតិគួរយកចិត្តទុកដាក់ក្នុងការកាត់បន្ថយការប្រើប្រាស់ឈើជាថាមពល។ តើយើងគួរគិតគូរពីបញ្ហានេះដោយរបៀបណា?

*ចម្លើយទី ៤*: យើងនឹងដាក់បញ្ចូលបញ្ហាថាមពលនេះទៅក្នុងកម្មវិធីព្រៃឈើជាតិ។

*សំនួរទី ៥*: តើគួរដាក់បញ្ចូលកម្មវិធីរ៉ែ ក្នុងកម្មវិធីព្រៃឈើជាតិដែរឬទេ?

*ចម្លើយទី ៥*: ការយករ៉ែ មិនធ្វើឱ្យខូចខាតព្រៃក្នុងទ្រង់ទ្រាយធំទេ។

*សំនួរទី ៦:* ជាទូទៅ កញ្ចប់ថវិកាសម្រាប់ការបណ្ដុះបណ្ដាលសមត្ថភាពគួរមានយ៉ាងតិច ៥% ។ តែចំពោះកម្មវិធីព្រៃឈើជាតិ មានតិចជាងនេះ តើគួរធ្វើយ៉ាងណា?

*ចម្លើយទី ៦:* ផែនការបណ្ដុះបណ្ដាលរបស់យើងមានតិចជាង ៥ឆ្នាំ ហើយនេះជាការសន្សំសំចៃរបស់យើងទៀតផង ពេលមានថវិកាច្រើនយើងនឹងគិតគួរបន្ថែម ។

**<u>ឧបសម្ព័ន្ធ ១០:</u>** បទបង្ហាញពីលទ្ធផលរបស់ក្រុមពិភាក្សា

# ក្រុម ១: សមាជិក ៣៥ នាក់

## ព្រះតេជគុណ ញ៉ែម គឹមតេង -ប្រធានក្រុម

## លោក ប៊ុល ពិសិដ្ឋ -អ្នកធ្វើកំណត់ត្រា

### ចំណុចដែលត្រូវលើកយកមកពិភាក្សាក្នុងអង្គសិក្ខាសាលា

- តើអ្វីដែលជាឧបសគ្គចំបង រាំងស្ទះដល់ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ហើយថាតើគួរធ្វើយ៉ាងណាដើម្បីដោះ ស្រាយបញ្ហាទាំងនេះ ។
- ព្រៃឈើកំពុងរងការគំរាមកំហែង ពីការចាប់រំលោភយកដីព្រៃ។ តើព្រៃឈើគួរត្រូវបានគ្រប់គ្រងបែបណា អោយ ប្រសើរជាងនេះ។
- វិធីមួយក្នុងការបង្កើនប្រាក់ចំណូលពីព្រៃឈើ គឺការប្រមូលថ្លៃសួយសារ សេវាកម្ម បរិស្ថាន (អ្នកក្រុងបង់លុយសំរាប់ ប្រើប្រាស់ទឹកស្អាតពីព្រៃឈើ ។តើប្រទេសកម្ពុជាអាចធ្វើបែបនេះបានឬទេ ? បើបាន តើពេលណា ហើយគួរធ្វើយ៉ាង ដូចម្តេច ?
- តើអ្នកអាចស្នើជាយន្តការសំរាប់ការបែងចែកផលប្រយោជន៍ពីព្រៃឈើដោយសមធម៌បានទេ (រវាងរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងក្រុមហ៊ុន)
- តើកិច្ចការអ្វីខ្លះដែលត្រូវធ្វើ ក្នុងវិស័យសិក្សាធិការ ពិសេសលើមុខវិជ្ជាការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីគាំទ្រដល់ គោលដៅនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ?

# ឧបស័គ្គចំបង

- ការអនុវត្តច្បាប់ មិនទាន់មានប្រសិទ្ធិភាព
- ការចូលរួមពីស្ថាប័នពាក់ព័ន្ធនៅមានកំរិត
- ការវិនិយោគទុនមិនទាន់ធ្វើឱ្យអស់លទ្ធភាព និងមិនទាន់គោរពកិច្ច ព្រមព្រៀងឱ្យបានពេញលេញនៅឡើយ
- ការយល់ដឹងរបស់ប្រជាជននៅមានកំរិត
- មិនទាន់មានច្បាប់គ្រប់គ្រាន់ ហើយនៅតែមាន អ្នករុករានដីព្រៃច្រើន

# ឧបស័គ្គចំបង

- មិនទាន់មានភាពច្បាស់អំពីសមត្ថកិច្ច រវាងរដ្ឋបាលព្រៃឈើនិងបរិស្ថាន
- ដីព្រៃឈើមិនបានកំណត់ និងចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋនៅឡើយ
- ខ្វះសមត្ថភាពក្នុងការរៀបចំការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ខ្វះការលើកទឹកចិត្តដល់មន្ត្រីជំនាញក្នុងការបំពេញការងារ
- ការមិនបានបន្សីគ្នា រវាងច្បាប់ព្រៃឈើ និងច្បាប់តំបន់ការពារ

## ឧបសគ្គចំបង

- មិនមានការវិនិយោគដើម្បីការពារព្រៃឈើ មានតែការវិនិយោគដើម្បីបំប្លែងព្រៃឈើ និងមិនមានគោលដៅច្បាស់លាស់
- មិនមានកម្មវិធីព្រៃឈើជាតិ សំរាប់អនុវត្តនៅឡើយ
- ភាពក្រីក្ររបស់ប្រជាជនមូលដ្ឋាននៅមានច្រើន
- មិនមានការកំណត់មុខងារព្រៃឈើឱ្យបានច្បាស់ ដើម្បីងាយស្រួលក្នុងការធ្វើផែនការគ្រប់គ្រង

## ឧបសគ្គចំបង

- នៅមានការប្រើប្រាស់ថាមពលពីព្រៃឈើច្រើន
- មិនមានការព្រមព្រៀងគ្នា លើយន្តការគ្រប់គ្រង រវាងគ្រប់ភាគីពាក់ព័ន្ធ
- ប្រជាជនខ្វះដីធ្វើស្រែចំការ និង ដីសំរាប់លំនៅដ្ឋាន និងការធ្វើអាជីវកម្មរ៉ែខុសច្បាប់
- ខ្វះថវិកា និងមធ្យោបាយ ដើម្បីអនុវត្តផែនការ
- ទីផ្សារដីមានតំលៃខ្ពស់

## ដំណោះស្រាយ ១

- បង្កើនការបង្កើតសហគមន៍ព្រៃឈើ
- កសាងសមត្ថភាពជំនាញដល់អ្នកគ្រប់គ្រងសហគមន៍ព្រៃឈើ
- ស្វែងរកថវិកាឱ្យបានតាមផែនការគ្រោងទុក
- ពង្រឹងការអនុវត្តច្បាប់ព្រៃឈើឱ្យមានប្រសិទ្ធិភាព និងមានការចូលរួមត្រួតពិនិត្យអំពីអជ្ញាធរមូលដ្ឋាន
- ផែនការគ្រប់គ្រងនេះគួរផែកលើច្បាប់ព្រៃឈើ និងច្បាប់តំបន់ការពារ

## ដំណោះស្រាយ ១

- បង្កើនការអប់រំនិងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- គួរកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ យកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន
- ត្រូវមានបង្គោលព្រំប្រទល់ច្បាស់លាស់
- ការផ្តល់ឱ្យនូវដីសម្បទានដល់ក្រុមហុនណាមួយ គួរមានការព្រមព្រៀងពីប្រជាជនមូលដ្ឋាន
- បំបែរការប្រើប្រាស់ថាមពលព្រៃឈើ ជាថាមពលរ៉ែ ធ្យូង ហ្គាស អគ្គិសនី

# ដំណោះស្រាយ ២

- គាំទ្រសហគមន៍ការពារព្រៃឈើ ជាបណ្តាញក្នុងតំបន់ព្រៃធំៗ
- មានវិធានការតាមផ្លូវច្បាប់ចំពោះបុគ្គលដែលរំលោភដីព្រៃ និងជ្រកក្រោមរូបភាពអភិវឌ្ឍន៍
- ធ្វើចំណាត់ថ្នាក់ដីធ្លីឱ្យបានច្បាស់លាស់
- បង្កើនប្រាក់ចំណូលរបស់ប្រជាជន ឱ្យស្របនឹងច្បាប់
- ជំរុញការផ្សព្វផ្សាយច្បាប់ ឱ្យបានទូលំទូលាយ
- បោះព្រំប្រទល់ និងដាក់ផ្លាកសំគាល់ដីព្រៃឈើឱ្យបានច្បាស់លាស់

# ដំណោះស្រាយ ២

- ព្រៃឈើគួរគ្រប់គ្រងតាមប្រព័ន្ធច្បាប់ដ៏តឹងរ៉ឹងបំផុតមួយ
- រដ្ឋអំណាចត្រូវទប់ស្កាត់ មិនត្រូវធ្វើលិខិតកាន់កាប់ដីរដ្ឋ ឱ្យជាកម្មសិទ្ធិបានទេ
- ពង្រឹងការត្រួតពិនិត្យ បទល្មើស និង ពង្រឹងសហគមន៍មូលដ្ឋាន ក្នុងការការពារព្រៃឈើ
- បង្កើនកិច្ចសហការ រវាងស្ថាបនពាក់ព័ន្ធ ដើម្បីពង្រឹងកិច្ចការពារព្រៃឈើ
- គួរឱ្យភ្នាក់ងាររដ្ឋបាលព្រៃឈើ បោះទីតាំងនៅក្បែរដែនព្រៃ និងចុះត្រួតពិនិត្យជាប្រចាំ

# ដំណោះស្រាយ ៣

- គួរកំណត់យកពន្ធលើឧស្សាហកម្ម ដែលប៉ះពាល់ដល់បរិស្ថាន ហើយបង្វិលថវិកានេះទៅគាំទ្រដល់សហគមន៍ព្រៃឈើ
- សេវាកម្មបរិស្ថានពីព្រៃឈើ- ឧទា. ទឹក អាចបង់ពន្ធ សួយសារ សេវាកម្មបាននៅពេលដែលប្រជាជនមានប្រាក់ចំណូលច្រើនជាងពេលនេះ
- អ្នកធ្វើអាជីវកម្មទឹក គួរត្រូវបង់សួយសារឱ្យវិស័យព្រៃឈើ

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈ

លើកម្មវិធីព្រៃឈើជាតិ

លទ្ធផលនៃកិច្ចពិភាក្សាក្រុម ២លើប្រធានបទ

ឯកសារក្របខណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិ

កំពង់ចាម ទី៤-៥ មិថុនា ២០០៩

## កិច្ចការដែលត្រូវធ្វើក្នុងវិស័យសិក្សាធិការ លើមុខវិជ្ជា ការគ្រប់គ្រងធនធានធម្មជាតិ

- បញ្ចូលច្បាប់ព្រៃឈើ និងច្បាប់ដែលពាក់ព័ន្ធនិងការអភិរក្សក្នុងកម្មវិធីសិក្សា
- ធ្វើការផ្សព្វផ្សាយច្បាប់ព្រៃឈើ និងច្បាប់ដែលពាក់ព័ន្ធ ។
- បញ្ចូលកម្មវិធីការគ្រប់គ្រងធនធានធម្មជាតិនៅគ្រប់គ្រឹះស្ថានសិក្សាអប់រំ ។
- ធ្វើការស្រាវជ្រាវដែលមានលក្ខណៈ ជាការរៀនសូត្រផង និងអនុវត្តផង ដើម្បីធ្វើការផ្សព្វផ្សាយអោយបានទូលាយ ក្នុងកម្មវិធីអប់រំ ។

- ទស្សនកិច្ចសិក្សា បង្កើនការយល់ដឹង និងបណ្តុះបណ្តាលអោយបានទាន់ពេលវេលា ។
- ផ្តល់ការអប់រំពីទិសដៅនៃការគ្រប់គ្រងព្រៃឈើ ។
- អប់រំអោយចេះទប់ស្កាត់ និងយល់ដឹងពីការទទួលផលពីការការពារព្រៃឈើ ។
- អប់រំពីសេដកិច្ច-សង្គម ។
- អប់រំពីការតាមដាន ត្រួតពិនិត្យ និងរាយការណ៍ ។
- រុក្ខវប្បកម្ម និង អេកូឡូស៊ី ។
- បញ្ចូលច្បាប់ព្រៃឈើក្នុងកម្មវិធីអប់រំ ។

# ការស្នើនូវយន្តការសំរាប់ការបែងចែកផលប្រយោជន៍ពីព្រៃឈើដោយសមធម៌
# (ខាងរដ្ឋាភិបាល សហគមន៍ វិស័យឯកជន)

**បាន**

- វិស័យឯកជនត្រូវបង់ថ្លៃសួយសារជូនរដ្ឋ ហើយរដ្ឋផ្តល់ឱកាសអោយឯកជនធ្វើការអភិវឌ្ឍន៍តាមគោលការណ៍និរន្តរភាព។
- ត្រូវអោយសហគមន៍ច្រើនជាង ព្រោះសហគមន៍ជាម្ចាស់។
- សហគមន៍ទទួលផលប្រយោជន៍ តាមគោលការណ៍របស់រដ្ឋ ហើយក្រុមហ៊ុនទទួលផលប្រយោជន៍តាមកិច្ចសន្យា។
- ពិនិត្យលើការចូលរួមលើការថែរក្សាព្រៃឈើរបស់សហគមន៍។
- បែងចែកផលប្រយោជន៍ ដោយមាន ការចូលរួម និងមានការឯកភាព។

**មិនបាន**

- មិនអាចបែងចែកផលប្រយោជន៍ពីព្រៃឈើដោយសមធម៌បានទេ រវាងសហគមន៍ និងក្រុមហ៊ុន។
- មិនអាចបែងចែកបានទេ ព្រោះរដ្ឋាភិបាលជាអ្នកគ្រប់គ្រង។

- រដ្ឋាភិបាលត្រូវគ្រប់គ្រងនិងដកហូតពន្ធ ចំណែកសហគមន៍ គ្រប់គ្រង និងដកហូតផលប្រយោជន៍ ហើយក្រុមហ៊ុនគ្រប់គ្រង ដកហូតផលចំណេញ ។
- ក្រុមហ៊ុនធ្វើវារីអគ្គិសនីត្រូវបង់ថ្លៃការការពារអោយអ្នកប្រើប្រាស់ព.ឈ ។

## លទ្ធភាពនៃការបង្កើនប្រាក់ចំណូល តាមរយៈការប្រមូលថ្លៃសួយសារពីសេវាកម្មបរិស្ថានរបស់ព្រៃឈើនៅប្រទេសកម្ពុជា (អ្នកត្រូវបង់លុយសំរាប់ប្រើប្រាស់ទឹកស្អាតពីព្រៃឈើ)

**បាន:**

- ការផ្សព្វផ្សាយច្បាប់ដែលទាក់ទងនឹងថ្លៃសួយសារ សេវាកម្មបរិស្ថាន ។
- អប់រំប្រជាពលរដ្ឋអោយយល់ដឹងពីផលប្រយោជន៍ព្រៃឈើ ។

**មិនបាន:**

- ការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើ មិនបានត្រឹមត្រូវ ។
- គួរលើកកំពស់ការកែច្នៃផលិតផល វិញដើម្បីតំរូវទីផ្សារក្នុងតំលៃខ្ពស់ ។

- បញ្ចូលការបង់ប្រាក់ ទៅក្នុង វិក័យប័ត្រអគ្គិសនី ។
- ដកហូតពីក្រុមហ៊ុនធ្វើអាជីវកម្ម ។
- បង្កើតច្បាប់ស្តីពីការប្រើប្រាស់សេវាកម្មព្រៃឈើ ។
- ត្រូវសិក្សាពីចំណូលចិត្តអ្នកប្រើ
  ប្រាស់និងរៀបចំយន្តការក្នុងការ បង់សេវាកម្ម ។

- កំណត់ការបង់ក្នុងកំរិតទាប តែមានតម្លាភាព ។
- បើមិនមានការបំផ្លាញព្រៃឈើ ពីប្រជាជន និងអ្នកមានអំណាច ។
- ប្រជាជនចេះគោរពច្បាប់ ។
- មានច្បាប់ និងនាំគ្នាគោរពច្បាប់ ។
- អ្នកគ្រប់គ្រងប្រភពនិយ័តភាពទឹកត្រូវបង់ប្រាក់អោយអ្នកប្រើប្រាស់ទឹក

តាមរយៈរដ្ឋាករទឹក ។

## ការគ្រប់គ្រងព្រៃឈើឱ្យបានល្អប្រសើរ ដើម្បីទប់ស្កាត់ការចាប់រំលោភយកដីព្រៃ

- កំណត់ព្រំអោយបានច្បាស់លាស់ ។
- ចុះបញ្ជីការអោយបានត្រឹមត្រូវ ។
- ផ្សព្វផ្សាយច្បាប់ព្រៃឈើ ។
- ត្រួតពិនិត្យឱ្យបានជាប់ជាប្រចាំ ។
- អប់រំ ដាក់ពិន័យ និងផ្តន្ទាទោសតាមច្បាប់ ។
- លើកសរសើរដល់មន្ត្រីដែលអនុវត្តល្អ ។

- តុលាការត្រូវកាត់ក្តី អោយទាន់ ពេល និងយុត្តិធម៌ ។
- គ្រប់គ្រងតាមរយៈសហគមន៍មូលដ្ឋាន ។
- ទប់ស្កាត់ និងហាមឃាត់ការរំលោភយកដីព្រៃ ។
- ពង្រឹងការអនុវត្តច្បាប់ ។
- ស្រង់ព័ត៌មានពីអ្នកអត់ដី ។
- មានការឃាមល្បាត នៅតាមតំបន់ព្រៃ ។
- មានការបណ្តុះ បណ្តាលសំរាប់ការរកប្រាក់ចំណូល ។

- កុំអោយក្រុមហ៊ុនរំលោភលើច្បាប់ស្តីពី ព្រៃឈើ ។
- ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។
- ជំរុញអោយមហាជនទប់ស្កាត់បទល្មើសព្រៃឈើ ។
- មានកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ។
- ស្រង់ឈ្មោះអ្នកកាប់រានដីព្រៃហើយអោយគាត់បញ្ចប់សកម្មភាពទាំងនេះ

រីឯដីដែលកាប់រានត្រូវដកហូតជាសម្បត្តិរដ្ឋ ។

- ដីដកហូតបានត្រូវដាំដើមឈើឡើងវិញ ។

- បង្កើតសហគមន៍ព្រៃឈើ ។
- លុបបំបាត់ព្រៃសម្បទាន និងបង្កើតព្រៃអភិរក្សវិញ តាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ច ។
- អ្នកមានប្រាក់ និងមានអំណាចត្រូវចូលរួមក្នុងការគ្រប់គ្រងព្រៃ ។
- តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័តមាន ។

ក្រុមពិភាក្សា ទី៣ : កម្មវិធីវិនិយោគវិស័យព្រៃឈើ

**ទី១ : ការប៉ាន់ប្រមាណនូវថវិកាសំរាប់អនុវត្តកម្មវិធីនាំងឆ្នាំ**

**ក្រុមបានធ្វើការឯកភាពក្រោមការ យល់ឃើញដូចខាងក្រោម :**

១-ត្រូវធ្វើការចាត់អាទិភាពកម្មវិធីនីមួយៗតាមរយៈ

-ពង្រឹងការអនុវត្តន៍ច្បាប់ វាជាការងារសំខានណាស់ក្នុងស្ថានភាពបច្ចុប្បន្ន ប៉ុន្តែវាមានថវិកាត្រឹមតែ ១លាន ដុល្លាប៉ុណ្ណោះ ក្នុងរយៈពេល ១២ ឆ្នាំ ។

-ការកាត់បន្ថយភាពក្រីក្រគឺជាការងារអាទិភាព និងបន្ទាន់ ដូច្នេះការប្រគល់ព្រៃទៅឱ្យសហគមន៍គឺជាការសំខាន់ តាមរយៈកម្មវិធីសហគមន៍ព្រៃឈើ ។

២-ទឹកប្រាក់ចំនួន ៧០,៦ លាន ដុល្លាសហរដ្ឋអាមេរិកនៅក្នុងរយៈពេល ១២ ឆ្នាំ គួរធ្វើការបែងចែកចំណាយឱ្យបានសមស្របតាមកម្មវិធីនីមួយៗ ។

៣-ត្រូវសិក្សាលើតម្រូវការជាក់ស្តែងតាមកម្មវិធីនីមួយៗ ទើបដឹងពីការចំណាយជាក់លាក់ ពិសេសគឺផែនការសកម្មភាព និងការចំណាយមួយដែលមានភាពបត់បែនតាមស្ថានការណ៍ (Action Plan) ។

៤-អន្តរអំពើរវាងកម្មវិធីនីមួយៗនៅក្នុងកម្មវិធីព្រៃឈើជាតិ : ជាឧទាហរណ៍ កម្មវិធី១ នៅពេលត្រូវការពង្រឹងសមត្ថភាព ត្រូវពាក់ព័ន្ធដល់កម្មវិធីទី៥ ។ចុះបង្ក្រាបបទល្មើសត្រូវការកម្មវិធីទី៣ជាអ្នកជួយអន្តរាគមន៍ ។

## ទី២ : ការងារអទិភាពដែលចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើដើម្បីៈ

**២.១ : ប្រមូលប្រាក់ចំណូលពីអាជីវកម្មឈើមូលៈ** ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងវិស័យព្រៃឈើឱ្យបានល្អ (ផែនការអាជីវកម្ម លទ្ធកម្ម ការត្រួតពិនិត្យ និងការវាយតំលៃ):

-រៀបចំនិង វិភាគផែនការប្រើប្រាស់ឈើក្នុងស្រុក ដែលសមស្រប

-នីតិវិធីរដ្ឋបាលឱ្យខ្លី

-តំលៃពន្ធ និងសេវា មេត្តាពិនិត្យឡើងវិញ ថាសមស្រប ឬអត់

-ពង្រឹកការអនុវត្តន៍ច្បាប់

## ២.២ : ការបណ្តាក់ទុននៅក្នុង និងការប្រមូលប្រាក់ចំណូលពីការលក់កាបោនព្រៃឈើក្រោមយន្តការការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការកាប់បំផ្លាញព្រៃឈើ :

**(Reduce Emission from Degradation and forest Degradation-REDD) :**

-ប្រាក់ដែលបានលក់ ត្រូវពិចារណាពីការជួយដល់សហគមន៍បានចំនួនប៉ុន្មានក្នុងក៏រិតណានោះ ។ ផ្តល់អាទិភាពដល់សហគមន៍ និងជួយគាំទ្រដល់សហគមន៍ក្នុងកិច្ចខិតខំប្រឹងប្រែង ថែរក្សា ការពារព្រៃធម្មជាតិ ហើយធ្វើការលក់កាបោន ដែលបានពីព្រៃទាំងនោះ។

-ធ្វើការផ្សព្វផ្សាយពីផលប្រយោជន៍ពី REDD  ពីតំលៃរបស់វា ដើម្បីចូលរួមអភិវឌ្ឍ ការការពារ ការថែរក្សា និងអភិរក្ស ។

**២.៣ : ការបណ្តាក់ទុន និងប្រមូលប្រាក់ចំណូលពីសម្បទានបែបអភិរក្សគឺ :** វាមានចំនួន ២ប្រភេទៈ

១-ការបណ្តាក់ទុន ដោយសហគមន៍ : បង្កើតគោលការណ៍សំរាប់សហគមន៍

២-ការបណ្តាក់ទុនដោយក្រុមហ៊ុនឯកជន :

ត្រូវមានលក្ខខណ្ឌដោយធ្វើការផ្តល់ការងារដល់ប្រជាជននៅមូលដ្ឋាននោះ និងធ្វើការបែងចែកផលចំណូលបានពីសម្បទានអភិរក្សនេះដល់សហគមន៍ ក្នុងទិសដៅបង្កើនជីវភាព ។

**ទី៣ : ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពលើការបោះបង្គោលព្រំ ការសិក្សាស្រាវជ្រាវ ការដាំដុះថ្នាលបណ្តុះកូនឈើ ដោយមានការត្រួតពិនិត្យពីស្ថាប័នឯករាជ្យត្រូវៈ**

-ត្រូវបង្កើតគណៈកម្មការចម្រុះដើម្បីឱ្យមានប្រសិទ្ធភាពលើការបោះបង្គោលព្រំព្រៃឈើ

-ពង្រឹងសមត្ថភាពដល់គណៈកម្មការដែលបានបង្កើតនោះ

-មានផែនការច្បាស់លាស់

-ជ្រើសរើសយកប្រព័ន្ធម៉ៅការក្នុងការបោះបង្គោលព្រំព្រៃ ( គ្រប់ការងារទាំងអស់ មិនត្រឹមតែការងារបោះបង្គោលព្រំនោះទេ) ដើម្បីធ្វើឱ្យងាយស្រួលក្នុងការត្រួតពិនិត្យ និងការទទួលខុសត្រូវជាក់លាក់ ។

# ក្រុមទី ៤

# ប្រធានបទពិភាក្សា:

# កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ

| សមាជិកក្រុម: | |
|---|---|
| ១. កែវ ច័ន្ទរដ្ឋា | ៨. លោក ឈី សារឿន |
| ២. លោកស្រី មូល ណេន | ៩. លោក សេង ឆារ៉ុប |
| ៣. កញ្ញា ចាន់ស្រីរត្ន័ | ១០. លោកព្រី ផល្លីផូង |
| ៤. លោក លី សាវុធ | ១១. លោក ចឹក សារអន |
| ៥. លោក រីក ជរ | ១២. លោក នួន សុជាតិ |
| ៦. លោក ច្រាន់ ទាន់ | ១៤. លោក គឹម ឧុតនិត្យា |
| ៧. លោក អ៊ិច សាន | ១៥. លោក សយ សុផាត |

(រំលងលេខ ១៣ ក្នុងតារាងខាងលើ ត្រូវបានកែ៖)

## ប្រធានបទទី១ :

## ការគណនាដំបូងបានប៉ាន់ប្រមាណឃើញនូវចំនួនថវិកាសំរាប់អនុវត្តកម្មវិធីទាំង៥ ដូចខាងក្រោម ។ តើអ្នកយល់ឃើញយ៉ាងណា?

កម្មវិធីទី១: ការចំណាយចំពោះការបោះបង្គោលព្រំគួរបន្ថយដើម្បីយកថវិការជួយកម្មវិធី ឯទៀត

កម្មវិធីទី២: ការចំណាយសំរាប់កម្មវិធីគ្រប់គ្រង និងអភិរក្សគួរបង្កើនឱ្យបានច្រើនជាងនេះ ព្រោះមានការងារច្រើនដែលត្រូវធ្វើ

កម្មវិធីទី៣: គួរបង្កើនការចំណាយទៅលើការពង្រឹងការអនុវត្តន៏ច្បាប់ និងអភិបាលកិច្ច ព្រោះវាសំខាន់ និងប្រឈមជាងគេ

កម្មវិធីទី៤: គួរបន្ថែមការចំណាយលើកម្មវិធីសហគមន៍ព្រៃឈើ ព្រោះសហគមន៍ព្រៃឈើ មានចំនួនច្រើន និងត្រូវពង្រីកបន្ថែមទៀត

❖ កម្មវិធីទី៥: ការចំណាតសំរាប់ការពង្រឹងសមត្ថភាព និងការស្រាវជ្រាវក៏គួរបន្ថែមដើម្បី ឱ្យការអនុវត្តកម្មវិធីព្រៃឈើជាតិទទួលបានជោគជ័យ ។

## ប្រធានបទទី១ (ត)

- ការបោះបង្គោលព្រំដូចជាមានចំណាយច្រើនពេក ។ ប៉ុន្តែបង្គោលព្រំសុំឱ្យមាន លក្ខណៈធំជាងមុន វែងជាងមុន និងមានគុណភាព ជាពិសេសដាំបានជ្រៅ ទៅក្នុងដីមិនងាយរើរុសបាន ។
- គួរបោះពីមួយទៅមួយចម្ងាយ ២០០ម ទៅ៣០០ម ចំពោះបង្គោលធម្មតា
- ឯបង្គោលខ្នាតធំ សុំឱ្យរក្សាតាមខ្នាតចាស់
- ចំពោះតម្លៃបង្គោលព្រំបើគិតតាមបទពិសោធន៍សាកល្បងលើកដំបូងឆ្នាំ២០០២ ៥០០4,៛កម ឃើញថាសមរម្យ អាចទទួលយកបាន ប៉ុន្តែការបង្កើនចំនួនមន្ត្រី មើលការខុសត្រូវ ឱ្យមានចំនួនច្រើន ក៏សំខាន់ណាស់ដែរ ។
- ការបោះបង្គោលព្រំជាការចាំបាច់ តែចំណាយច្រើន ហើយមិនអាចមានប្រសិទ្ធិភាព គួរបន្ថែមការចំណាយក្នុងការអនុវត្តច្បាប់ និងអភិបាលកិច្ច ឱ្យបានពេញលេញ ទើបប្រសើរជាង ។
- បង្គោលព្រំអាចបាត់ ដោយមនុស្សមិនគោរពច្បាប់បំផ្លាញ ។

## ប្រធានបទទី២ :
## តើក្នុងការងារអាទិភាពអ្វីខ្លះ ដែលអ្នកចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ

❖ ២.១ ប្រមូលប្រាក់ចំណូលពីអាជីវកម្មឈើមូល ដែលគ្រប់គ្រងដោយរដ្ឋាភិបាល

- ពង្រឹងការគ្រប់គ្រងលើការចំណាយទៅលើការគ្រប់គ្រង និងអភិរក្ស

## ប្រធានបទទី២ :
## តើក្នុងការងារអាទិភាពអ្វីខ្លះ ដែលអ្នកចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ

❖២.២ ការបណ្តាក់ទុនទៅក្នុងនិងការប្រមូលប្រាក់ចំណូលពីការលក់កាបោនព្រៃឈើក្រោមយន្តការ ប្រ៉ែឧ

- ការបណ្តាក់ទុននៅក្នុង និងការប្រមូលប្រាក់ចំណូលពីការលក់កាបោនព្រៃឈើគឺជាអាទិភាពល្អ ប្រសើរឡើង
- ថែរក្សាព្រៃឈើធនធានធម្មជាតិជាគំរបព្រៃឈើ ៦០% ដើម្បីលក់កាបោន
- ផ្តល់ព្រៃឈើឱ្យសហគមន៍រៀបចំសហគមន៍ព្រៃឈើ ដែលមានទំហំដីធំៗដូចពីមុន ដើម្បីរួមគ្នាថែ
  រក្សាប្រព័ន្ធអេកូឡូស៊ី ជីវចំរុះនិងមានកាបោនច្រើន
- បង្កើនការរៀបចំសហគមន៍ព្រៃឈើ
- បង្កើនការរៀបចំតំបន់ទេសចរណ៍ធម្មជាតិ
- យើងអាចធ្វើការបណ្តាក់ទុនតាមផ្លូវច្បាប់
- ការលក់ឈើធំត្រូវតែមានការដាំដុះឡើងវិញ និងធានាថាមិនឱ្យបាត់បង់និរន្តរភាពព្រៃឈើ ជាដាច់ខាត

## ប្រធានបទទី២ :
## តើក្នុងការងារអាទិភាពអ្វីខ្លះ ដែលអ្នកចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ

❖២.២ ការបណ្តាក់ទុនទៅក្នុងនិងការប្រមូលប្រាក់ចំណូលពីការលក់កាបោនព្រៃឈើក្រោមយន្តការ ប្រ៉ែឧ

- ក្រោយពេលបង្កើតបាននូវសហគមន៍ព្រៃឈើហើយ គួរតែឱ្យសហគមន៍មានសិទ្ធិស្របច្បាប់
  មួយក្នុងការគ្រប់គ្រងចំណូល ដែលកើតពីអនុផលព្រៃឈើដូចជា :
  - (១) ពន្ធលើអុសដុតត្រូវបានកំណត់ត្រឹមត្រូវឧ
  - (២) អនុផលផ្សេងៗ ដែលបានយកចេញពីព្រៃសហគមន៍
- រាជរដ្ឋាភិបាលគួរផ្តល់អាទិភាពដល់ការបណ្តាក់ទុនទៅក្នុង និការប្រមូលប្រាក់ចំណូលពីការលក់
  - (១)ព្រោះអាចរក្សាបានព្រៃឈើដែលមានស្រាប់
  - (២)ការពារបាននូវបរិយាកាស បរិស្ថាន និងបង្កើនការងារដល់សង្គម

## ប្រធានបទទី២ :
## តើក្នុងការងារអាទិភាពអ្វីខ្លះ ដែលអ្នកចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើ

### ❖២.៣ បណ្តាក់ទុន និងប្រមូលប្រាក់ចំណូលពីសម្បទានបែបអភិរក្ស

- បណ្តាក់ទុន និងសម្បទានដី គួរសម្បទានតែតំបន់រិចរិលពិតប្រាកដ
- គួរចុះទៅសិក្សា រៀន ពិភាក្សាជាមួយសហគមន៍មូលដ្ឋានផ្ទាល់ ដើម្បីដឹងពីតំរូវការរបស់សហគមន៍ពិតប្រាកដ
- ការបណ្តាក់ទុន និងការប្រមូលប្រាក់ចំណូលពីសម្បទានបែបអភិរក្សត្រូវឱ្យមានក្នុងកិច្ចព្រមព្រៀងមួយរវាងភាគី ក និងខ ដើម្បីបន្តការពារថែរក្សាតំបន់ព្រៃអភិរក្ស

## ប្រធានបទទី៣:
## តើមានវិធីសាស្ត្រអ្វីខ្លះដើម្បីជំរុញឱ្យមានប្រសិទ្ធិភាពលើការបោះបង្គោលព្រំ ការសិក្សាស្រាវជ្រាវ ការដាំដុះថ្នាលបណ្តុះកូនឈើដោយមានការត្រួតពិនិត្យដោយស្ថាប័នឯករាជ្យ

- គួរក្រុមការងារខិតខំប្រឹងប្រែងជូនគំរោងទៅម្ចាស់ទុនឱ្យបានឆាប់រហ័ស
- មានស្ថាប័នឯករាជ្យមួយ និងដាក់ឱ្យដេញថ្លៃជាសាធារណៈដោយជ្រើសរើសក្រុមហ៊ុនចាប់ពី ប្រាំឡើងទៅទាំងក្នុងនិងក្រៅស្រុក
- ត្រូវឱ្យសហគមន៍ត្រួតពិនិត្យ
- បង្ហាញផលឈើជូនសាធារណៈជនឱ្យដឹងច្បាស់
- មានផែនការប្រមូលឈើ អភិរក្សឱ្យច្បាស់លាស់ ការបង្កើតក្រុមការងារតាមតំបន់និងថ្នាក់ជាតិ
- ដាក់ទណ្ឌកម្មចំពោះអ្នកកាប់ឈើខុសច្បាប់ ទោះជាក្រុមហ៊ុន ឬអ្នកមានអំណាច
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍
- ផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយ
- ចុះទៅពិភាក្សា និងរៀនសូត្រពីស្ថានភាពរស់នៅរបស់សហគមន៍មូលដ្ឋានផ្ទាល់

**<u>ឧបសម្ព័ន្ធ ១១:</u>** សំណួរ ចម្លើយ ពីលទ្ធផលពិភាក្សាតាមក្រុម

## សំនួរ ចម្លើយ ពីលទ្ធផលពិភាក្សាតាមក្រុម

*សំនួរទី ១:* តើគុណភាពនៃការចូលរួមអាចជាឧបសគ្គសម្រាប់ការអនុវត្តន៍កម្មវិធីព្រៃឈើជាតិដែរឬទេ?

*ចម្លើយទី ១:* គុណភាពនៃការចូលរួមកន្លងមកនៅទាប ព្រោះខ្វះការសហការ ជួនកាលអាចនឹងមានការគាំទ្រដល់ជនខិលខូចទៀតផង។ ដូចនេះការអនុវត្តន៍កម្មវិធីព្រៃឈើជាតិនៅជួបនឹងឧបសគ្គ។

*សំនួរទី ២:* ហេតុអ្វីបានជាការអនុវត្តន៍ច្បាប់មិនមានប្រសិទ្ធភាព?

*ចម្លើយទី ២:* ដោយសារខ្វះការយល់ដឹង និងមិនមានមធ្យោបាយគ្រប់គ្រាន់ក្នុងការអនុវត្តន៍ច្បាប់។

*សំនួរទី ៣:* តើមានជម្រើសបែបណា ដើម្បីបង្វែរការប្រើប្រាស់ឧស ធ្យូង របស់សហគមន៍?

*ចម្លើយទី ៣:* តទៅមុខ យើងនឹងសម្រេចបានការស្រាវជ្រាវរុករកប្រេងកាត និងថាមពលផ្សេងទៀត ដូចនេះយើងអាចបន្ថយការប្រើប្រាស់ឧស ធ្យូងបាន។ ម្យ៉ាងទៀតយើងនឹងធ្វើការអភិវឌ្ឍន៍ចង្ក្រាន ដែលអាចសន្សំសំចៃឧស ធ្យូងបានមយយកម្រិតទៀតផង។

*សំនួរទី ៤:* បើយើងយកពន្ធលើសេវាកម្មបរិស្ថានព្រៃឈើ អាចនឹងនាំឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តើគួរធ្វើដូចម្តេច?

*ចម្លើយទី ៤:* យើងមិនទាន់មានច្បាប់យកពន្ធពីឧស្សាហកម្មដែលប៉ះពាល់ដល់បរិស្ថាននៅឡើយទេ។ ម្យ៉ងទៀត បើយើងយកពន្ធគឺយើងយកតែចំពោះឧស្សាហកម្មធំៗតែប៉ុណ្ណោះ។

**ឧបសម្ព័ន្ធ ១២:** មតិចាប់អារម្មណ៏របស់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

## បញ្ជីឈ្មោះអ្នកចូលរួមចាប់អារម្មណ៍ក្នុងសិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **ញ៉ៀម គឹមតេង** | ប្រធានអង្គការសន្តិសេនា (ខេត្តស្វាយរៀង) |
| ២- ឯ. ឧ. | **ហោ សុភាព** | រដ្ឋលេខាធិការ ក្រសួង ពត៌មាន |
| ៣-លោក | **ខោល យុទ្ធលី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ |
| ៤-លោក | **លិ ទុន្នី** | តំណាងដៃគូរអភិវឌ្ឍន |
| ៥-លោក | **ស្រេង អុន** | ក្រសួងរៀបចំដែនដី នគរូនីយកម្ម សំណង់ និងសុរិយោដី |
| ៦-លោក | **ថន គឹមហុង** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន |
| ៧-លោកស្រី | **ឡឹង ចាន់សុភា** | អនុប្រធានការិយាល័យអធិការកិច្ចបច្ចេកទេស នាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី ក្រសួងពាណិជ្ជកម្ម |
| ៨-លោក | **ស៊ឹម ស៊ីសុខាលី** | ប្រធាននាយកដ្ឋានអភិវឌ្ឍធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| ៩-លោក | **នេត មុនី** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ១០-លោក | **ឡុង សុខា** | ប្រធាននាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ១១-លោក | **ប៉ិល ពិសិដ្ឋ** | ប្រធានកម្មវិធីអង្គការ Concern Worldwide |
| ១២-លោកស្រី | **សែ សុភី** | តំណាងបណ្តាញកម្មវិធីព្រៃឈើនៃអង្គការ NGO Forum |
| ១៣-លោក | **ជា ជួង** | សហគមន៏ព្រៃឈើ រតនរុក្ខា ឧត្តរមានជ័យ |
| ១៤-លោក | **សេង សុខហេង** | តំណាងបណ្តាញកម្មវិធីព្រៃឈើឧត្តរមានជ័យ |

# ចំណាប់អារម្មណ៍

របស់ព្រះតេជគុណ **ញៀម គីមតេង** (វជិរប្បញ្ញោ) នាយកអង្គការសន្តិសេនា ខេត្តស្វាយរៀង

ជាដំបូងខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងអំណរគុណនិងការកោតសរសើរយ៉ាងក្រៃលែង ចំពោះក្រុមការងារបច្ចេកទេសនិងបរិស្ថាន ដែលបានរៀបចំបង្កើតសិក្ខាសាលានេះឡើង ។

ខ្ញុំព្រះករុណាអាត្មាភាពបានកត់សម្គាល់ថា សិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ មានរយៈពេលពីរថ្ងៃនេះ ពិតជាមានសារសំខាន់បំផុត ព្រោះថាសិក្ខាសាលានេះបានអញ្ជើញអ្នកពាក់ព័ន្ធគ្រប់សមាសភាពមកពីគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមពិភាក្សាប្តូរយោបល់គ្នា ស្វែងរកគន្លឹះក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។
សិក្ខាសាលានេះបានធ្វើឱ្យយើងមានឱកាសបានផ្លាស់ប្តូរមតិ យោបល់
និងបានទទួលនូវព័តិមានល្អៗពីគ្នាទៅវិញទៅមក ។

ក្រោយការបានស្តាប់នូវបទបង្ហាញ និងការពន្យល់របស់វាគ្មិនគ្រប់រូប ក៏ដូចជាការពិភាក្សាគ្នាមក, ខ្ញុំ ព្រះករុណាអាត្មាភាពជឿជាក់ថា ដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ
របស់យើងនឹងបានទទួលជោគ ជ័យដោយពិតប្រាកដ ។ ទោះបីជាយ៉ាងនេះក៏ដោយ,
ខ្ញុំព្រះករុណាអាត្មាភាព សូមធ្វើសំណូមពរយ៉ាងទទូច ដល់ក្រុមការងារបច្ចេកទេស
មេត្តាពិចារណានិងដាក់បញ្ចូលនូវការផ្តល់លទ្ធភាពតាមផ្លូវច្បាប់ ដល់ព្រះសង្ឃ
និងវត្តអារាមក្នុងការចូលរួម លើផែនការអភិវឌ្ឍន៏កម្មវិធីព្រៃឈើជាតិ ។

ទីបញ្ចប់ខ្ញុំព្រះករុណាអាត្មាភាព សូមប្រគេនពរព្រះតេជគុណគ្រប់អង្គ និងជូនពរឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញាគ្រប់រូប នូវពុទ្ធពរបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ

សូមអរគុណ!

# ចំណាប់អារម្មណ៍របស់ឯកឧត្តម ហោ សុភាព រដ្ឋលេខាធិការក្រសួងព័ត៌មាន
# ក្នុងសិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ
## នៅសណ្ឋាគារភ្នំព្រុស ថ្ងៃទី ០៤-០៥ ខែមិថុនា ឆ្នាំ២០០៩

ក្នុងនាមឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអបអរសាទរ និងកោតសរសើរយ៉ាងក្រៃលែងចំពោះ **រដ្ឋបាលព្រៃឈើ** ដែលដឹកនាំដោយឯកឧត្តម **ឆឺ សុគន្ធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ដែលបានខិតខំប្រឹងប្រែងក្នុងដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិនេះឡើងក្នុងរយៈពេលវែងដែលមិនធ្លាប់មានកន្លងមក ។

ក្នុងគោលបំណងសម្រេចឱ្យបានពីគោលនយោបាយចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។

ក្នុងនាមឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមឱ្យសារព័ត៌មានជាតិ និងសារព័ត៌មានឯកជនទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា សូមលោកមេត្តាចូលរួម ជួយគាំទ្រ និងផ្សព្វផ្សាយ អំពីខ្លឹមសារនៃការខិតខំប្រឹងប្រែងរបស់រដ្ឋបាលព្រៃឈើ **ស្តីពីកម្មវិធីព្រៃឈើជាតិនេះ** ក្នុងគោលបំណងសម្រេចឱ្យបានពីបំណងរបស់យើងទាំងអស់គ្នា និងមនុស្សជាតិទាំងមូល ដើម្បីពិភពផែនដី មានសុខភាពឡើងវិញ ។

ជាទីបញ្ចប់ សូមគោរពជូនពរអង្គសិក្ខាសាលា និងរដ្ឋបាលព្រៃឈើ ប្រកបដោយជោគជ័យ ។

**សូមអរគុណ !!**

## ចំណាប់អារម្មណ៍លើសិក្ខាសាលាពិគ្រោះយោបល់សាធារណៈ
## លើកម្មវិធីព្រៃឈើជាតិ

ជាបឋម ខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរព ក្រាបថ្វាយបង្គំព្រះថេរ៉ា ព្រះថេរះ គ្រប់ព្រះអង្គជាទីសក្ការៈ

- ឯកឧត្តម លោក លោកស្រី និងដៃគូរអភិវឌ្ឍន៍ជាទីគោរព

ថ្ងៃនេះ ខ្ញុំព្រះករុណា ខ្ញុំបាទមានសេចក្តីរីករាយជាពន់ពេក ដែលបានចូលរួមនៅក្នុង សិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិនៅកម្ពុជា ដែលរៀបចំឡើងដោយក្រុមការងារបច្ចេក ទេសវិស័យព្រៃឈើ និងបរិស្ថាន ដែលដឹកនាំដោយឯកឧត្តម **ទី សុគន្ធ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងនាមក្រសួងមហាផ្ទៃ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរយ៉ាងខ្លាំងចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសក្រុមការងារបច្ចេកទេសវិស័យព្រៃឈើ និងបរិស្ថាន ដែលបានលើកយកបញ្ហាព្រៃឈើនេះ មកដាក់ជារបៀបវារៈសម្រាប់ធ្វើការជជែកក្នុងគោលបំណង រកដំណោះស្រាយរួមមួយដើម្បីទប់ស្កាត់រាល់បទល្មើសព្រៃឈើដែលកើតមានឡើងកន្លងមក។ យើងដឹងហើយថា បច្ចុប្បន្ននេះព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ត្រូវបាន រងនូវការ បាត់បង់ដោយសារការកាប់ទន្រ្ទានយ៉ាង អនាធិប្បតេយ្យ និង គ្មានច្បាប់ទម្លាប់ ដែលធ្វើឱ្យបានបង់នូវ ជម្រកសត្វ និងជីវសាស្រ្តចំរុះមួយចំនួន សម្រាប់ទ្រទ្រង់នូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមួយចំនួន ដែលពឹងអាស្រ័យផលលើព្រៃឈើនេះ។

**- ព្រះតេជគុណ ឯកឧត្តម លោក លោកស្រី និងដៃគូរអភិវឌ្ឍន៍ជាតិ និងអន្តជាតិជាទីគោរព**

ឆ្លងតាមការពិនិត្យលើសេចក្តីព្រាង កម្មវិធីព្រៃឈើជាតលើកទី៤ នេះ ខ្ញុំបាទបានពិនិត្យ ឃើញថា ឯកសារស្តីពីកម្មវិធីព្រៃឈើជាតិនេះ មិនទាន់បានសរសេរបញ្ជាក់ឱ្យបានច្បាស់អំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធឡើយ ពិសេសអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ ព្រោះយើងទាំងអស់គ្នាបានដឹងច្បាស់ហើយថា ថ្មីៗនេះក្រសួងមហាផ្ទៃ បាន

រៀបចំច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទទួលបានជោគជ័យ និងបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយបានធ្វើការ និង កំពង់ធ្វើការ ប្រកាសតែងតាំងដល់ក្រុមប្រឹក្សាដែលបានជាប់ឆ្នោត។ ហើយកន្លងមកក៏បានធ្វើការរៀបចំ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបំរើឱ្យផល ប្រយោជន៍របស់មូលដ្ឋានដែរ ។ នៅក្នុង មាត្រា ៣៩ ត្រេទី៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានឱ្យ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រៀបចំផែនការអភិវឌ្ឍន៍ ដោយពិនិត្យលើក្របខណ្ឌអភិវឌ្ឍន៍ ដែលចែងពីគោលការណ៍ណែនាំជា មូលដ្ឋានលើការប្រើប្រាស់ និង គ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់។ ហើយនៅក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា ៤១ បានចែងថា " រដ្ឋបាលឃុំ សង្កាត់មានតួនាទីជម្រុញ និងគាំពារអភិវបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានា ដែលមានប្រកបដោយចិរភាពសម្រាប់បំពេញសេចក្ដីត្រូវការ របស់មូលដ្ឋាន " និងមាត្រា ៤៣ ត្រេទី ៥ បានចែងថា " ក្នុងតួរនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងបេតិកភណ្ឌជាតិ " ។

តាមខ្លឹមសារមាត្រានៃច្បាប់ទាំងពីរខាងលើ ដែលខ្ញុំព្រះករុណា ខ្ញុំបាទបានលើកខាងនេះ គឺសរ បញ្ជាក់ឱ្យឃើញថា ច្បាប់បានតម្រូវឱ្យអាជ្ញាធរមូលដ្ឋានចូលរួមចំណែកក្នុងការទប់ស្កាត់ និងថែរក្សា ធនធានធម្មជាតិ សម្បត្តិវប្បធម៌ជាតិ ឱ្យរក្សាបានភាពគង្សវង្សលើធនធានធម្មជាតិទាំងនោះ ប្រកបដោយ និរន្តរភាព ។ គួរបញ្ជាក់ផងដែរថា ថ្មីៗនេះ ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ បានរៀបចំ អនុក្រឹត្យមួយ ស្ដីពីការរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលអនុក្រឹត្យនេះ បានផ្ដល់សិទ្ធិអំណាចឱ្យអាជ្ញាធរមូលដ្ឋានថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ រៀបចំផែនការប្រើប្រាស់ដីនៅមូលដ្ឋានរបស់ខ្លួន ដោយខ្លួនឯងផ្ទាល់ ព្រោះមានតែមូលដ្ឋានខ្លួន ឯងផ្ទាល់ទេ ទើបដឹងថា ដីណាទំនេរ ដីណាមានកម្មសិទ្ធិ ។

**ព្រះតេជគុណ ឯកឧត្ដម លោក លោកស្រី ជាទីគោរព !**

ឆ្លងតាមបទពិសោធន៍នេះ ដើម្បីធ្វើការធានាឱ្យមានការគ្រប់គ្រង និង ថែរក្សាព្រៃឈើ កម្ពុជាឱ្យមាននិរន្តរភាព និងគង់វង្ស ក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់

ខ្ញុំសូមស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យឡើងវិញ ដោយដាក់បញ្ចូលនូវតួនាទីភារកិច្ច និងការទទួលខុសត្រូវ របស់អាជ្ញាធរមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីរួមចំណែកក្នុងការទប់ស្កាត់ បទល្មើសព្រៃឈើ និងការការពារព្រៃឈើឱ្យមាននិរន្តភាព ហើយប្រសិនបើអាចទៅរួច ស្នើឱ្យមន្ត្រីជំនាញ បច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជួបប្រជុំជាមួយមន្ត្រីបច្ចេកទេសរបស់ក្រសួង មហាផ្ទៃ ដើម្បីរៀបចំជាសេចក្តីណែនាំ ឬប្រកាសអន្តរក្រសួង ក្នុងការបង្កើតក្រុមការងារគ្រប់គ្រង និង ថែរក្សាធនធានព្រៃឈើនៅថ្នាក់មូលដ្ឋាន។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងាររៀបចំសិក្ខាសាលាពិភាក្សា ពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើនៅកម្ពុជា របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងដៃគូរអភិវឌ្ឍន៍នានា ដែលបានរួមចំណែកក្នុងការជួយសម្របសម្រួលឱ្យកិច្ចប្រជុំនេះអនុវត្តទៅដោយ រលូន ហើយជាចុងក្រោយខ្ញុំបាទក៏សូមអំពាវនាវផងដែរ ដល់ក្រសួង ស្ថាប័នដែលនឹងត្រូវរៀបចំក្របខណ្ឌ ការងារសម្រាប់ការអនុវត្ត សូមគិតទៅដល់អាជ្ញាធរមូលដ្ឋានដែលនៅកៀកនឹងប្រជាពលរដ្ឋ និង កៀក នឹងទីតាំងដែលត្រូវអនុវត្ត ព្រោះថា មានតែអាជ្ញាធរមូលដ្ឋានដែលស្ថិតនៅកៀកនឹងប្រជាពលរដ្ឋទេ ដែល ដឹងពិតប្រាកដ ការជាក់ស្តែងរបស់មូលដ្ឋាន។

ជាចុងបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមជូនពរ ដល់ព្រះតេជគុណ ឯកឧត្តម លោក លោកស្រី ឱ្យជួបតែពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លៀតឡើយ ។

**សូមអរគុណ !**

# សេចក្តីថ្លែងការណ៍របស់ភ្នាក់ងារដៃគូអភិវឌ្ឍន៍

*DANIDA/DFID/NZAID, FAO, JICA AND UNDP*

កម្មវិធីព្រៃឈើជាតិនឹងចងក្រងបាននូវគោលការណ៍គ្រឹះមួយចំនួនសំខាន់ៗស្តីពីគោលនយោបាយព្រៃឈើនៅកម្ពុជា នៅក្នុងរយៈកាល ២០ឆ្នាំខាងមុខនេះ ។ ភ្នាក់ងារអភិវឌ្ឍន៍សូមចូលរួមវិភាគទានដល់ការរៀបចំកម្មវិធីព្រៃឈើជាតិដោយរីករាយ ។ កិច្ចការដ៏សំខាន់លេចធ្លោមួយ ដែលយើងកំពុងចូលរួមវិភាគទាន នៅពេលនេះ គឺជួយធានាឱ្យបានថាបទពិសោធន៍ទាំងឡាយពីអតីតកាលក្នុងការគ្រប់គ្រងព្រៃឈើត្រូវបានយកមកឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីព្រៃឈើជាតិ ។

ព្រៃឈើបាន និងកំពុងបំរើមុខងារសំខាន់ៗដ៏ច្រើន ។ ព្រៃឈើគ្រប់ប្រភេទជួយដល់ការកើនឡើងសេដ្ឋកិច្ចជាតិជួយកាត់បន្ថយការប្រែប្រួលធាតុអាកាស និងទ្រទ្រង់ការបន្សាំទៅនឹងការប្រែប្រួលនេះ ព្រៃឈើជាជម្រកជីវចំរុះដ៏សន្ធឹកសន្ធាប់ របស់ពិភពលោក និងជាពិសេស វាមានសារៈសំខាន់ជាអាយុជីវិតដល់ជីវភាពប្រចាំថ្ងៃរបស់សហគមន៍ក្រីក្រ ។

បទពិសោធន៍ល្បីល្បាញជាងគេនោះគឺ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពទាមទារជាចាំបាច់នូវគោលនយោបាយ និងយុទ្ធសាស្ត្រសមស្របដែលទ្រទ្រង់ដល់ចំណងទាក់ទងនៃអភិបាលកិច្ច និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ។ ក្នុងបរិបទផលប្រយោជន៍ផ្សេងៗគ្នាជាច្រើននៃព្រៃឈើ ការធ្វើសេចក្តីសំរេចនានាអំពីការប្រើប្រាស់ព្រៃឈើនេះចាំបាច់ផ្តល់អាទិ ភាពឱ្យបានសមស្របទៅតាមកាលៈទេសៈនីមួយៗ ។ ជាការពិតការធ្វើសេចក្តីសំរេចនេះមិនមែនជាការងាយនោះទេ ហើយវាក៏ទាមទារឱ្យមានតម្លាភាព និងគណនេយ្យភាពនៃអភិបាលកិច្ច ដោយឱ្យមានការចូលរួមពីរាល់អ្នកពាក់ព័ន្ធ ដែលរួមមាន សហគមន៍ ក្រុមសង្គមស៊ីវិល ផ្នែកឯកជន និងរដ្ឋាភិបាល ។

ពង្រាងកម្មវិធីព្រៃឈើជាតិនេះផ្តល់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍន៍វិស័យនានាដែលមានចំណងទាក់ទងជាមួយនឹងព្រៃឈើនាអំឡុងពេលឆ្នាំ ២០១០ ដល់ ២០៣០ ។ ដោយឈរលើការយោគយល់គ្នាពីបណ្តាអ្នកពាក់ព័ន្ធទាំងអស់ ក្របខ័ណ្ឌព្រៃឈើជាតិបង្ហាញទិសដៅលើគោលដៅសំខាន់ៗសំរាប់ការអនុវត្តន៍កិច្ចការព្រៃឈើដូចជា :

- ការកំណត់ព្រំព្រៃឈើ និងការចាត់ថ្នាក់ព្រៃឈើ
- ការគ្រប់គ្រងព្រៃឈើជាតិ និងការអភិរក្ស

- កិច្ចការសហគមន៍ព្រៃឈើ
- ការអនុវត្តន៍ច្បាប់ព្រៃឈើ និងអភិបាលកិច្ច
- ការកសាងសមត្ថភាព និងការស្រាវជ្រាវ ហើយនិង
- និរន្តរភាពនៃហិរញ្ញប្បទាននៃព្រៃឈើ ។

ពង្រាងកម្មវិធីព្រៃឈើជាតិនេះផ្តល់នូវការអនុវត្តន៍មួយដ៏មានតម្លាភាពតាមរយៈការចូលរួមពីបណ្តាវិស័យដទៃៗទៀតជាច្រើន ។

គោលការណ៍អនុវត្តកម្មវិធីព្រៃឈើដោយមានការចូលរួមនេះក៏នឹងធានាឱ្យបានផងដែរនូវសង្គតភាពនៃបណ្តាយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានច្បាប់នានារបស់រាជរដ្ឋាភិបាល (ដូចជា យុទ្ធសាស្ត្រចតុកោណផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល) លើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបរិស្ថាន ហើយនិងកិច្ចការអន្តរជាតិសំខាន់ៗជា ច្រើនទៀត ដែលគួរតែដាក់ឱ្យចូលរួមសហការគ្នា ។

ជាការសំខាន់ណាស់ដែលកម្មវិធីព្រៃឈើជាតិដាក់ឱ្យប្រើប្រាស់ និងអនុវត្តជាអាទិភាពលើ :

- ការបញ្ចៀស និងដោះស្រាយទំនាស់
- ប្រព័ន្ធការត្រួតពិនិត្យ និងការវាយតម្លៃ ។

នៅមុនអ្វីៗទាំងអស់ កម្មវិធីនេះនឹងជួយជាប្រទីបដល់តួនាទី និងសមត្ថភាពនៃស្ថាប័នគ្រប់គ្រងដែលទាមទារឱ្យមាន អភិបាលកិច្ចព្រៃឈើដ៏ល្អ ។ កិច្ចសហការក្នុងការគ្រប់គ្រងវិស័យព្រៃឈើ ដែលមានការចូលរួមដោយចំហ ព្រមទាំងក្នុងគោលបំណងរួមគ្នាជាមួយនឹងកម្មវិធីព្រៃឈើជាតិ គឺជាគ្រឹះនៃការអភិវឌ្ឍន៍ព្រៃឈើប្រកបដោយនិរន្តរភាព ។

ការគ្រប់គ្រងធនធានព្រៃឈើតាមរបៀបអភិបាលកិច្ចល្អ និងការកសាងសមត្ថភាពដើម្បីទប់ទល់នឹងបញ្ហាប្រឈម ទាំងឡាយដែលអាចកើតមាន គឺជាយានដ៏សំខាន់មួយនាំទៅដល់ការអភិវឌ្ឍន៍ជនបទ និងប្រជាពលរដ្ឋកម្ពុជាប្រមាណ ៨៥% រស់នៅទីនោះ និងមានផលវិជ្ជមានជាច្រើនលើសលប់ដល់ការកែលំអជីវភាពរបស់ពួកគេ ។

(ប្រែសំរួលក្រៅផ្លូវការ)

# សេចក្តីថ្លែងការណ៍របស់បណ្តាញអង្គការសង្គមស៊ីវិល
# ស្តីពីជីវភាពអាស្រ័យព្រៃឈើ និង ចំការឈើដាំ
# ចំពោះ
# កម្មវិធីព្រៃឈើជាតិកម្ពុជា

- សូមគោរពអង្គសិក្ខាសាលា
- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់
- សូមអរគុណចំពោះឯកឧត្តម លោក លោកស្រីដែលជាអ្នករៀបចំកម្មវិធីទាំងអស់

ក្រោយពីបានចូលរួមសិក្ខាសាលាថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងបានអាននូវរាល់ខ្លឹមសារនៅក្នុងសេចក្តីព្រាងស្តីពីកម្មវិធីព្រៃឈើជាតិកម្ពុជា ក្នុងនាមខ្ញុំបាទ និង ក្នុងនាមអង្គការសង្គមស៊ីវិល សូមប្រកាសនូវគោលជំហរ និង ការយល់ឃើញដូចតទៅ:

- សូមអបអរសារទ និង កោតសរសើរចំពោះគំនិតផ្តួចផ្តើម និង ការខិតខំប្រឹងប្រែងក្នុងការរៀបចំធ្វើសេចក្តីព្រាងនេះឡើង ។
- សូមទទួលស្គាល់ថា កិច្ចអភិវឌ្ឍន៍តាមរយៈការផ្តល់ដីសម្បទានលើផ្ទៃដីប្រមាណ ៧ លាន ហិកតា ប្រមាណ៧០ភាគរយនៃផ្ទៃដីព្រៃ ពិតជាបានរួមចំណែកដ៏ធំក្នុងការបំផ្លិចបំផ្លាញព្រៃ[1] ឈើ ។
- អភិបាលកិច្ចនៅក្នុងវិស័យព្រៃឈើនៅមានកំរិត ដែលនាំទៅដល់ការអនុវត្តន៍ច្បាប់ និង ការគ្រប់គ្រងខ្សោយ បណ្តាលអោយមានការដកហូតឈើនៅក្នុង និង ក្រៅតំបន់ព្រៃសម្បទាន ហួសហេតុ ដែលទង្វើទាំងនេះជាដំណើរឆ្ពោះទៅរកវិនាសកម្មព្រៃឈើ ។
- ប្រតិភូកម្មអំណាចទៅដល់អាជ្ញាធរ និង សហគមន៍មូលដ្ឋានលើវិស័យព្រៃឈើ គួបផ្សំនឹងការយល់ដឹងនៅមានកំរិត ការយល់ច្រឡំបានផុសចេញថា មានតែរដ្ឋបាលព្រៃឈើ និង រដ្ឋ ប៉ុណ្ណោះទើបមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងព្រៃឈើ រួមទាំងមានការផ្សព្វផ្សាយ បំផ្លើសដោយមន្ត្រី និង អាជ្ញាធរខិលខូចមួយចំនួនផងនោះ បានកាត់បន្ថយនូវការចូលរួមក្នុង ការគ្រប់គ្រងវិស័យព្រៃឈើ ហើយបានប្រែក្លាយសកម្មភាពទៅជាកាបំផ្លិចបំផ្លាញ ។

[1] សេចក្តីព្រាងលើកទី២ ស្តីពីកម្មវិធីព្រៃឈើជាតិកម្ពុជា ខែឧសភា ឆ្នាំ ២០០៩ — ទំព័រ ១៨

- ទទួលស្គាល់ថា ករណីបទល្មើសព្រៃឈើមានច្រើនរាប់មិនអស់ ប៉ុន្តែភាពទន់ខ្សោយក្នុងការ ស៊ើបអង្កេត និង បើកអង្គជម្នុំជម្រះក្តីពាក់ព័ន្ធករណីព្រៃឈើ មិនត្រូវបានចាត់អាទិភាព ។
- ពុំទាន់មានសូចនករណ៍ច្បាស់លាស់ណាបានបង្ហាញថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចបាន កាត់បន្ថយភាពក្រីក្រនៅកម្ពុជា ផ្ទុយទៅវិញគេឃើញផ្ទៃដីព្រៃធម្មជាតិបានប្រែក្លាយទៅជា លេណដ្ឋានកាប់ឈើ ជាចំការឈើដាំ និង ការទុកដីអោយនៅទំនេរ ។
- ប្រជាពលរដ្ឋកម្ពុជាមិនមែនជាបញ្ញើក្អែកនៃប្រទេសរបស់ខ្លួនទេ ព្រៃឈើជារបស់យើងទាំង អស់គ្នា ការធ្វើអោយវិនាសកម្មព្រៃឈើ គឺធ្វើអោយមានផលប៉ះពាល់សង្គម បរិស្ថាន សេដ្ឋកិច្ច និង វប្បធម៌ ជាពិសេសជនក្រីក្រ និង ជនជាតិដើមភាគតិចនៅតាមមូលដ្ឋាន។

ព្រះតេជគុណគ្រប់ព្រះអង្គ ជាទីសក្ការៈ ឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ជាទី គោរព រាប់អាន ដើម្បីចូលរួមអនុវត្តអោយសំរេចលើចក្ខុវិស័យ និង បេសកកម្ម កម្មវិធីព្រៃឈើ ជាតិកម្ពុជាអោយមានប្រសិទ្ធិភាព និង ប្រសិទ្ធិផល ក្នុងនាមខ្ញុំបាទ និង ក្នុងនាមអង្គការសង្គមស៊ីវិល សូមផ្តល់អនុសាសន៍ដូចខាងក្រោមៈ

១. ធ្វើការត្រួតពិនិត្យមើលភាពស្របច្បាប់នានាពាក់ព័ន្ធដីសម្បទានសេដ្ឋកិច្ច ធ្វើការដកហូត និង បញ្ឈប់ការផ្តល់បន្ថែម និង ចូលរួមថែរក្សាព្រៃរិចរិលអោយដុះឡើងវិញ។
២. ធ្វើការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថាន និង សង្គមដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ទាំងអស់ ហើយធានាថាព័ត៌មានត្រូវបានបើកចំហរ ចំពោះផ្ទៃដីសម្បទានសេដ្ឋកិច្ច ។
៣. ត្រូវពង្រឹងការអនុវត្តច្បាប់ និង អភិបាលកិច្ចល្អដោយរួមបញ្ចូលនូវការចូលរួម និតិរដ្ឋ តម្លាភាព ការព្រមព្រៀងឯកភាពគ្នា សមធម៌ ប្រសិទ្ធិភាពខ្ពស់ គណនេយ្យភាព និង ការឆ្លើយតបនៅក្នុងវិស័យព្រៃឈើ ។ សិទ្ធិពលរដ្ឋ ជាអង្គការមហាជនចូលរួមការពារ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានអនុវត្ត ។
៤. ធ្វើការប្រកាសជាចំហរបន្ទាន់នូវតំបន់សក្តានុពលសំរាប់រៀបចំសហគមន៍ព្រៃឈើ និង ព្រៃ សហគមន៍ ដែលធានាដល់ការផ្ទេរអំណាចក្នុងការគ្រប់គ្រងដោយសហគមន៍មូលដ្ឋានផ្ទាល់ ។ ធ្វើការជំរុញ និង ចូលរួមដោយមន្ត្រីរដ្ឋបាលព្រៃឈើក្នុងការអនុវត្តន៍រៀបចំសហគមន៍ព្រៃ ឈើ និង ព្រៃសហគមន៍ដែលបាន និង កំពុងមានដំណើរការ ។

៥. ពង្រឹងវប្បធម៌នៃការចែករំលែក ដែលមានអភិបាលកិច្ចល្អជាមូលដ្ឋានគ្រឹះ នៅក្នុងវិស័យ ព្រៃឈើ ជាពិសេសគិតគូដល់ផលប្រយោជន៍ និង ផលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន ប្រកបដោយសមភាព និង សមធម៌ ។

៦. ប្រែក្លាយខ្លឹមសារនៅក្នុងកម្មវិធីព្រៃឈើជាតិកម្ពុជា និង លទ្ធផលពិគ្រោះយោបល់ ដែល បានឯកភាព ជាពិសេសសំណើនានាដែលលើកឡើងដោយសហគមន៍មូលដ្ឋាន ទៅជាកាយ វិការជាក់ស្តែង ប្រកបដោយភាពត្រឹមត្រូវ និង ឈ្លាសវៃ ដើម្បីលើកទឹកចិត្តដល់ការចូលរួម ប្រកបដោយនិរន្តភាព ។

៧. ដើម្បីធានាដល់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព និង ប្រសិទ្ធិផលខ្ពស់ ការត្រួតពិនិត្យ ជាទៀងទាត់ និង ការវាយតម្លៃកម្មវិធីព្រៃឈើជាតិត្រូវរៀបចំឡើងដោយមានការចូលរួម ការទទួលខុសត្រូវ តម្លាភាព និង ភាពជឿជាក់បាន ដែលផ្តល់ឱកាសអោយអ្នកពាក់ព័ន្ធ ទាំងអស់បានធ្វើការឆ្លុះ បញ្ចាំងចក្ខុវិស័យ បេសកកម្មឡើងវិញ និង ប្រែក្លាយការអនុវត្តន៍ ទៅជាការរៀនសូត្រ ។

ធ្វើនៅក្រុងកំពង់ចាម ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩
តំណាងអង្គការសង្គមស៊ីវិល

# សេចក្តីថ្លែងការណ៍របស់សហគមន៍មូលដ្ឋាន
# ក្នុងសិក្ខាសាលាពិគ្រោះយោបល់លើកម្មវិធីព្រៃឈើជាតិ ជា~ ដួង

- ជាបឋមខ្ញុំព្រះករុណាខ្ញុំសូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ
- សូមគោរពឯកឧត្តម លោកជំទាវ ជាទីគោរព
- សូមគោរព អស់ លោក លោកស្រី អង្គការជាតិ អន្តរជាតិជាទីគោរពរាប់អាន

ខ្ញុំព្រះករុណាខ្ញុំឈ្មោះ សេង សុខហេងជាបណ្តាញសហគមន៍ព្រៃឈើអណ្តូងបរ មកពីខេត្តឧត្តរមាន ជ័យ។ ជួសមុខឱ្យសហគមន៍មូលដ្ឋាននានា សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមប្រធាន រដ្ឋបាលព្រៃឈើ ក្រុមការងាររៀបចំកម្មវិធីព្រៃឈើ និង អង្គការម្ចាស់ជំនួយនានាដែលបានផ្តល់ឱកាសឱ្យ សហគមន៍យើងខ្ញុំបានចូលរួម ក្នុងការពិគ្រោះយោបល់លើកម្មវិធីព្រៃឈើជាតិ ជាពិសេសបានផ្តល់ឱកាសឱ្យសហគមន៍មូលដ្ឋានបានឡើងធ្វើសេចក្តី ថ្លែងការណ៍ដើម្បីបង្ហាញពីចំណាប់អារម្មណ៍ចំពោះកម្មវិធីព្រៃឈើជាតិ។

ដូចឯកឧត្តម លោកជំទាវ អស់លោក លោកស្រីបានដឹងហើយថាព្រៃឈើនៅកម្ពុជាត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរតាមរូបភាពផ្សេងៗដូចជាតាមរយៈការកាប់ឈើលក់យ៉ាងអាណាធិបតេយ្យ ការធ្វើអាជីវកម្ម នានាដោយខ្វះការ ត្រួតពិនិត្យទៅតាមច្បាប់ ការកាប់រានហ៊ុំពទ្ធ័ដីព្រៃធ្វើកម្មសិទ្ធិ ការផ្តល់សម្បទានព្រៃគប់ ការផ្តល់សម្បទានដីដល់ ក្រុមហ៊ុនដើម្បីធ្វើការឈូសឆាយដីព្រៃឈើធម្មជាតិធ្វើចំការឧស្សាហកម្ម ។ល។ រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងធ្វើ កំណែទំរង់លើវិសយ័ព្រៃឈើដោយបង្កើតច្បាប់ព្រៃឈើ អនុក្រិត្យ លិខិតបទដ្ឋាននានា រៀបចំស្ថាបន័ជំនាញ ដោយ លើកស្ទួយឱ្យបង្កើតសហគមន៍ព្រៃឈើដើម្បីធានានូវការការពារ និងគ្រប់គ្រងព្រៃឈើឱ្យមាន និរន្តរភាព។ ដោយការ អនុវត្តច្បាប់ទន់ខ្សោយ អំពើពុករលួយធ្វើឱ្យព្រៃឈើនៅតែ រងនូវការបំផ្លិចបំផ្លាញដដែល ទោះបីជាសហគមន៍ខិតខំ ព្យាយាមទប់ ស្កាត់រាល់បទល្មើសព្រៃឈើទាំងនេះ ជាទូទៅមិនត្រូវបានអាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋានគាំទ្រនោះទេ ហើយសហគមន៍តែងតែរងនូវការ គំរាមកំហែងពីអ្នកប្រព្រឹត្តបទល្មើស និងចោទប្រកាន់ដោយតុលាការក្នុងការការពារ ធនធានធម្មជាតិរបស់ខ្លួន និងទ្រព្យសម្បត្តិរបស់ប្រទេសជាតិទៅវិញ ។

តាមខ្លឹមសារក្នុងឯកសារនៃកម្មវិធីព្រៃឈើជាតិ និងតាមរយៈការធ្វើបទបង្ហាញរបស់វាគ្មិនក្នុងសិក្ខាសាលា នេះបានធ្វើឱ្យយើងខ្ញុំ មានក្តីសង្ឃឹមសារជាថ្មីថាព្រៃឈើនៅកម្ពុជាកំពុងតែរដ្ឋាភិបាល ជាពិសេស រដ្ឋបាលព្រៃឈើបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារ និងស្តារព្រៃឈើដែលបានបាត់បង់ ឡើងវិញក្នុង

គោលបំណងរួមចំណែក កាត់បន្ថយភាពក្រីក្រដោយបង្កើតកម្មវិធីព្រៃឈើជាតិនេះឡើង ។ ក្នុងនាមយើងខ្ញុំជាសហគមន៍ដែលរស់អាស្រយ័ ផលលើព្រៃឈើមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ចំពោះការយកចិត្តទុកដាក់ខ្ពស់របស់ថ្នាក់ដឹកនាំ បើទោះបីជា អត្ថនយ័ក្នុងកម្មវិធីនេះស្ថិតនៅជាពង្រាងក៏ដោយក៏មានគោលការណ៍ជាច្រើនបាន លើកកំពស់ការគាំទ្រឱ្យមាន សហគមន៍ព្រៃឈើទាំងការថែរក្សាប្រើប្រាស់ជាពិសេសតម្រូវឱ្យអាជ្ញាធរ និង សមត្ថកិច្ចជំនាញជួយគាំទ្រផងដែរ។ ជាងនេះទៅទៀតក្នុងដំណើរការពិគ្រោះយោបល់លើកម្មវិធីព្រៃឈើជាតិបានផ្តល់ឱកាសដល់សហគមន៍ចូលរួម បញ្ចេញគំនិតយោបល់ និង លើកពីតម្រូវការរបស់ខ្លួនដាក់បញ្ចូលក្នុងកម្មវិធីនេះ ទោះបីជាសមាសសភាព សហគមន៍មានចំនួនតិចក៏ដោយក៏ជាសក្ខីភាពមួយ ពីការយក ចិត្តទុកដាក់របស់ថ្នាក់ដឹកនាំមកដល់ការរស់នៅរបស់ ប្រជាពលរដ្ឋហើយពេលក្រោយយើងសង្ឃឹមថានឹងអនុញ្ញាតឱ្យមានសម្លេងសហគមន៍បានចូលរួមក្នុងការពិគ្រោះ កាន់តែច្រើន។

ដូច្នេះដើម្បីធានាឱ្យការអនុវត្តកម្មវិធីព្រៃឈើមាននិរន្តរភាពចំពោះការគ្រប់គ្រង និងសំរេចបានតាមទិសដៅ របស់រាជរដ្ឋាភិបាល និងដើម្បីជៀសវាងកុំឱ្យ ការខិតខំការជួយការពារព្រៃឈើ និងទប់ស្កាត់បទល្មើសរបស់សហគមន៍ មិនត្រូវបានគេទទួលស្គាល់ សហគមន៍យើង ខ្ញុំសូមលើកនូវសំណូមពរដូចខាងក្រោមៈ

១- សុំឱ្យមានសមាសភាពសហគមន៍ក្នុងក្រុមការងារព្រៃឈើជាតិតាមតំបន់ពាក់ពន្ធ័
២- សុំកុំទាន់បញ្ចូលកម្មវិធីវិនិយោគលើការផ្តល់សម្បទាន ការធ្វើអាជីវកម្មក្នុងកម្មវិធីព្រៃឈើ
៣- សុំរៀបចំការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើតែក្នុងប្រទេស ជាជាងការជុំរុញឱ្យមានការ ធ្វើអាជីវកម្មទៅក្រៅប្រទេស
៤- សុំឱ្យមានការពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាងនេះទៀតមុននិងអនុមត័កម្មវិធីព្រៃឈើ
៥- គាំទ្រសហគមន៍ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើតាមតំបន់ និងមូលដ្ឋាន
៦- គាំទ្រដល់សហគមន៍ក្នុងការគ្រប់គ្រង ប្រើប្រាស់ព្រៃឈើជាទ្រង់ទ្រាយធំដូចពីជំនាន់មុនក្នុងភាពជាម្ចាស់ និង មានសិទ្ធិគ្រប់គ្រាន់
៧- សុំឱ្យកាត់បន្ថយទំហំដី និងរយៈពេលកុងត្រាសម្បទានដែលបានផ្តល់ហើយ និងបញ្ឈប់ការផ្តល់ដី សម្បទានបន្ត ទៀតសំរាប់អនាគត
៨- ដីព្រៃដែលធ្វើសម្បទានរួចហើយមានផលប៉ះពាល់ដល់បិស្ថាន និងផលប្រយោជន៍សហគមន៍មូលដ្ឋានសូមលប់កិច្ចព្រមព្រៀងនោះចោល ហើយផ្តល់ដីនិងព្រៃទាំងនោះអោយសហគមន៍គ្រប់គ្រង ប្រើប្រាស់វិញ
៩- សុំរៀបចំផែនការប្រើប្រាស់ដីធ្លីរបស់សហគមន៍ មុននឹងធ្វើការកំណត់ព្រំប្រទល់ព្រៃឈើ
១០- ព្រៃឈើដែលរក្សាទុកជាង៦០ភាគរយសុំរក្សាព្រៃធម្មជាតិ មិនមែនជាឈើឧស្សាហកម្ម

យើងខ្ញុំសូមទទូចដល់ក្រុមការងារដែលរៀបចំកម្មវិធីព្រៃឈើជាតិ មេត្តាយកសំណូមពរសហគមន៍ យើងខ្ញុំដាក់បញ្ចូលក្នុងកម្ម វិធីព្រៃឈើជាតិនេះផង ។ក្នុងនាមយើងខ្ញុំជាសហគមន៍ដែលរស់ពឹងផ្អែកលើធនធាន ធម្មជាតិចង់ឃើញការសហការមួយយ៉ាងពេញលេញ រវាងអាជ្ញាធរ ស្ថាប័ន ពាក់ពន្ធ័គ្រប់លំដាប់ថ្នាក់ដើម្បី ធ្វើឱ្យប្រទេសកម្ពុជាយើងឈានទៅរកប្រទេសនិតិរដ្ឋ គោរពសិទ្ធិ មនុស្សឱ្យកាន់តែល្អប្រសើរ ជាពិសេសចង់ឃើញការអនុវត្តកម្មវិធីព្រៃឈើជាតិប្រកបដោយប្រសិទ្ធភាព និងបំរើផល ប្រយោជន៍ សហគមន៍ពិតប្រាកដ ហើយធានាបាននូវការការពារប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាពស្របទៅ តាមទស្សនៈវិស័យកម្មវិធី ។ជាថ្មីម្តងទៀតសហគមន៍យើងខ្ញុំសូមឱ្យមានការ ទទួលស្គាល់សិទ្ធិពេញលេញ ក្នុងការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើ ដីធ្លី ធនធានធម្មជាតិផ្សេងៗតាមបែបប្រពៃណីក្នុង តំបន់របស់ខ្លួនដូចពីជំនាន់មុន និងមានការគាំទ្រ ខ្ពស់ពីអាជ្ញាធរ សមត្ថកិច្ចគ្រប់ស្ថាប័ន និងអ្នកពាក់ពន្ធ័ ។

ជាទីបញ្ចប់នៃសេចក្តីថ្លែងការណ៏របស់សហគមន៍ខ្ញុំ្រ ពះករុណាខ្ញុំសូមប្រគេន និងជូនពរដល់ព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អង្គការជាតិ អន្តរជាតិដែលមានវត្តមាននៅទីនេះ ជាពិសេសក្រុម ការងាររៀបចំកម្មវិធីព្រៃឈើជាតិសូមប្រទះ តែ សិរីសួស្តី ជយ័មង្គល វិបុលសុខ មហាប្រសើរ និងទទួលបានជយ័ជំនះ រាល់ភារកិច្ច ។

កំពង់ចាមថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩
សូមអរព្រះគុណ និងសូមអរគុណ

**ឧបសម្ព័ន្ធ១៣:** របាយការណ៍បូកសរុបលទ្ធផលសិក្ខាសាលារបស់លោក ហ៊ុន-អៀង នាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម

# របាយការណ៍

# ស្តីពី

# ការបូកសរុបលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ

**សណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម, ថ្ងៃទី ០៤-០៥ ខែ មិថុនា ឆ្នាំ ២០០៩**

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សូមគោរពឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ជាទីគោរព
-សូមគោរព ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និង អន្តរជាតិទាំងអស់ជាទីមេត្រី

តាងនាមអង្គសិក្ខាសាលានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវមនោសញ្ចេតនា និង អរគុណជាអនេកចំពោះវត្តមាន របស់ ឯកឧត្តម **ជា សំអាង** អនុប្រធានរដ្ឋបាលព្រៃឈើ ឯកឧត្តម អស់លោក លោកស្រីតំណាងក្រសួង មន្ទីរ ស្ថាប័ន អង្គភាព អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សារពតិមាន ព្រះសង្ឃ និងសហគមន៍ ព្រៃឈើ និងរដ្ឋបាលព្រៃឈើ ដែលបានអញ្ជើញចូលរួមក្នុងពិធី **បូកសរុបលទ្ធផលពិគ្រោះយោបល់ជាសាធារណៈលើសេចក្តី ព្រាងកម្មវិធីព្រៃឈើជាតិ** នារសៀលនេះ ដែលញ៉ាំងឱ្យពិធីនេះមានសភាពអធិកអធមប្រកបដោយ កិត្តិយសដ៏ខ្ពង់ខ្ពស់ និងស បញ្ជាក់អំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជានិច្ចជាកាល តែងតែគាំទ្រសហការយ៉ាងជិតស្និត និងអនុវត្តយ៉ាងយកចិត្តទុកដាក់លើកម្មវិធីកំណែទំរង់វិស័យព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ និងម៉ឺងម៉ាត់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ។

***ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ***

***គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព***

ជាមួយសេចក្តីគោរពស្វាគមន៍ដ៏កក់ក្តៅនេះ ខ្ញុំព្រះកុរណាខ្ញុំបាទសូមអនុញ្ញាតទូលប្រគេន និង រាយការណ៍ដោយសង្ខេប ជូនព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា និងអង្គពិធីទាំងមូល អំពីដំណើរការនិង លទ្ធផលនៃការ ពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ក្នុងរយៈពេល២ថ្ងៃ កន្លងមកនេះមានដូចតទៅ :

អង្គសិក្ខាសាលាបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៤ ដល់ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៩ នៅសណ្ឋាគារភ្នំប្រុស ខេត្ត កំពង់ចាម ដែលមានអ្នកចូលរួមអញ្ជើញមកពីខេត្ត កំពត កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង កោះកុង កំពង់ធំ បន្ទាយមានជ័យ និងកំពង់ចាម ព្រមទាំងមានការចូលរួមពីតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងចំនួន ១៣ រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានទូរទស្សន៍ជាតិ មន្ទីរ-អង្គភាពពាក់ពន្ធ័ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សារពត៌មាន ព្រះសង្ឃ និងសហគមន៍ព្រៃឈើ សរុបចំនួន ១៦១ នាក់។

សិក្ខាសាលានេះមានការអញ្ជើញចូលរួមអធិបតី និង ថ្លែងសុន្ទរកថាស្វាគមន៍ដោយឯកឧត្តម ម៉េង សួន អភិបាលរង ខេត្តកំពង់ចាម និងថ្លែងសុន្ទរកថាបើកដោយឯកឧត្តម ទី សុគន្ធ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ។

អង្គសិក្ខាសាលាបានធ្វើបទបង្ហាញអំពីសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ហើយក៏បានធ្វើការពិភាក្សា ផ្តល់មតិដើម្បី កែលំអ កំណត់នូវទិសដៅយុទ្ធសាស្ត្រ និងផែនការសកម្មភាព សំរាប់អនុវត្ត ការងារក្នុងវិស័យព្រៃឈើ ឱ្យស្របតាមគោល នយោបាយវិស័យព្រៃឈើជាតិ ច្បាប់ស្តីពីព្រៃឈើ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា និង យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សូចនាករតាមដានរួមស្តីពីកំណែ ទំរង់ព្រៃឈើ ដើម្បីឈានឆ្ពោះដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនេះ នៅថ្ងៃទី ១ ត្រូវនឹងថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ អង្គសិក្ខាសាលាក៏បានធ្វើបទបង្ហាញចំនួន ៥ មានដូចតទៅ :

១- គោលបំណង និង លទ្ធផលរំពឹងទុកពីសិក្ខាសាលា

២- ដំណើរការអភិវឌ្ឍកម្មវិធីព្រៃឈើជាតិ

៣-ឯកសារក្របខណ្ឌយុទ្ធសាស្ត្រ

៤-កម្មវិធីទី ១ ដល់កម្មវិធីទី ៥

៥-កម្មវិធីស្តីពីហិរញ្ញប្បទាន ដើម្បីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

នៅវេលារសៀលថ្ងៃដដែល សិក្ខាកាមបានលើកឡើងជាសំនួរប្រកបដោយខ្លឹមសារ និងអត្ថន័យ ហើយត្រូវបានបក ស្រាយដោយវាគ្មិនសំខាន់ៗដែលជាអ្នករៀបចំកម្មវិធីព្រៃឈើជាតិនេះឡើង ព្រមទាំងបាន ផ្តល់នូវសំណូមពរមួយចំនួន ដល់អង្គ សិក្ខាសាលាទាំងមូល ។ សំនួរសំខាន់ៗដែលបានលើកឡើងរួមមាន :

-តើអភិបាលកិច្ចព្រៃឈើវាមានអត្ថន័យដូចគ្នា ឬខុសគ្នាជាមួយនឹងពាក្យថា ការការពារ និងអភិរក្សព្រៃឈើ? ហើយដំណើរការវាមានដូចម្តេចខ្លះ?

-តើអ្នកណាខ្លះជាអ្នកធ្វើ ឬអ្នកអនុវត្តផ្ទាល់នូវការគ្រប់គ្រង និងអភិរក្សព្រៃឈើ?

-តើយើងមានឯកសារបង្អែកគ្រប់គ្រាន់រឹងមាំហើយឬនៅ?

-តើការបើកចំហដល់សាធារណៈជនចំពោះតារាងគណនេយ្យប្រចាំឆ្នាំដែលមានកត់ត្រាលំអិតអាចធ្វើបានដែរឬទេ?

-កម្មវិធីព្រៃឈើជាតិធ្វើតែក្នុងដែនសមត្ថកិច្ចរដ្ឋបាលព្រៃឈើ មិនបានរួមបញ្ចូលនូវតំបន់ការពារ តើការគ្រប់គ្រង ព្រៃឈើអាចមាននិរន្តរភាពដែរឬទេ?

-តើការគ្រប់គ្រង និងអភិរក្សជីវៈចំរុះអាចសំរេចបានតាមរបៀបណា ប្រសិនបើការផ្តល់ផ្ទៃដីសម្បទានមានចំនួនច្រើន?

-ការអភិវឌ្ឍន៏វិស័យរ៉ែធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៏កម្មវិធីព្រៃឈើជាតិ តើគួរមានដំណោះស្រាយរបៀបណា ឬដាក់ បញ្ចូលទៅក្នុងកម្មវិធីព្រៃឈើជាតិដែរឬទេ?

អង្គសិក្ខាសាលាក៏បានផ្តល់នូវសំណូមពរ និងអនុសាសន៏មួយចំនួនផងដែរដូចជា :

-កម្មវិធីព្រៃឈើជាតិមានរយៈពេល ២០ឆ្នាំ មិនស៊ីសង្វាក់គ្នាជាមួយផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គមដែលមានរយៈ ពេលតែ១៥ឆ្នាំប៉ុណ្ណោះ និងផែនការការអនុវត្ត ៥ឆ្នាំម្តង។

-ចំពោះបទបង្ហាញដែលសរសេរថា រដ្ឋបាលព្រៃឈើរកចំណូល ក្នុងនាមអង្គភាពរបស់រដ្ឋមិនអាចធ្វើបែបនេះបានទេ លុះត្រាតែប្រែក្លាយជា សហគ្រាសសាធារណៈរបស់រដ្ឋ ដែលមានស្វ័យភាពថវិកា។

គួរពិចារណានិងដាក់បញ្ចូលបន្ថែមនូវបញ្ហាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ឈើថាមពលដោយស្របច្បាប់។

-គួរកំណត់ថវិកាសំរាប់កម្មវិធីស្តីពីការពង្រឹងសមត្ថភាព និងអភិវឌ្ឍការងារស្រាវជ្រាវ ឱ្យដល់១០% នៃថវិកាសរុប ពោលគឺស្មើនឹង ១០លានដុល្លារអាមេរិក។

សិក្ខាសាលាបានធ្វើការបែងចែកជាក្រុមពិភាក្សាចំនួន ៤ ដែលក្រុមទី១ មានសមាជិកចំនួន ៣៦ នាក់ ក្រុមទី២ មានសមាជិកចំនួន ៤២ នាក់ ក្រុមទី៣ មានសមាជិកចំនួន ១៥ នាក់ ក្រុមទី ៤ មានសមាជិកចំនួន ១៥ នាក់ ។ ក្រុមពិភាក្សា ទី១ និង ទី២ រួមគ្នាពិភាក្សាលើប្រធានបទស្តីពី ឯកសារក្របខណ្ឌយុទ្ធសាស្ត្រកម្មវិធីព្រៃឈើជាតិ ដែលមានសំនួរពិភាក្សា ដូចតទៅ :

- តើអ្វីដែលជាឧបសគ្គចំបង រាំងស្ទះដល់ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ហើយថាតើគួរធ្វើយ៉ាងណាដើម្បី ដោះស្រាយបញ្ហាទាំងនេះ?
- ព្រៃឈើកំពុងរងការគំរាមកំហែងពីការចាប់រំលោភយកដីព្រៃ ។ តើព្រៃឈើគួរត្រូវបានគ្រប់គ្រងបែបណាឱ្យ ប្រសើរជាងនេះ?
- វិធីមួយក្នុងការបង្កើនប្រាក់ចំណូលពីព្រៃឈើ គឺការប្រមូលថ្លៃសួយសារសេវាកម្មបរិស្ថាន (អ្នកក្រុងបង់លុយ សំរាប់ប្រើប្រាស់ទឹកស្អាតពីព្រៃឈើ ។ តើប្រទេសកម្ពុជាអាចធ្វើបែបនេះបានឬទេ ? បើបាន តើពេលណា ហើយគួរធ្វើយ៉ាងដូចម្តេច ?

- តើអ្នកអាចស្នើជាយន្តការសំរាប់ការបែងចែកផលប្រយោជន៍ពីព្រៃឈើដោយសមធម៌បានទេ (រវាងរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងក្រុមហ៊ុន)?

- តើកិច្ចការអ្វីខ្លះដែលត្រូវធ្វើក្នុងវិស័យសិក្សាធិការ ពិសេសលើមុខវិជ្ជាការគ្រប់គ្រងធនធានធម្មជាតិ ដើម្បី គាំទ្រដល់គោលដៅនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ?

ក្រុមទី៣ និង ទី៤ បានរួមគ្នាពិភាក្សាលើប្រធានបទស្តីពី កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ ដែលមានសំណួរ ពិភាក្សាដូចតទៅ :

-ការគណនាដំបូងបានប៉ាន់ប្រមាណឃើញនូវចំនួនថវិកាសំរាប់អនុវត្តកម្មវិធីទាំងប្រាំដូច ខាងក្រោម តើអ្នក យល់ឃើញយ៉ាងណា ? ការបោះបង្គោល ៥៣.៦លានដុល្លារ , ការគ្រប់គ្រង និងអភិរក្ស ការចំណាយសំរាប់ កម្មវិធី ៦លានដុល្លារ , ពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ១ លានដុល្លារ , សហគមន៍ព្រៃឈើ ៧.២ លានដុល្លារ និងការពង្រឹងសមត្ថភាពស្រាវជ្រាវ ២.៨ លានដុល្លារ ។

-តើក្នុងការងារអាទិភាពអ្វីខ្លះ ដែលអ្នកចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើដើម្បី : (ក) ប្រមូលប្រាក់ ចំណូលពីអាជីវកម្មឈើមូល ដែលគ្រប់គ្រងដោយរដ្ឋាភិបាល (ខ) ការបណ្តាក់ទុនទៅក្នុង និងការប្រមូលប្រាក់ ពីការលក់កាបោនព្រៃឈើក្រោមយន្តការ REDD (គ) បណ្តាក់ទុន និងប្រមូលប្រាក់ចំណូលពីសម្បទានបែប អភិរក្ស ។

-តើមានវិធីសាស្ត្រអ្វីខ្លះដើម្បីជំរុញឱ្យមានប្រសិទ្ធិភាពលើ ការបោះបង្គោលព្រំ ការសិក្សា ស្រាវជ្រាវ ការដាំដុះ ថ្នាលបណ្តុះកូនឈើ ដោយមានការត្រួតពិនិត្យដោយស្ថាប័នឯករាជ្យ ។

ឆ្លងតាមរយៈការពិភាក្សាផ្លាស់ប្តូរយោបល់គ្នាយ៉ាងល្អិតល្អន់លើសំណួរ ដែលបានលើកឡើង ខាងលើក្នុងក្រុមពិភាក្សា និមួយៗ រយៈពេល ១ ថ្ងៃ រួចមកយើងទទួលបានលទ្ធផលដូចខាងក្រោម :

## ១-ឯកសារក្របខណ្ឌយុទ្ធសាស្ត្រ

### ❖ ចំណុចខ្សោយ :

-ការអនុវត្តច្បាប់ មិនទាន់មានប្រសិទ្ធិភាព

-ការចូលរួមពីស្ថាប័នពាក់ព័ន្ធនៅមានកំរិត

-ការវិនិយោគទុនមិនទាន់ធ្វើឱ្យអស់លទ្ធភាព និងមិនទាន់គោរពកិច្ចព្រមព្រៀងឱ្យបានពេញលេញនៅឡើយ

-ការយល់ដឹងរបស់ប្រជាជននៅមានកំរិត

-មិនទាន់មានច្បាប់គ្រប់គ្រាន់ ហើយនៅតែមាន អ្នករុករានដីព្រៃច្រើន

-មិនទាន់មានភាពច្បាស់អំពីសមត្ថកិច្ច រវាងរដ្ឋបាលព្រៃឈើនិងបរិស្ថាន

-ដីព្រៃឈើមិនបានកំណត់ និងចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋនៅឡើយ

-ខ្វះសមត្ថភាពក្នុងការរៀបចំការគ្រប់គ្រងសហគមន៍ព្រៃឈើ

-ខ្វះការលើកទឹកចិត្តដល់មន្ត្រីជំនាញក្នុងការបំពេញការងារ

-ការមិនបានបន្សុីគ្នា រវាងច្បាប់ព្រៃឈើ និងច្បាប់តំបន់ការពារ

-មិនមានការវិនិយោគដើម្បីការពារព្រៃឈើ មានតែការវិនិយោគដើម្បី បំប្លែងព្រៃឈើ និងមិនមានគោលដៅ ច្បាស់លាស់

-មិនមានកម្មវិធីព្រៃឈើជាតិ សំរាប់អនុវត្តនៅឡើយ

-ភាពក្រីក្ររបស់ប្រជាជនមូលដ្ឋាននៅមានច្រើន

-មិនមានការកំណត់មុខងារព្រៃឈើឱ្យបានច្បាស់ ដើម្បីងាយស្រួលក្នុង ការធ្វើផែនការគ្រប់គ្រង

-នៅមានការប្រើប្រាស់ថាមពលពីព្រៃឈើច្រើន

-មិនមានការព្រមព្រៀងគ្នា លើយន្តការគ្រប់គ្រង រវាងគ្រប់ភាគីពាក់ព័ន្ធ

-ប្រជាជនខ្វះដីធ្វើស្រែចំការ និង ដីសំរាប់លំនៅដ្ឋាន និងការធ្វើអាជីវកម្មរ៉ែខុសច្បាប់

-ខ្វះថវិកា និងមធ្យោបាយ ដើម្បីអនុវត្តផែនការ

-ទីផ្សារដីមានតំលៃខ្ពស់

### ❖ ដំណោះស្រាយ :

-បង្កើនការបង្កើតសហគមន៍ព្រៃឈើ

-កសាងសមត្ថភាពជំនាញដល់អ្នកគ្រប់គ្រងសហគមន៍ព្រៃឈើ

-ស្វែងរកថវិកាឱ្យបានតាមផែនការគ្រោងទុក

-ពង្រឹងការអនុវត្តច្បាប់ព្រៃឈើឱ្យមានប្រសិទ្ធិភាព និងមានការចូលរួមត្រួតពិនិត្យពីអជ្ញាធរមូលដ្ឋាន

-ផែនការគ្រប់គ្រងនេះគួរផ្អែកលើច្បាប់ព្រៃឈើ និងច្បាប់តំបន់ការពារ

-បង្កើនការអប់រំនិងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ

-គួរកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ យកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន

-ត្រូវមានបង្គោលព្រំប្រទល់ច្បាស់លាស់

-ការផ្តល់ឱ្យនូវដីសម្បទានដល់ក្រុមហ៊ុនណាមួយ គួរមានការព្រមព្រៀងពីប្រជាជនមូលដ្ឋាន

-ជំនួសការប្រើប្រាស់ថាមពលព្រៃឈើ ជាថាមពលរ៉ែ ធ្យូង ហ្គាស អគ្គិសនី

-គាំទ្រសហគមន៍ការពារព្រៃឈើ ជាបណ្ដាញក្នុងតំបន់ព្រៃធំៗ

-មានវិធានការតាមផ្លូវច្បាប់ចំពោះបុគ្គលដែលរំលោភដីព្រៃ និងជ្រកក្រោមរូបភាពអភិវឌ្ឍន៍

-ធ្វើចំណាត់ថ្នាក់ដីធ្លីឱ្យបានច្បាស់លាស់

-បង្កើនប្រាក់ចំណូលរបស់ប្រជាជន ឱ្យស្របនឹងច្បាប់

-ជំរុញការផ្សព្វផ្សាយច្បាប់ ឱ្យបានទូលំទូលាយ

-បោះព្រំប្រទល់ និងដាក់ផ្លាកសំគាល់ដីព្រៃឈើឱ្យបានច្បាស់លាស់

-ព្រៃឈើគួរគ្រប់គ្រងតាមប្រព័ន្ធច្បាប់ដ៏តឹងរ៉ឹងបំផុតមួយ

-រដ្ឋអំណាចត្រូវទប់ស្កាត់ មិនត្រូវធ្វើលិខិតកាន់កាប់ដីរដ្ឋ ឱ្យជាកម្មសិទ្ធិបានទេ

-ពង្រឹងការត្រួតពិនិត្យបទល្មើស និង ពង្រឹងសហគមន៍មូលដ្ឋាន ក្នុងការការពារព្រៃឈើ

-បង្កើនកិច្ចសហការ រវាងស្ថាបនពាក់ព័ន្ធ ដើម្បីពង្រឹងកិច្ចការពារព្រៃឈើ

-គួរឱ្យភ្នាក់ងាររដ្ឋបាលព្រៃឈើ បោះទីតាំងនៅក្បែរដែនព្រៃ និងចុះត្រួតពិនិត្យជាប្រចាំ

-គួរកំណត់យកពន្ធលើឧស្សាហកម្ម ដែលប៉ះពាល់ដល់បរិស្ថាន ហើយបង្វិលថវិកានេះទៅគាំទ្រដល់សហគមន៍ព្រៃឈើ

-សេវាកម្មបរិស្ថានពីព្រៃឈើ ឧទាហរណ៍ ទឹកអាចបង់ពន្ធសួយសារសេវាកម្មបាន នៅពេលដែលប្រជាជនមានប្រាក់ ចំណូលច្រើនជាងពេលនេះ

-អ្នកធ្វើអាជីវកម្មទឹក គួរត្រូវបង់សួយសារឱ្យវិស័យព្រៃឈើ

### ❖ការគ្រប់គ្រងព្រៃឈើឱ្យបានល្អប្រសើរ ដើម្បីទប់ស្កាត់ការចាប់រំលោភយកដីព្រៃ :

-កំណត់ព្រំអោយបានច្បាស់លាស់។

-ចុះបញ្ជីការអោយបានត្រឹមត្រូវ។

-ផ្សព្វផ្សាយច្បាប់ព្រៃឈើ។

-ត្រួតពិនិត្យឱ្យបានជាប់ជាប្រចាំ។

-អប់រំ ដាក់ពិន័យ និងផ្ដន្ទាទោសតាមច្បាប់។

-លើកសរសើរដល់មន្ត្រីដែលអនុវត្តល្អ។

-តុលាការត្រូវកាត់ក្ដី អោយទាន់ពេល និងយុត្តិធម៌។

-គ្រប់គ្រងតាមរយៈសហគមន៍មូលដ្ឋាន។

-ទប់ស្កាត់ និងហាមឃាត់ការរំលោភយកដីព្រៃ។

-ពង្រឹងការអនុវត្តច្បាប់ ។

-ស្រង់ពត៌មានពីអ្នកអត់ដី ។

-មានការយាមល្បាតនៅតាមតំបន់ព្រៃ ។

-មានការបណ្តុះបណ្តាលសំរាប់ការរកប្រាក់ចំណូល ។

-កុំអោយក្រុមហ៊ុនរំលោភលើច្បាប់ស្តីពីព្រៃឈើ ។

-ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ។

-ជំរុញអោយមហាជនទប់ស្កាត់បទល្មើសព្រៃឈើ ។

-មានកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ។

-ស្រង់ឈ្មោះអ្នកកាប់រានដីព្រៃហើយអោយគាត់បញ្ឈប់សកម្មភាពទាំងនេះ

-រីឯដីដែលកាប់រានត្រូវដកហូតជាសម្បត្តិរដ្ឋ ។

-ដីដកហូតបានត្រូវដាំដើមឈើឡើងវិញ ។

-បង្កើតសហគមន៍ព្រៃឈើ ។

-លុបបំបាត់ព្រៃសម្បទាន និងបង្កើតព្រៃអភិរក្សឡើងវិញ ។

-តាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ច ។

-អ្នកមានប្រាក់ និងមានអំណាចត្រូវចូលរួមក្នុងការគ្រប់គ្រងព្រៃ ។

-តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័តមាន ។

-តាមរយៈការបញ្ចូលខ្លឹមសារខាងលើ ក្នុងកម្មវិធីសិក្សា ។

**❖លទ្ធភាពនៃការបង្កើនប្រាក់ចំណូល តាមរយៈការប្រមូលថ្លៃសួយសារពី សេវាកម្មបរិស្ថានរបស់ព្រៃឈើនៅ ប្រទេសកម្ពុជា (អ្នកត្រូវបង់លុយសំរាប់ប្រើប្រាស់ទឹកស្អាតពីព្រៃឈើ) : គឺអាចធ្វើបានដោយ :**

-ការផ្សព្វផ្សាយច្បាប់ដែលទាក់ទងនឹងថ្លៃសួយសារសេវាកម្មបរិស្ថាន ។

-អប់រំប្រជាពលរដ្ឋអោយយល់ដឹងពីផលប្រយោជន៍ព្រៃឈើ ។

-បញ្ចូលការបង់ប្រាក់ទៅក្នុងវិក័យប័ត្រអគ្គិសនី ។

-ដកហូតពីក្រុមហ៊ុនធ្វើអាជីវកម្ម ។

-បង្កើតច្បាប់ស្តីពីការប្រើប្រាស់សេវាកម្មព្រៃឈើ ។

-ត្រូវសិក្សាពីចំណូលចិត្តអ្នកប្រើប្រាស់និងរៀបចំយន្តការក្នុងការបង់សេវាកម្ម ។

-កំណត់ការបង់ក្នុងកំរិតទាប តែមានតម្លាភាព ។

-បើមិនមានការបំផ្លាញព្រៃឈើពីប្រជាជន និងអ្នកមានអំណាច ។

-ប្រជាជនចេះគោរពច្បាប់ ។

-មានច្បាប់ និងនាំគ្នាគោរពច្បាប់ ។

-អ្នកគ្រប់គ្រងប្រភពនិយ័តភាពទឹកត្រូវបង់ប្រាក់អោយអ្នកប្រើប្រាស់ទឹក តាមរយៈរដ្ឋាករទឹក ។

❖ការស្នើនូវយន្តការសំរាប់ការបែងចែកផលប្រយោជន៍ពីព្រៃឈើដោយសមធម៌ (រវាងរដ្ឋាភិបាល សហគមន៍ វិស័យឯកជន) : គឺអាចធ្វើបានដោយ :

-វិស័យឯកជនត្រូវបង់ថ្លៃសួយសារជូនរដ្ឋ ហើយរដ្ឋផ្តល់ឱកាសអោយឯកជនធ្វើការអភិវឌ្ឍន៍តាមគោលការណ៍ និរន្តរភាព ។

-ត្រូវអោយសហគមន៍ច្រើនជាង ព្រោះសហគមន៍ជាម្ចាស់

-សហគមន៍ទទួលផលប្រយោជន៍ តាមគោលការណ៍របស់រដ្ឋ ហើយក្រុមហ៊ុន ទទួលផលតាម កិច្ចសន្យាថែរក្សា ការពារព្រៃឈើ ។

-ពិនិត្យលើការចូលរួមលើការថែរក្សាព្រៃឈើរបស់សហគមន៍ ។

-បែងចែកផលប្រយោជន៍ ដោយមាន ការចូលរួម និងមានការឯកភាព

-គួរសំរបសំរួលរវាងអ្នកពាក់ព័ន្ធ ឬ ធ្វើការបែងចែកអោយបានច្បាស់លាស់

-រដ្ឋាភិបាលគ្រប់គ្រងនិងដកហូតពន្ធ ។ សហគមន៍គ្រប់គ្រង និងដកហូតផលប្រយោជន៍ ។

-ក្រុមហ៊ុនគ្រប់គ្រង ដកហូតផលចំណេញ ។

-គួរអនុវត្តតាមភាគ ផលដែលទទួលបាន ។

-ក្រុមហ៊ុនធ្វើវារីអគ្គិសនីត្រូវបង់ថ្លៃការការពារ អោយអ្នក ប្រើប្រាស់ព.ឈ ។

-ចំណូលបានពីព្រៃឈើត្រូវគិតជាភាគរយណាមួយ អោយសហគមន៍ ។

❖កិច្ចការដែលត្រូវធ្វើក្នុងវិស័យសិក្សាធិការ លើមុខវិជ្ជា ការគ្រប់គ្រងធនធានធម្មជាតិ :

-បញ្ចូលមុខវិជ្ជាគ្រប់គ្រង ធនធានធម្មជាតិ ក្នុងកម្មវិធីអប់រំ ។

-គ្រប់គ្រង អភិរក្សព្រៃឈើ និងបញ្ចូលកម្មវិធិព្រៃឈើជាតិក្នុងកម្មវិធីអប់រំ ។

-បញ្ចូលច្បាប់ព្រៃឈើក្នុងកម្មវិធីអប់រំ ។

**២_កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ**

(ក) ត្រូវធ្វើការចាត់អាទិភាពកម្មវិធីនីមួយៗតាមរយៈ

-ពង្រឹងការអនុវត្តន៍ច្បាប់ ។

-ការកាត់បន្ថយភាពក្រីក្រគឺជាការងារអាទិភាព និងបន្ទាន់ ។

(ខ) -ទឹកប្រាក់ចំនួន ៧០,៦ លាន ដុល្លាសហរដ្ឋអាមេរិកនៅក្នុងរយៈពេល ១២ ឆ្នាំ គួរធ្វើការបែងចែកចំណាយឱ្យ បានសមស្របតាមកម្មវិធីនីមួយៗ ។

(គ) -ត្រូវសិក្សាលើតម្រូវការជាក់ស្តែងតាមកម្មវិធីនីមួយៗ ទើបដឹងពីការចំណាយជាក់លាក់ ពិសេសគឺផែនការ សកម្មភាព ។

(ឃ) -អន្តរអំពើរវាងកម្មវិធីនីមួយៗនៅក្នុងកម្មវិធីព្រៃឈើជាតិ : ចុះបង្ក្រាបបទល្មើសត្រូវការកម្មវិធីទី ៣ជាអ្នកជួយអន្តរាគមន៍ ។

❖ **ការខ្វះអធិការពាដែលចង់ឱ្យរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើគឺ :**

(ក) ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងវិស័យព្រៃឈើឱ្យបានល្អ(ផែនការអាជីវកម្ម លទ្ធកម្មការត្រួតពិនិត្យ និងការវាយតំលៃ):

-រៀបចំនិង វិភាគផែនការប្រើប្រាស់ឈើក្នុងស្រុក ដែលសមស្រប

-នីតិវិធីរដ្ឋបាលឱ្យខ្លី

-តំលៃពន្ធ និងសេវា មេត្តាពិនិត្យឡើងវិញ ថាសមស្រប ឬអត់

-ពង្រឹកការអនុវត្តន៍ច្បាប់

(ខ) ការបណ្តាក់ទុនទៅក្នុង និងការប្រមូលប្រាក់ចំណូលពីការលក់កាបោនព្រៃឈើក្រោម យន្តការ **REDD** :

-ប្រាក់ដែលបានលក់ ត្រូវពិចារណាពីការជួយដល់សហគមន៍បានចំនួនប៉ុន្មានក្នុងក៏រិតណានោះ ។

-ធ្វើការផ្សព្វផ្សាយពីផលប្រយោជន៍ពី REDD ពីតំលៃរបស់វា ។

(គ) ការបណ្តាក់ទុន និងប្រមូលប្រាក់ចំណូលពីសម្បទានបែបអភិរក្ស គឺវាមានចំនួន ២ ប្រភេទ :

-ការបណ្តាក់ទុន ដោយសហគមន៍

-ការបណ្តាក់ទុនដោយក្រុមហ៊ុនឯកជន

:ធ្វើការបែងចែកផលចំណូលបានពីសម្បទានអភិរក្សនេះដល់សហគមន៍ ក្នុងទិសដៅបង្កើនជីវភាព ។

❖ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពលើការបោះបង្គោលព្រំ ការសិក្សាស្រាវជ្រាវ ការដាំដុះ ថ្នាលបណ្តុះកូនឈើ ដោយ មានការត្រួតពិនិត្យពីស្ថាប័នឯករាជ្យ :

-ត្រូវបង្កើតគណៈកម្មការចម្រុះដើម្បីឱ្យមានប្រសិទ្ធភាព

-ពង្រឹងសមត្ថភពដល់គណៈកម្មការដែលបានបង្កើតនោះ

-មានផែនការច្បាស់លាស់

-ជ្រើសរើសយកប្រព័ន្ធម៉ៅការក្នុងការបោះបង្គោលព្រំព្រៃ ។

បន្ទាប់ពីសំណួរចំលើយត្រូវបានចោទសួរនិងបកស្រាយយ៉ាងក្បោះក្បាយពីសំណាក់សិក្ខាកាម និងវាគ្មិនរបស់អង្គ សិក្ខាសាលារួចមក ព្រះសង្ឃ តំណាងក្រសួង-មន្ទីរ អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អ្នកសារពត៌មានបានចូលរួម ធ្វើសេចក្តីថ្លែងការពាក់ព័ន្ធជាមួយនឹងសិក្ខាសាលា កម្មវិធីព្រៃឈើជាតិ ព្រមទាំងបានផ្តល់នូវអនុសាសន៍ និងសំណូមពរមួយ ចំនួនជូនដល់អង្គសិក្ខាសាលា រដ្ឋបាលព្រៃឈើ ដែលក្នុងន័យរួមចំណែក និងជួយជំរុញឱ្យកម្មវិធីព្រៃឈើជាតិនេះប្រព្រឹត្តទៅបាន ជោគជ័យ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព ស្របតាមគោលដៅអភិវឌ្ឍន៍ សហស្សវត្ស កម្ពុជា ។

***គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ជាទីគោរព***

ជាថ្មីម្តងទៀត ក្នុងនាមអង្គសិក្ខាសាលាទាំងមូល ខ្ញុំសូមសំដែងនូវការគោរពដឹងគុណ និងកតញ្ញូតាធមិដ៏ជ្រាលជ្រៅ បំផុតចំពោះវត្តមានរបស់ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលបានអញ្ជើញមកពីខេត្ត នានា ពិសេសក្នុងខេត្តកំពង់ចាម ព្រមទាំងមានការចូលរួមពីតំណាងក្រសួង មន្ទីរ-អង្គភាពពាក់ពន្ធ័ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សារពត៌មាន ព្រះសង្ឃ និងសហគមន៍ព្រៃឈើ ចូលរួមក្នុងសិក្ខាសាលាស្តីពីការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ដែលបានប្រព្រឹត្តិទៅអស់រយៈពេល២ថ្ងៃនេះ។ សកម្មភាពទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញា បានចូលរួមផ្តល់វិភាគទានដ៏មានតំលៃ ក្នុងការកសាងនូវកម្មវិធីព្រៃឈើជាតិរបស់យើង មានលក្ខណៈជាតិស្របទៅតាមតំរូវការក្នុងមូលដ្ឋាន មានតម្លាភាព និងមាន សុខដុមនីយកម្មទៅនឹងច្បាប់ស្តីពីព្រៃឈើ គោលនយោបាយយុទ្ធសាស្ត្រចតុកោណជំហានទី ២ របស់រាជរដ្ឋាភិបាល និង គោលដៅ អភិវឌ្ឍសហសវត្សន៍កម្ពុជា ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើរបស់យើងប្រកបដោយនិរន្តភាព សំរាប់ កូនចៅជំនាន់ក្រោយ ។

សំរាប់ឱកាសនេះ ខ្ញុំព្រះកុរណា ខ្ញុំបាទសូមអនុញ្ញាតប្រគេនពរ និងគោរពជូនពរចំពោះឯកឧត្តម អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ជួបប្រទះនូវជ័យជំនះ សំណាងល្អ និង សុភមង្គលគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរព្រះគុណ និងអរគុណ !***